**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Science Économiques

Royal University of Law and Economics


**សារណាបញ្ចប់ការសិក្សា**

# សិទ្ធិសន្តតិកម្មរបស់អនីតិជននៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០២២


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ កញ្ញា **ប៊ុន ឌីណា**

កញ្ញា **លឹម គឹមឆេង**

សាស្ត្រាចារ្យណែនាំ

លោក **រុន ពណ្ណារិទ្ធ**



ថ្នាក់បរិញ្ញាបត្រ៖ **នីតិសាស្ត្រ**

ជំនាន់ទី ៖ ២២

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# **សេចក្តីថ្លែងអំណរគុណ**

នាងខ្ញុំទាំងពីរនាក់ឈ្មោះ **ម៉ុន ឌីណា** និង **លឹម គឹមឆេង** ជានិស្សិតថ្នាក់ L4C6 ផ្នែកបរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី ៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៨ ដល់ឆ្នាំ ២០២២ ជំនាន់ទី ២២។

## **សូមគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**

លោកតា **ម៉ុន មឿន** និងលោកយាយ **គ្រី ឡាយហ៊ាប**

លោកឪពុក **ម៉ុត្ត សាមិត្ត** និង អ្នកម្តាយ **ម៉ុន ផារ៉ុន**

លោកឪពុក **សាន កប** និងអ្នកម្តាយ **តាន់ សុខចេង**

ដែលលោកទាំងអស់បានផ្តល់កំណើតដល់រូបកូន ថែមទាំងបានចិញ្ចឹមបីបាច់ថែរក្សា ការពារ អប់រំទូន្មាន ជាពិសេសនោះបានប្រៀនប្រដៅកូនបានល្អ លើកទឹកចិត្ត ក៏ដូចជាផ្គត់ផ្គង់គ្រប់បែបយ៉ាង ទាំងថវិកា ទាំងកម្លាំងកាយកម្លាំងចិត្ត និងបានទំនុកបម្រុងដល់រូបកូនទាំងពីរអោយបានរៀនសូត្រ តាំងពីនៅវ័យកុមាររហូតដល់ពេញវ័យ។ គុណូបការរបស់អ្នកមានគុណទាំងអស់ មានទំហំធំធេងណាស់គ្មានអ្វីប្រៀបផ្ទឹមប្រដូចបានឡើយ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះ ឯកឧត្តម **លុយ ចន្ថា** សាកលវិទ្យាធិការ សាកលវិទ្យាធិការរងនៃព្រឹទ្ធបុរស និងព្រឹទ្ធបុរសរង ព្រមទាំងលោក លោកស្រី សាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចំណាយពេលវេលាដ៏មានតម្លៃមិនអាចកាត់ថ្លៃបាន ក្នុងការបង្រៀនដោយយកចិត្តទុកដាក់នូវក្នុងការផ្តល់ចំណេះដឹងដល់និស្សិតគ្រប់រូបដោយមិនលំអៀង ដើម្បីអោយនិស្សិតទទួលបានចំណេះវិជ្ជា និងបទពិសោធល្អៗឆ្ពោះទៅរកអនាគតល្អនៅថ្ងៃមុខ។

សូមថ្លែងអំណរគុណជាពិសេសដល់ លោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** ដែលជាសាស្ត្រាចារ្យដឹកនាំក្នុងការសិក្សាស្រាវជ្រាវ និងអ្នកគ្រូសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ដែលលោកទាំងពីរ ជាសាស្ត្រាចារ្យជំនាញមានបទពិសោធន៍ក្នុងការបង្រៀនជាច្រើនឆ្នាំ។ ជាពិសេសនោះ លោកជាសាស្ត្រាចារ្យឆ្នើមដែលបានដឹកនាំយើងខ្ញុំក្នុងការចងក្រងសៀវភៅមួយក្បាលនេះគឺ «**សិទ្ធិសន្តិកម្មរបស់អនីតិជននៅកម្ពុជា**» ឱ្យទទួលបានជោគជ័យមួយរយភាគរយ ដោយលោកបានផ្តល់យោបល់ល្អៗ និងបានកែសម្រួលនូវកំហុសទាំងឡាយដូចជា ខ្លឹមសារ អក្ខរាវិរុទ្ធ មុននឹងចេញជាសៀវភៅមួយក្បាលនេះ។ ជាចុងក្រោយ នាងខ្ញុំទាំងពីររូបសូមជូនពរ និងបួងសួងដល់វត្ថុស័កសិទ្ធទាំងអស់នៅក្នុងលោក សូមជួយតាមថែរក្សាអោយលោកទាំងអស់ឱ្យជួបតែពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានសិក្សាអស់រយៈពេល ៤ ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកនីតិសាស្ត្រ នេះមកបានធ្វើអោយនាងខ្ញុំទាំងពីរ មានការកត់សម្គាល់នូវមុខវិជ្ជាទាក់ទងនឹងសន្តតិកម្មដែលជាទីចាប់អារម្មណ៍ ជាពិសេសចំពោះអនីតិជននេះតែម្តងរហូតដល់នាងខ្ញុំទាំងពីរបានធ្វើការសម្រេចចិត្តជ្រើសរើសសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយ ដែលមានចំណងជើងស្តីអំពី សិទ្ធិសន្តតិកម្មរបស់អនីតិជននៅកម្ពុជា ជាសារណាបញ្ចប់ការសិក្សារបស់នាងខ្ញុំទាំងពីរ ដែលបានខិតខំសហការគ្នាស្រាវជ្រាវ និងបានចងក្រងឡើង សម្រាប់ចែករំលែកជា ចំណេះដឹងដល់និស្សិតជំនាន់ក្រោយធ្វើការស្វែងយល់ជាឯកសារយោង។

ការសិក្សាលើប្រធានបទមួយនេះក្នុងគោលបំណង ដើម្បីយល់ដឹងបន្ថែមឱ្យកាន់តែស៊ីជម្រៅ អំពីការទទួលបាននូវ សិទ្ធិសន្តតិកម្មដែលសន្តតិជន ជាអនីតិជននៅប្រទេសកម្ពុជាត្រូវទទួលបាន។ ជាពិសេសនោះតើសន្តតិជនដែលជាអនីតិជនមានសិទ្ធិអ្វីខ្លះ នៅពេលដែលសន្តតិកម្មបានកើតឡើង? មូលហេតុដែលនាងខ្ញុំទាំងពីរផ្តោតសំខាន់ទៅលើសិទ្ធិសន្តតិកម្មរបស់អនីតិជននោះគឺ មនុស្សគ្រប់គ្នាត្រូវយល់ច្បាស់ពីសន្តតិកម្មជាពិសេសនោះគឺ អនីតិជនដែលជាសន្តតិជន ព្រោះថាការបែងចែកមត៌កមានសារៈសំខាន់ណាស់ចំពោះមនុស្សនៅក្នុងគ្រួសារមួយ ជួនកាលក៏អាចបង្កើតជាជម្លោះបានដែរ។ ក្នុងនោះផងដែលអនីតិជនទាំងអស់ ក៏ត្រូវយល់ដឹងដូចគ្នានូវសិទ្ធិ និងករណីយកិច្ចរបស់ខ្លួននៅក្នុងរបបសន្តតិកម្មនោះ។ ដូចនេះ នៅពេលដែលអនីតិជនបានយល់ដឹងនោះ គេអាចបានទទួលនូវចំណែករបស់គេទៅតាមច្បាប់ដែលបានកំណត់។

នាងខ្ញុំទាំងពីរសង្ឃឹមថា អត្ថបទសារណាមួយនេះនឹងបានចូលរួមជាគំនិតខ្លះៗ ដល់សិស្សនិស្សិតជំនាន់ក្រោយបានសិក្សាស្វែងយល់ដើម្បីជា ឯកសារមួយសម្រាប់ការសិក្សាស្រាវជ្រាវ និងយល់ដឹងបន្ថែមឱ្យបានល្អប្រសើរ។

ជាទីបញ្ចប់ នាងខ្ញុំទាំងពីរសូមអភ័យទោសនូវរាល់ការកង្វះខាត ឬការធ្វេសប្រហែសណាមួយដោយអចេតនាពីយើងខ្ញុំទាំងពីររូប ប្រសិនបើមានការកង្វះខាតត្រង់ចំណុចណាមួយ នាងខ្ញុំទាំងពីរបានត្រៀមខ្លួនជាស្រេចក្នុងការទទួលមតិរិះគន់ស្ថាបនា ដើម្បីសិក្សាស្រាវជ្រាវបន្ថែម និងកែតម្រូវបន្តទៀត។

# មាតិកា

ទំព័រ

## សេចក្តីផ្តើម


១. លំនាំបញ្ហានៃការស្រាវជ្រាវ ........................................................ ១
២. ចំណោទបញ្ហានៃការដោះស្រាយ ........................................................ ២
៣. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........................................................ ២
៤. សារៈសំខាន់នៃប្រធានបទ ........................................................ ២


## ជំពូកទី ១

## លក្ខណៈទូទៅរបស់អនីតិជនជាសន្តតិជន


**១. សញ្ញាណទូទៅនៃអនីតិជន** ........................................................ ៤
១.១ លក្ខណៈនៃអនីតិជន ........................................................ ៤
១.២ ការទទួលបានអត្តាធីនភាព ........................................................ ៦
១.២.១ នីតិវិធីនៃការដាក់ពាក្យសុំអត្តាធីនភាព ........................................................ ៧
១.២.២ អានុភាពនៃអត្តាធីនភាព ........................................................ ៧
**២. សិទ្ធិអនីតិជនដែលទទួលបានដោយមាតាបិតា ឬអ្នកអាណាព្យាបាល** ........................................................ ៨
២.១ សិទ្ធិក្នុងការចាត់ចែងទ្រព្យសម្បត្តិ ........................................................ ៨
២.២ សិទ្ធិចាត់ចែងទ្រព្យសម្បត្តិដោយមិនកំណត់គោលបំណង ........................................................ ៩
២.៣ សិទ្ធិក្នុងការប្រកបអាជីវកម្ម ........................................................ ៩
**៣. អ្នកតំណាងស្របច្បាប់ក្នុងរបបសន្តតិកម្មរបស់អនីតិជន** ........................................................ ១១
៣.១ ការចាប់ផ្តើម និងការប្រព្រឹត្តទៅនៃរបបអាណាព្យាបាលសម្រាប់អនីតិជន ........................................................ ១១
៣.២ ករណីយកិច្ចរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ........................................................ ១៣


## ជំពូកទី ២

## លក្ខខណ្ឌដើម្បីឱ្យអនីតិជនទទួលបានសិទ្ធិសន្តតិកម្ម


**១. លក្ខណសម្បត្តិក្នុងការក្លាយជាសន្តតិជន** ........................................................ ១៧
**២. លក្ខណៈទូទៅ** ........................................................ ១៨

២.១ លក្ខណៈទូទៅនៃសន្តតិជនតាមច្បាប់ ........ ១៨
២.២ បុគ្គលដែលមានសិទ្ធិជាសន្តតិជន ........ ១៨
២.២.១ ករណីសន្តតិជនជាទារកស្ថិតនៅក្នុងគភ៌ ........ ១៩
២.២.២ ករណីសន្តតិជនជា រូបវន្តបុគ្គល ........ ១៩
**៣. ការកំណត់ពីសន្តតិជនតាមច្បាប់** ........ ២០
៣.១ លក្ខខណ្ឌទាក់ទងនឹងញាតិ ........ ២១
៣.៣ លក្ខខណ្ឌទាក់ទងនឹងសន្តតិជន ........ ២៤
**៤. ការបាត់បង់សិទ្ធិជាសន្តតិជន** ........ ៣០
៤.១ ករណីអភ័ព្វបុគ្គល ........ ៣០
៤.២ បុគ្គលត្រូវបានផ្តាច់ពីមត៌ក ........ ៣១

## ជំពូកទី ៣

## សិទ្ធិផ្សេងៗរបស់អនីតិជនក្នុងការទទួលបានសិទ្ធិសន្តតិកម្ម

**១. សិទ្ធិអនីតិជនដែលទទួលបានអត្តាធីនភាព** ........ ៣៥
**២. ការយល់ព្រមទទួលស្គាល់ និងការបោះបង់ចំពោះសន្តតិកម្ម** ........ ៣៦
២.១ ការយល់ព្រមទាំងស្រុង ........ ៣៧
២.២ ការយល់ព្រមដោយកម្រិត ........ ៣៩
**៣. ការបោះបង់ចោលសន្តតិកម្ម** ........ ៤០
៣.១ នីតិវិធី ........ ៤០
៣.២ អានុភាព ........ ៤១
**៤. ការកំណត់ចំណែកដែលសន្តតិជនទទួលបាន** ........ ៤២
៤.១ ការបែងចែកតាមការស្រុះស្រួលគ្នា ........ ៤២
៤.២ ការបែងចែកតាមផ្លូវតុលាការ ........ ៤៣
**សេចក្តីសន្និដ្ឋាន** ........ ៤៧
**អនុសាសន៍** ........ ៥០
**ឯកសារយោង**
**បញ្ជីឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលមានប្រវត្តិសាស្ត្រយូរលង់ណាស់មកហើយ ថែមទាំងមានប្រពៃណីទំនៀមទម្លាប់ជាច្រើន ដែលប្រជាជនទាំងអស់តែងតែធ្វើតាមគ្នារហូតមក។ ប្រជាជននៅប្រទេសកម្ពុជា មិនត្រឹមតែរៀបចំកូនចៅបានល្អទេ ថែមទាំងរៀបចំទុកដាក់ទ្រព្យសម្បត្តិក៏បានល្អផងដែរ។ កាលពីសម័យមុនមិនទាន់មាន ធនាគារទុកដាក់លុយកាក់របស់ប្រជាពលរដ្ឋឡើយទេ ដែលនាំឱ្យប្រជាពលរដ្ឋខ្លះយកទៅកប់ក្នុងដី ក្រោមពាង ក្រោមដី(ជណ្ដើរ) ខ្លះទៀតលាក់ក្នុងកន្លោះកន្លៀតដើម្បីទុកចែកអោយកូនចៅរបស់ខ្លួន។ កាលនោះប្រជាពលរដ្ឋខ្លះមានលុយកាក់ ដីស្រែ មាស រីឯប្រជាពលរដ្ឋខ្លះទៀតក៏មិនមាន ជាហេតុនាំប្រជាពលរដ្ឋដែលមានទុកសម្រាប់ឱ្យកូនចៅ ក៏ធ្វើការបែងចែកទ្រព្យរបស់គេទៅតាមប្រពៃណី។ សម័យមុនពេលដែលម្ចាស់ទ្រព្យបានទទួលមរណភាព នោះមត៌ករបស់គាត់ត្រូវបានបែងចែកទៅអោយសន្តតិជន ដែលជា កូន បងប្អូន សាច់ញាតិ ជាដើម ចំណែកឯប្រជាពលរដ្ឋកាលពេលនៅរស់មិនមានសហព័ទ្ធ កូន សាច់ញាតិ ឬមិនបានដឹងព័ត៌មានអំពីសាច់ញាតិរបស់គាត់ ដោយសារតែបានព្រាត់ប្រាស់គ្នា ក្នុងអំឡុងពេលមានសង្គ្រាម ឬក្រោយសង្គ្រាមដោយមិនដឹងថានៅមានជីវិត ឬក៏យ៉ាងណានោះ ទ្រព្យសម្បត្តិរបស់ពួកគាត់នឹងត្រូវបានកប់ចោលដោយមិនមាននរណាម្នាក់ដឹង ឬយកទៅធ្វើបុណ្យជាដើម។ ចំពោះការបែងចែកទ្រព្យនៅសម័យនោះវិញក្មេងៗដែលនៅជាអនីតិជន មិនទាន់មានសិទ្ធិ ក្នុងការកាន់កាប់ទ្រព្យសម្បត្តិឡើយ ដោយសារតែចាស់បុរាណគិតថា ក្មេងមិនទាន់មានសមត្ថភាពក្នុងការកាន់កាប់ទ្រព្យសម្បត្តិ ឬមត៌កនៅឡើយទេ។ ប៉ុន្តែផ្ទុយទៅវិញនៅក្នុងសម័យនេះ អនីតិជនមានសិទ្ធិស្មើទៅនឹងនីតិជន នៅក្នុងការទទួលបាននូវទ្រព្យសម្បត្តិ ក្រោយពេលដែលមតកជនបានទទួលមរណភាពទៅ។ នៅក្នុងក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ភាគច្រើនមានចែងអំពីសិទ្ធិ និងការកំណត់ផ្សេងៗរបស់នីតិជន រីឯការកមណត់អនីតិជនវិញត្រូវបានចាត់ទុក ជាជនស្ថិតនៅក្រោមការកម្រិតសមត្ថភាព។ ដូចនេះហើយទើបសិទ្ធិ កាតព្វកិច្ច និងសេរីភាពរបស់អនីតិជន មានភាពខុសគ្នាពីនីតិជនដោយការកម្រិតសមត្ថភាពរបស់អនីតិជននេះឯង។ ហើយការកម្រិតសមត្ថភាពនេះ ដើម្បីជានាដល់ផលប្រយោជន៍របស់អនីតិជនក៏ដោយក៏ ពួកគេមានសិទ្ធិទទួលនូវបទពិសោធនិងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើសកម្មភាពសំខាន់ៗដែរ។

## ២. ចំណោទបញ្ហានៃការដោះស្រាយ

ដូចដែលបានរៀបរាប់ខាងលើ អនីតិជន គឺជាបុគ្គលមួយរូបនៅក្នុងគ្រួសារដែលពួកគេមានសិទ្ធិ និងកាតព្វកិច្ចដូចនីតិជនដែរ។ ដើម្បីជាការស្វែងរក ក៏ដូចជាការបកស្រាយនូវបញ្ហារបស់អនីតិជននោះ នាំអោយមានចំណោទបញ្ហាចោទមកថាៈ

**តើសន្តតិជននៃសន្តតិកម្មមានសិទ្ធិ និងករណីយកិច្ចដូចម្តេច? រីឯ សន្តតិជនជាអនីតិជនវិញ តើបុគ្គលនោះមានសិទ្ធិសម្រេចលើទ្រព្យរបស់គាត់ដូចម្តេចខ្លះ? តើការទទួលរបបសន្តតិកម្ម របស់អនីតិជននោះមានអានុភាពដែរ ឬទេ?**

## ៣. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

អត្ថបទសារណានេះមានគោលបំណងរៀបរាប់ឱ្យបានច្បាស់លាស់អំពីសិទ្ធិ និងករណីយកិច្ចរបស់អនីតិជនក្នុងដំណើរការសន្តតិកម្មមួយ។ ក្នុងការស្រាវជ្រាវនេះ យើងនឹងរៀបរាប់ដោយផ្អែកលើបញ្ញត្តិច្បាប់នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ និងអត្ថបទច្បាប់នានា ដែលទាក់ទងទៅនឹងសន្តតិកម្ម បូករួមនឹងចំណេះដឹងដែលបានសិក្សាកន្លងមកពីសំណាក់លោកគ្រូអ្នកគ្រូ សាស្ត្រាចារ្យ ក្នុងរយៈប៉ុន្មានឆ្នាំកន្លងមកនេះ។ ការសិក្សាលើ **ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា** ជាចំណុចខ្លាំងមួយ ដែលអាចអោយយើងបានយល់កាន់តែស៊ីជម្រៅនៃ ច្បាប់សន្តតិកម្ម ដោយហេតុថា មាត្រាដែលបានរៀបរាប់នៅក្នុងក្រមនេះត្រូវបានអនុម័ត និងដាក់អោយប្រើប្រាស់នៅក្នុងប្រទេសកម្ពុជាតែម្តង។ ចំណែកឯដែនកំណត់នៃអត្ថបទសារណានេះវិញ ពួកយើងទាំងពីរនាក់បានសិក្សាតែទៅលើអត្ថបទច្បាប់នានា នៃព្រះរាជាណាចក្រកម្ពុជា តែប៉ុណ្ណោះ។

## ៤. សារៈសំខាន់នៃប្រធានបទ

សៀវភៅជាច្រើនបានធ្វើការបោះពុម្ពទាក់ទងទៅនឹង សន្តតិកម្ម ក៏ប៉ុន្តែជាទូទៅយើងពុំសូវឃើញមានការផ្តោតសំខាន់ទៅលើសន្តតិជនជាអនីតិជននោះទេ។ នេះជាមូលហេតុមួយ ដែលនាំអោយមានពាក្យមួយពោលឡើងថា ក្មេងមិនមានសិទ្ធិដូចមនុស្សធំក្នុងការទទួលបានមត៌កទេ ឬក៏នៅក្មេងត្រូវទទួលបានចំណែកតិចជាដើម នេះជាមូលហេតុចម្បងមួយ ដែលបណ្តាលអោយអនីតិជនទាំងនោះត្រូវបានគាបសង្កត់នៅពេលដែលមានសន្តតិកម្មកើតឡើង។ បច្ចុប្បន្ននេះ យើងពុំសូវឃើញមានការបែកចែកមត៌កនោះទេ ដោយនៅក្នុងគ្រួសារមួយភាគធំគេគិតថា ការធ្វើសន្តតិកម្មពុំមានសារៈសំខាន់ឡើយ ជាពិសេសសន្តតិកម្មសម្រាប់សន្តតិជនជាអនីតិជននេះតែម្តង។ ដូចនេះហើយ បានជាអត្ថបទសារណានេះ មានសារៈសំខាន់ណាស់នៅក្នុងការអានដើម្បីស្វែងយល់អោយកាន់តែច្បាស់ក្នុងការធ្វើជាប្រយោជន៍ និងអាចចែករំលែកទៅអ្នកជុំវិញខ្លួនបាន។

# ជំពូកទី ១
# លក្ខណៈទូទៅរបស់អនីតិជនជាសន្តតិជន

# ជំពូកទី ១

# លក្ខណៈទូទៅរបស់អនីតិជនជាសន្តតិជន

## និយមន័យ

មុននឹងធ្វើការសិក្សាឱ្យបានស៊ីជម្រៅនូវអត្ថបទនេះ យើងគប្បីគួរតែយល់នូវនិយមន័យរបស់ពាក្យមួយចំនួនជាមុនសិនដូចជា៖ សិទ្ធិ អនីតិជន សន្តតិកម្ម និងសន្តតិជនជាដើម។ ដោយពាក្យទាំងនេះនឹងមានលេចឡើងនៅក្នុងអត្ថបទសារណាទាំងមូល។ យោងទៅតាមវចនានុក្រមរបស់សម្តេចសង្ឃរាជ ជួន ណាត និងសទ្ទានុក្រមផ្នែករដ្ឋប្បវេណី បានឱ្យនិយមន័យពាក្យ **"សិទ្ធិ"** គឺជាសេចក្តីសម្រេច ឬផលសម្រេច ការសម្រេចប្រយោជន៍ ការសមតាមបំណង សេចក្តីសម្រេចតាមអំណាចច្បាប់។ រីឯពាក្យ **"អនីតិជន"** គឺជាពាក្យពេចន៍នៃវិស័យច្បាប់ជាគោលការណ៍មួយក្នុងចំណោមគោលការណ៍ទូទៅ ដែលជាការកំណត់អាយុរបស់រូបវន្តបុគ្គលណាម្នាក់ ដែលត្រូវបានគិតថា ពុំមានសមត្ថភាពក្នុងការវិនិច្ឆ័យទៅលើសកម្មភាពរបស់ខ្លួន ដូចនេះនឹងត្រូវបានការពារដោយច្បាប់។[1] ចំណែកឯពាក្យ **"សន្តតិកម្ម"** យោងទៅតាមសទ្ទានុក្រមផ្នែករដ្ឋប្បវេណី បានអោយនិយមន័យថា ការផ្ទេរទ្រព្យសម្បត្តិទាំងឡាយណារបស់បុគ្គលណាម្នាក់ ដែលបានទទួលមរណភាពនោះ អាចជាការផ្ទេរតាមឆន្ទៈរបស់បុគ្គលដែលបានស្លាប់ ឬតាមផ្លូវច្បាប់។[2] អ្នកដែលត្រូវបានទទួលមរណភាពនោះត្រូវបានគេហៅថា **"មតកជន"** រីឯ អ្នកដែលត្រូវទទួលសន្តតិកម្មបន្តពីមតកជននោះ ហៅថា **"សន្តតិជន"** ។[3]

នៅក្នុងការសិក្សាទៅលើសិទ្ធិសន្តតិកម្មរបស់អនីតិជន យើងត្រូវតែយល់អំពីសញ្ញាណទូទៅនៃ សិទ្ធិ និងករណីយកិច្ចរបស់អនីតិជនជាមុនសិន ក៏ដូចជាអ្នកដែលមានសិទ្ធិអំណាចមេបា និងអ្នកអាណាព្យាបាលទូទៅសម្រាប់អនីតិជនផងដែរ។

## ១. សញ្ញាណទូទៅនៃអនីតិជន

ចំពោះសញ្ញាណទូទៅរបស់អនីតិជនដែលមាននៅក្នុងក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា មានគោលការណ៍សំខាន់ ២ គឺ **លក្ខណៈនៃអនីតិជន(១.១) និងអត្តាធីនភាព (១.២)**[4]។

### ១.១ លក្ខណៈនៃអនីតិជន

នៅក្នុងសង្គមនីមួយៗ ការកំណត់នូវលក្ខណៈរបស់អនីតិជន មានលក្ខណៈខុសៗគ្នាទៅតាមបរិបទសង្គមនៅក្នុងរដ្ឋនីមួយៗ។ រីឯការកំណត់លក្ខណៈរបស់អនីតិជននៅក្នុងប្រទេសកម្ពុជាវិញ បានបង្ហាញនូវ

---

[1] សទ្ទានុក្រមផ្នែករដ្ឋប្បវេណី ទំព័រលេខ ២៧

[2] សទ្ទានុក្រមផ្នែករដ្ឋប្បវេណី ទំព័រលេខ ២១

[3] សទ្ទានុក្រមផ្នែករដ្ឋប្បវេណី ទំព័រលេខ ២១

[4] សទ្ទានុក្រមផ្នែករដ្ឋប្បវេណី ទំព័រលេខ ២៦

លក្ខណៈសំខាន់ៗដែលមានក្នុង ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលជាគោលនូវការកំណត់ជាចាំបាច់។ ក្នុងនោះដែរ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា បានកំណត់ និងផ្តល់អត្ថន័យ អនីតិជន ដោយសំដៅទៅលើជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ។[5] ប៉ុន្តែនៅក្នុងក្រមរដ្ឋប្បវេណី នៃប្រទេសជប៉ុនគេបានកំណត់អាយុរបស់អនីតិជនត្រឹម ២០ (ម្ភៃ) ឆ្នាំ ទៅតាមតំបន់ផ្សេងៗ។[6] ទោះបីជា ការកំណត់នៅក្នុងក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា បានបញ្ជាក់យ៉ាងច្បាស់លាស់អំពីលក្ខណៈនៃអនីតិជនក៏ដោយក៏ប៉ុន្តែការកម្រិតសកម្មភាពនៅក្នុងការធ្វើសកម្មភាពនេះនៅមានកម្រិតនៅឡើយ។ ថ្វីត្បិតតែ អនីតិជនត្រូវបានកំណត់សកម្មភាពដោយច្បាប់ក៏ពិតមែនក៏មិនមែនមានន័យថា អនីតិជនមិនអាចទទួលបាននូវសិទ្ធិសន្តតិកម្មពីមតកជនបានដែរ។ ជាគោលការណ៍ រាល់សកម្មភាពរបស់អនីតិជនបានធ្វើទាក់ទងទៅនឹងទ្រព្យសម្បត្តិនោះ អ្នកដែលមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវធ្វើការទទួលខុសត្រូវក្នុងនាមជាអ្នកតំណាងអោយអនីតិជនពាក់ព័ន្ធទៅនឹងសកម្មភាពទាំងនោះ។ ករណីប្រសិនបើ អនីតិជនទទួលសន្តតិកម្មពីមតកជន ដែលជាសកម្មភាពឯកតោភាគីរបស់មតកជនបានធ្វើចំពោះអនីតិជនដែលជាកូននោះ ដូចនេះសហព័ទ្ធដែលរស់នៅជាមួយជាអ្នកមានសិទ្ធិអំណាចមេបា ឬប្រសិនបើគ្មានសហព័ទ្ធរបស់មតកជននៅរស់ទេ អ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវមានសិទ្ធិចាត់ចែងធ្វើការយល់ព្រម ឬបោះបង់សន្តតិកម្មនោះក្នុងនាមជាអ្នកតំណាង ដើម្បីធ្វើការការពារផលប្រយោជន៍របស់អនីតិជន។ ចំណែកឯ អនីតិជន ដែលបានធ្វើដោយមិនបានទទួលការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនវិញ អាចបោះបង់សន្តតិកម្មនោះបាន។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តន៍ឡើយ ចំពោះសកម្មភាពដែលទទួលសិទ្ធិ ឬឱ្យរួចផុតពីកាតព្វកិច្ចក៏ដូចជាសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ។ យោងតាមក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១៩ បានចែងថា ការចាត់ចែងទ្រព្យសម្បត្តិ ដែលអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលទូទៅសម្រាប់អនីតិជនអនុញ្ញាតឱ្យចាត់ចែងទ្រព្យសម្បត្តិដោយកំណត់គោលបំណង ក្នុងទំហំនៃគោលបំណងនេះបាន។[7] មាត្រាបានសំដៅដល់ករណី អ្នកដែលមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនបានផ្តល់ទ្រព្យសម្បត្តិដែលមានដូចជា ប្រាក់កាស ដល់អនីតិជនដោយបានកំណត់គោលដៅប្រើប្រាស់ ឬសម្រាប់ចាយវាយកំប៉ិកកំប៉ុកដោយដោយមិនកំណត់គោលដៅប្រើប្រាស់ជាដើម។ ចំពោះការទទួលសិទ្ធិ ឬការរួចផុតពីកាតព្វកិច្ច ដែលជាសកម្មភាពផ្តល់

[5] មាត្រា ១៧ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

[6] សៀវភៅណែនាំសិក្សា ច្បាប់រដ្ឋប្បវេណី ករណីប្រទេសជប៉ុន

[7] មាត្រា ១៩ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧

ប្រយោជន៍ដល់អនីតិជនវិញ អនីតិជនអាចធ្វើសកម្មភាពផ្សេងៗបាន ដោយមិនចាំបាច់មានការយល់ព្រមពីសំណាក់អ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះឡើយ។ នៅក្នុងករណីខ្លះ អនីតិជនក៏អាចជៀសផុតពីការកម្រិតសកម្មភាពក្នុងការធ្វើសកម្មភាពបាន នៅពេលអនីតិជននោះទទួលបាន **អត្តាធីនភាព (១.២)**។

## ១.២ ការទទួលបានអត្តាធីនភាព

ជាទូទៅរាល់សកម្មភាព ដែលបានប្រព្រឹត្តឡើងដោយអនីតិជន ដោយគ្មានការអនុញ្ញាតពីសំណាក់អ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលទេនោះ ជាគោលការណ៍គឺអាចលុបចោលបាន លុះត្រាតែជននោះបានដល់នីតិភាព។[8] ថ្វីត្បិតតែ នីតិភាព ត្រូវបានកំណត់ចាប់ពីអាយុ ១៨ ឆ្នាំឡើងទៅក៏ដោយ ក៏ប៉ុន្តែមានករណីមួយ ដែលអាចទទួលស្គាល់អំពីការដល់នីតិភាពមុនអាយុកំណត់បាន ដោយអនីតិជនត្រូវមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងត្រូវបានតុលាការប្រកាសឱ្យរួចផុតពីឋានៈជាអនីតិជន ករណីដែលទទួលបាននេះត្រូវបានគេហៅថា ‹‹អត្តាធីនភាព››។

យោងតាមសទ្ទានុក្រមផ្នែករដ្ឋប្បវេណី ‹‹អត្តាធីនភាព›› គឺជាស្ថានភាពមួយ ដែលផ្តល់ឱ្យអនីតិជនបានរួចផុតពីរបបអាណាព្យាបាលសម្រាប់អនីតិជន ឬរួចផុតពីអំណាចមេបា និងមានសមត្ថភាពដូចទៅនឹងនីតិជនដែរ។[9] អត្តាធីនភាព អាចមានអានុភាពធ្វើឱ្យច្បាប់ចាត់ទុកថា អនីតិជននោះបានដល់នីតិភាពហើយ (ក្លាយជាជនដែលមានសិទ្ធិដូចទៅនីតិជនមានអាយុគ្រប់ ១៨ ឆ្នាំផងដែរ) ព្រមទាំងអាចធ្វើសកម្មភាពសម្រេចផ្សេងៗបាន ដូចជានីតិជនដែរ។ ដោយសារតែអានុភាពនេះហើយ ដែលធ្វើអោយអនីតិជននោះអាចធ្វើសកម្មភាពពាណិជ្ជកម្មបាន ដូចជាការបើកអាជីវកម្មផ្ទាល់ខ្លួនដោយមិនចាំបាច់មានការអនុញ្ញាតពីម្តាយឪពុក (អ្នកដែលមានអំណាចមេបា) ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន។ អនីតិជន ព្រមទាំងអាចធ្វើសកម្មភាពទាក់ទងនឹងកិច្ចសន្យាដោយអាចបង្កើត កែប្រែ និងរំលត់កាតព្វកិច្ចបាន ជាពិសេសនោះអាចធ្វើនូវសកម្មភាពឯកតោភាគីបានផងដែរ។ លើសពីនេះទៅទៀត អនីតិជនក៏អាចទទួលបាននូវបុគ្គលភាពគតិយុត្ត (ភាពជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច) យ៉ាងពេញលេញទៀតផង។ យោងតាមមាត្រា ២១ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ការទទួលបានអត្តាធីនភាពកើតឡើងតាមរយៈពីរបែបគឺ តាមរយៈការដាក់ពាក្យសុំអត្តាធីនភាពទៅតុលាការ និងតាមរយៈការរៀបអាពាហ៍ពិពាហ៍។

---

[8] មាត្រា ១៨ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[9] មាត្រា ២១ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ជម្រើសទីមួយ ដែលអាចនាំឱ្យអនីតិជនទទួលបានអត្តាធីនភាព គឺតាមការប្រកាសរបស់តុលាការ។ ចំពោះការស្នើសុំត្រូវគោរពទៅតាម នីតិវិធីនៃការដាក់ពាក្យសុំអត្តាធីនភាព។

លក្ខខណ្ឌម្យ៉ាងទៀត ដែលអាចនាំឱ្យអនីតិជនអាចទទួលអត្តាធីនភាពគឺ តាមរយៈការរៀបអាពាហ៍-ពិពាហ៍។ យោងតាមក្រមរដ្ឋប្បវេណី អនីតិជន ដែលជាបុរស ឬនារីអាចនឹងរៀបអាពាហ៍ពិពាហ៍បាន ប្រសិនបើអនីតិជននោះមានអាយុមិនតិចជាង ១៦ ឆ្នាំ ហើយភាគីម្ខាងទៀតបានដល់នីតិភាព និងមានការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ។ ក្រោយពីរៀបអាពាហ៍ពិពាហ៍ស្របច្បាប់រួច អនីតិជននោះនឹងទទួលបានអត្តាធីនភាពដោយពុំចាំបាច់មានការប្រកាសរបស់តុលាការឡើយ។ គួរកត់សម្គាល់ផងដែរថា ដោយសារនៅក្នុងមាត្រា ៩៤៨ ក្រមរដ្ឋប្បវេណី បានចែងថា ក្នុងករណីដែលភាគីម្ខាងបានដល់នីតិភាព ហើយភាគីម្ខាងទៀតជាអនីតិជនដែលមានអាយុមិនតិចជាង ១៦ (ដប់ប្រាំមួយ)ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បាន និងនៅក្នុងមាត្រា ២២ ក្រមរដ្ឋប្បវេណី បានចែងថា អនីតិជនដែលទទួលបានអត្តាធីនភាពត្រូវបានចាត់ទុកថាបានដល់នីតិភាព ដូចនេះ អនីតិជនអាចរៀបអាពាហ៍ពិពាហ៍ ជាមួយភាគីម្ខាងទៀតដែលជាអនីតិជនទទួលបានអត្តាធីនភាពតាមរយៈការប្រកាសរបស់តុលាការបាន ព្រមទាំងអាចធ្វើឱ្យអនីតិជនដែលពុំមានអត្តាធីនភាពនោះ ក៏ទទួលបានអត្តាធីនភាពបានដែរ យោងទៅតាមមាត្រា ២២ ក្រមរដ្ឋប្បវេណី ឱ្យតែអាពាហ៍ពិពាហ៍នោះគោរពទៅតាមបញ្ញត្តិច្បាប់។

### ១.២.១ នីតិវិធីនៃការដាក់ពាក្យសុំអត្តាធីនភាព

ជាគោលការណ៍ ដើម្បីទទួលបាននូវអត្តាធីនភាព គឺត្រូវធ្វើតាមការដាក់ពាក្យស្នើសុំទៅតុលាការដោយអនីតិជនចាំបាច់ត្រូវមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំឡើងទៅ។ ក្រោយពីការដាក់ពាក្យស្នើសុំរួច តុលាការនឹងពិនិត្យមើលទៅលើស្ថានភាពនៃជីវភាពរស់នៅរបស់អនីតិជន និងភាពចាំបាច់ ក៏ដូចជាប្រយោជន៍នៃការទទួលបាននូវអត្តាធីនភាពរបស់អ្នកស្នើនោះ។ ករណីប្រសិនបើតុលាការពិនិត្យទៅឃើញថា ការស្នើសុំនេះសមស្របហើយ តុលាការអាចនឹងប្រកាសនូវអត្តាធីនភាពរបស់បុគ្គលនោះបាន ដោយមុននឹងប្រកាសត្រូវមានការសួរយោបល់ពីសំណាក់ជន ដែលមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនជាមុនសិន។

### ១.២.២ អានុភាពនៃអត្តាធីនភាព

#### ក. សិទ្ធិ និងករណីយកិច្ចនៃជនដែលទទួលបានអត្តាធីនភាព

ដូចបានលើកឡើងខាងលើនេះ អនីតិជនដែលទទួលបានអត្តាធីនភាពនឹងត្រូវទទួលបាននូវសិទ្ធិ និងកាតព្វកិច្ចដូចទៅនឹងនីតិជនដែលមានអាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ។ ក្នុងករណីនេះ មានន័យថា អនីតិជន ដែលទទួលបានអត្តាធីនភាពនឹងអាចមានសមត្ថភាពក្នុងការបង្កើតកិច្ចសន្យាបាន និងសកម្មភាព

ឯកតោភាគីដែលមានសុពលភាពតែម្នាក់ឯងបាន ដោយពុំចាំបាច់មានការយល់ព្រមពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនឡើយ។ ដូចគ្នានេះដែរ អនីតិជនដែលទទួលបានអត្តាធីនភាពនឹងត្រូវទទួលខុសត្រូវចំពោះកាតព្វកិច្ច ដែលបានកើតឡើងចាប់តាំងពីពេលទទួលបាននូវអត្តាធីនភាពរហូតមកដោយគោរពអនុលោមដូចគ្នាទៅនឹងនីតិជន។

**ខ.ភាពមិនរលត់នៃអត្តាធីនភាព**

យោងតាមការបកស្រាយអំពី ការទទួលបានអត្តាធីនភាព(១.២)កន្លងមកនេះ អនីតិជនអាចទទួលបានអត្តាធីនភាពតាមរយៈអាពាហ៍ពិពាហ៍ស្របច្បាប់ **ប៉ុន្តែចុះបើអនីតិជននោះត្រូវបានលែងលះគ្នា នៅក្នុងអំឡុងពេលមានអាយុចាប់ពី ១៦ ទៅក្រោម ១៨ ឆ្នាំវិញ តើសិទ្ធិ និងកាតព្វកិច្ចរបស់អនីតិជននោះ នឹងត្រូវបានបញ្ញត្តិដូចម្តេច?** ចំពោះករណីបន្ទាប់ពីលែងលះរួច អត្តាធីនភាពរបស់អនីតិជននោះពុំត្រូវរលត់ឡើយ យោងតាមមាត្រា ២១ ក្រមរដ្ឋប្បវេណី កថាខណ្ឌទី ៣ បានចែងថា ក្រោយពីការលែងលះហើយ អនីតិជននោះនៅតែត្រូវបានចាត់ទុកថាមានអត្តាធីនភាពដោយមានសិទ្ធិ និងកាតព្វកិច្ចដូចនីតិជនដដែល ដូចដែលបានលើកឡើងក្នុងចំណុច **ក** ខាងលើ។

## ២. សិទ្ធិអនីតិជនដែលទទួលបានដោយមាតាបិតា ឬអ្នកអាណាព្យាបាល

អនីតិជន គឺជាជនត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាព ក្នុងហេតុផលកង្វះសមត្ថភាពទៅលើការវិនិច្ឆ័យ។ ដូចនេះជារឿយៗ វាជាមូលហេតុដែលតែងតែផ្តល់នូវផលលំបាកទៅដល់អនីតិជនផ្ទាល់ក្នុងការសម្រេចចិត្តអ្វីមួយ។ នៅក្នុងការជួយសម្រួលដល់អនីតិជនអោយធ្វើសកម្មភាពផ្សេងៗមួយចំនួនបាននោះ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា បានចែងឱ្យអនីតិជនអាចធ្វើសកម្មភាពដោយខ្លួនឯងបាន ក្នុងករណីដែល អនីតិជនត្រូវបានទទួលការអនុញ្ញាតពីសំណាក់អ្នកដែលមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលរបស់អនីតិជនដែលជា អ្នកតំណាង។ អ្នកតំណាងទាំងនោះ គឺជាអ្នកមានកាតព្វកិច្ចមើលថែ និងការពារអនីតិជន ដូចនេះហើយ ទើបច្បាប់បានជឿជាក់ថាពួកគេអាចនឹងផ្តល់នូវសេចក្តីយល់ព្រមយ៉ាងត្រឹមត្រូវមួយលើសកម្មភាពណាដែលខ្លួនគិតថា អនីតិជននឹងមិនបាត់បង់ផលប្រយោជន៍។

ចំពោះសិទ្ធិ ដែលអនីតិជនទទួលបានពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវបានចែកចេញជាបីផ្នែក៖ **សិទ្ធិក្នុងការចាត់ចែងទ្រព្យសម្បត្តិ(២.១) សិទ្ធិក្នុងការចាត់ចែងទ្រព្យសម្បត្តិដោយមិនកំណត់គោលបំណង (២.២) និងសិទ្ធិក្នុងការប្រកបអាជីវកម្ម (២.៣)**។

### ២.១ សិទ្ធិក្នុងការចាត់ចែងទ្រព្យសម្បត្តិ

នៅក្នុងការចាត់ចែងទ្រព្យសម្បត្តិមួយ អនីតិជនត្រូវបានទទួលសិទ្ធិយ៉ាងពេញលេញក្នុងការចាត់ចែងទ្រព្យសម្បត្តិពីសំណាក់អ្នកដែលមានសិទ្ធិតំណាង គឺអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលអនីតិជន

យោងតាមមាត្រា ១៩ ក្រមរដ្ឋប្បវេណី បានចែងថា អនីតិជនអាចធ្វើការចាត់ចែងទ្រព្យសម្បត្តិដែលទទួលបានពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឱ្យចាត់ចែងដោយកំណត់គោលបំណងក្នុងទំហំនៃគោលបំណងនោះ។ ក្នុងករណីនេះ អនីតិជនអាចបង្កើតកិច្ចសន្យាដែលទាក់ទងនឹងទ្រព្យសម្បត្តិរបស់ខ្លួនបាន នេះមានន័យថា ក្នុងករណីអ្នកអាណាព្យាបាលមានទ្រព្យសម្បត្តិ ដូចជាប្រាក់ទៅអោយអនីតិជនប្រើប្រាស់នោះ អនីតិជនមានសិទ្ធិទទួលបាន និងប្រើប្រាស់ទ្រព្យនោះតាមគោលបំណងដែលបានអនុញ្ញាត។

## ២.២ សិទ្ធិចាត់ចែងទ្រព្យសម្បត្តិដោយមិនកំណត់គោលបំណង

ទោះបីជាមានការផ្តល់សិទ្ធិទៅលើអនីតិជន នៅក្នុងការចាត់ចែងទ្រព្យសម្បត្តិដោយមានការកំណត់គោលបំណងក៏ដោយ ក៏អនីតិជននៅតែមានភាពលំបាកក្នុងការអនុវត្តន៍ ឬធ្វើសកម្មភាពសម្រាប់ជីវភាពរបស់ខ្លួនដដែល ដោយហេតុថាការប្រើប្រាស់ទ្រព្យសម្បត្តិម្តងត្រូវតែកំណត់នូវគោលបំណង។ ប៉ុន្តែនៅក្នុងសង្គមផ្ទាល់ ពេលខ្លះអនីតិជនចាំបាច់ត្រូវការប្រើប្រាស់ទ្រព្យដែលខ្លួនរកបាន ឬទទួលបានពីប្រទានកម្មនោះ សម្រាប់សកម្មភាពតូចតាចដែលខ្លួនចាំបាច់ប្រើប្រាស់ភ្លាមៗជាប្រចាំថ្ងៃផងដែរ។

ដូចនេះ ក្រៅពីសិទ្ធិចាត់ចែងទ្រព្យសម្បត្តិដោយកំណត់គោលបំណង អនីតិជននោះក៏អាចមានសិទ្ធិចាត់ចែងនូវទ្រព្យសម្បត្តិដែលខ្លួនទទួលបានដោយមានការអនុញ្ញាតពីសំណាក់អ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនដោយមិនមានការកំណត់គោលបំណងបានផងដែរ។ ការលើកឡើងនេះគឺផ្អែកទៅលើមាត្រា ១៩ ក្រមរដ្ឋប្បវេណី ដែលបានចែងថា អនីតិជនក៏អាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឱ្យចាត់ចែងបាន ដោយមិនកំណត់គោលបំណងបានដែរ។ បញ្ញត្តិក្នុងមាត្រានេះទទួលស្គាល់ថា អនីតិជនមានសិទ្ធិក្នុងការចាត់ចែងទ្រព្យសម្បត្តិ ឬការចាយវាយកំប៉ិកកំប៉ុកដោយមិនបានកំណត់គោលដៅប្រើប្រាស់ ដោយសារការធ្វើសកម្មភាពនោះស្ថិតនៅក្នុងទំហំដែលបានទទួលការអនុញ្ញាតពីសំណាក់អ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនហើយកិច្ចសន្យា ដែលកើតឡើងពីសកម្មភាពរបស់អនីតិជននោះនឹងមានសុពលភាពពេញលេញ។

## ២.៣ សិទ្ធិក្នុងការប្រកបអាជីវកម្ម

ក្រៅពីសិទ្ធិដែលបានរៀបរាប់ខាងលើនេះ មានសិទ្ធិមួយទៀតដែលអនីតិជនអាចនឹងធ្វើសកម្មភាពបានដោយមានការអនុញ្ញាតពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន គឺសិទ្ធិក្នុងការប្រកបអាជីវកម្ម។[10] ដើម្បីឱ្យអនីតិជនមានជម្រើស ក្នុងការធ្វើឱ្យជីវភាពរបស់ខ្លួនមានភាពប្រសើរឡើង អនីតិជនត្រូវ

[10] មាត្រា ២០ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

បានផ្តល់នូវសិទ្ធិក្នុងការប្រកបអាជីវកម្មមួយ ឬច្រើនប្រភេទ ប៉ុន្តែការអនុញ្ញាតនេះ ត្រូវចាំបាច់មានការទទួលស្គាល់ពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនជាមុន។ យោងតាមមាត្រា ២០ នៃក្រមរដ្ឋប្បវេណីពីបានចែងថា អនីតិជនដែលបានទទួលការអនុញ្ញាតឱ្យប្រកបអាជីវកម្មមួយប្រភេទ ឬច្រើនប្រភេទពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវមានសមត្ថភាពដូចនីតិជនដែរចំពោះមុខជំនួញ។ បញ្ញត្តិនេះ បានអនុញ្ញាតឱ្យអនីតិជនអាចធ្វើអាជីវកម្មបាន បើសិនមានការទទួលស្គាល់ពីអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ក្រោយពីទទួលបានការយល់ព្រមនោះហើយ អនីតិជននឹងមានឯករាជ្យភាពចំពោះប្រតិបត្តិការក្នុងកិច្ចប្រកបអាជីវកម្មដូចនីតិជនដែរ។ ការកំណត់បែបនេះមានគោលបំណងសម្របសម្រួលទៅដល់ប្រតិបត្តិការជំនួញរបស់អនីតិជន ព្រោះថាបើគ្រប់ប្រតិបត្តិការទាំងអស់មុននឹងអាចដំណើរការបាន លុះត្រាតែមានការយល់ព្រមពីអ្នកសំណាក់អ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះសិន ដែលជាហេតុនាំអោយការប្រកបអាជីវកម្មនឹងមានសភាពរាំងស្ទះជួនកាលអាចធ្វើអោយខាតប្រយោជន៍ដល់អាជីវកម្ម ថែមទាំងអាចធ្វើឱ្យអាជីវកម្មនេះហាក់មិនសូវមានន័យ។ **ឧទាហរណ៍** ប្រសិនបើអនីតិជនបានប្រកបនូវអាជីវកម្មលក់ផ្លែឈើ នោះការនាំចូលផ្លែឈើ ក៏ត្រូវចាំមានការយល់ព្រមពីឪពុកម្តាយ ចំណែកការលក់ផ្លែឈើដល់អតិថិជនវិញ ក៏ត្រូវចាំបាច់ឱ្យឪពុកម្តាយផ្តល់ការយល់ព្រមនូវអាជីវកម្មនោះយើងអាចមើលឃើញថាអាជីវកម្មនោះពុំអាចប្រព្រឹត្តទៅបានដោយទទួលផលប្រយោជន៍នោះឡើយ។

ដូចនេះហើយ ក្រោយពីមានការយល់ព្រម អនីតិជនអាចនឹងមានសមត្ថភាពធ្វើសកម្មភាពក្នុងការធ្វើកិច្ចសន្យាជាចាំបាច់សម្រាប់អាជីវកម្មនោះ។ ពោល គឺមានសិទ្ធិក្នុងការធ្វើកិច្ចសន្យាចាំបាច់ផ្សេងៗ សម្រាប់អាជីវកម្មនោះ ប៉ុន្តែអនីតិជននោះពុំមានសមត្ថភាពបង្កើតកិច្ចសន្យាណាផ្សេងដែលអាចធ្វើអោយហួសពីទំហំនៃភាពចាំបាច់សម្រាប់អាជីវកម្មរបស់ខ្លួនឡើយ។ ការប្រព្រឹត្តទៅបាន លុះត្រាតែមានការយល់ព្រមពីសំណាក់អ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដោយគោរពទៅតាមបញ្ញត្តិដែលបានចែងនៅក្នុងច្បាប់។

បន្ថែមពីនេះ ប្រសិនអនីតិជនដែលបានអនុញ្ញាតឱ្យប្រកបអាជីវកម្មហើយ បែរជាយកដើមទុនសម្រាប់រកទទួលទានទៅលេងល្បែងស៊ីសង ឬទិញតែទំនិញដែលលក់មិនដាច់ជាដើម ដែលខុសពីអ្វីដែលអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនគិតនោះ អ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនអាចធ្វើការលុបចោល ឬកម្រិតនូវការអនុញ្ញាតដែលខ្លួនបានផ្តល់រួចហើយនោះបាន។[11] ប៉ុន្តែ

[11] មាត្រា២០ កថាខណ្ឌទី២ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ក្នុងករណីគ្រាន់តែការផ្លាស់ប្តូរគំនិតរបស់អ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះទេ ការលុបចោល ឬការកម្រិតការអនុញ្ញាតមិនអាចប្រព្រឹត្តបានឡើយ។ ប្រសិនបើ អនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម លុបចោលនូវការអនុញ្ញាតសមត្ថភាពក្នុងការធ្វើសកម្មភាពរបស់អនីតិជនខ្លួនឯងនោះ ត្រូវត្រលប់ទៅស្ថានភាពដើមដូច អនីតិជនធម្មតា។

## ៣. អ្នកតំណាងស្របច្បាប់ក្នុងរបបសន្តតិកម្មរបស់អនីតិជន

ជាគោលការណ៍ អនីតិជនដែលមានអាយុក្រោម ១៨ឆ្នាំត្រូវបានច្បាប់សន្មតថា ជាជនទន់ខ្សោយខាងការបង្ហាញឆន្ទៈ។ ដូចនេះ អនីតិជនចាំបាច់ត្រូវមានការបណ្តុះបណ្តាលផ្នែកអប់រំ និងគ្រប់គ្រងពីសំណាក់អ្នកអាណាព្យាបាល។ ជាទូទៅ អ្នកដែលមានសិទ្ធិអំណាចតាមផ្លូវច្បាប់ក្នុងការគ្រប់គ្រងអនីតិជន គឺជាអ្នកមានអំណាចមេបា ដូចជាឪពុកម្តាយបង្កើត ឬឪពុកម្តាយចិញ្ចឹម។ ដូចដែលបានដឹងហើយថា អ្នកដែលមានអំណាចមេបាត្រូវមើលថែគ្រប់គ្រងអនីតិជនស្ថិតនៅក្នុងស្ថានភាពថែរក្សា ដូចនេះហើយទើបច្បាប់បានបង្កើតឱ្យមាននូវរបបអាណាព្យាបាលសម្រាប់អនីតិជន។ ការធ្វើបែបនេះ ជាការអនុញ្ញាតឱ្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនមានសិទ្ធិ និងករណីយកិច្ចមួយចំនួនជំនួសអ្នកមានអំណាចមេបា។ ជាពិសេសនោះ ការបង្កើតឱ្យមានរបបអាណាព្យាបាលត្រូវបានគោរពទៅតាមលក្ខខណ្ឌទម្រង់មួយចំនួន ដើម្បីធ្វើការប្រកាសរបបអាណាព្យាបាលសម្រាប់អនីតិជន ដែលនឹងត្រូវបកស្រាយនៅចំណុចដូចខាងក្រោម៖

### ៣.១ ការចាប់ផ្តើម និងការប្រព្រឹត្តទៅនៃរបបអាណាព្យាបាលសម្រាប់អនីតិជន

វាជាការចាំបាច់ណាស់ ក្នុងការបង្កើតរបបអាណាព្យាបាលសម្រាប់អនីតិជននៅពេលមានអត្ថិភាពនៃអំណាចមេបា។ ដូចនេះហើយទើប របបអាណាព្យាបាលសម្រាប់អនីតិជនត្រូវបានបង្កើតឡើង ក្នុងករណីដែលមានអង្គហេតុមួយចំនួនកើតមានដូចជា ការបាត់បង់អ្នកមានអំណាចមេបា ការកាត់កាលកូនសុំជាអាទិ៍ ដែលមូលហេតុទាំងនេះហើយ ទើបធ្វើឱ្យអំណាចមេបាត្រូវបានរលត់ថែមទាំងធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់អនីតិជនដែលកំពុងស្ថិតនៅក្នុងវ័យកម្រិតសមត្ថភាពនៅឡើយ។ ជាទូទៅ ការជ្រើសរើសអ្នកអាណាព្យាបាសម្រាប់អនីតិជន ត្រូវចាំបាច់ឆ្លងតាមនីតិវិធីតុលាការដោយឈរលើគោលគំនិតការពារផលប្រយោជន៍របស់អនីតិជនផ្ទាល់។ ការដែលអនុញ្ញាឱ្យមានការបង្កើតអាណាព្យាបាលសម្រាប់អនីតិជនក្រៅផ្លូវតុលាការអាចជួបផលវិបាកដូចជា ខ្វះលក្ខណសម្បត្តិ ខាតផលប្រយោជន៍អនីតិជន ជាពិសេសទ្រព្យសម្បត្តិរបស់អនីតិជន។

#### ក. មូលហេតុនៃការចាប់ផ្តើមរបបអាណាព្យាបាលសម្រាប់អនីតិជន

នត្ថិភាពនៃអ្នកមានអំណាចមេបា បានធ្វើឱ្យអនីតិជនស្ថិតនៅក្នុងស្ថានភាពពុំមានអ្នកគ្រប់គ្រង ដូចនេះហើយចាំបាច់ត្រូវតែបង្កើតឱ្យមានរបបសម្រាប់គ្រប់គ្រងអនីតិជន។ ការបង្កើតឱ្យមានរបបសម្រាប់គ្រប់គ្រង

អនីតិជននេះមានលក្ខណៈប្រហាក់ប្រហែលទៅនឹងអំណាចមេបាដែរ។ ប្រសិនបើអនីតិជន ក្រោយពេលមរណភាពនៃឪពុកម្ដាយ បានធ្វើលទ្ធកម្មនូវទ្រព្យសម្បត្តិមួយចំនួននោះ វាគឺជាការប្រសើរម្យ៉ាងបើមានអ្នកតំណាងឱ្យអនីតិជន ចំពោះការចាត់ចែងទ្រព្យសម្បត្តិទាំងនោះ។ ជាពិសេស នៅក្នុងរបបសន្តតិកម្មដោយសារតែអនីតិជនជាសន្តតិជនពុំអាចធ្វើសកម្មភាពដែលមានសុពលបានឡើយ។ លើសពីនេះ វាជាការសម្រេចចិត្តដ៏ល្អផងដែររបស់អ្នកមានអំណាចមេបាចុងក្រោយ មុនពេលមរណភាពបានផ្ដាំផ្ញើឱ្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនមើលថែរក្សាអនីតិជនឱ្យបានល្អតាមរយៈមតកសាសន៍នោះ។

## ខ. លក្ខខណ្ឌនៃការប្រកាសរបបអាណាព្យាបាលសម្រាប់អនីតិជន

របបអាណាព្យាបាលសម្រាប់អនីតិជន ត្រូវបានប្រកាសឡើងដោយដីកាសម្រេចរបស់តុលាការដោយឈរលើមូលដ្ឋាននៃ ច្បាប់ស្ដីពី នីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង យោងតាមឧបសម្ព័ន្ធទី ៤ ចំណុច ២៨ បានចែងថា តុលាការដែលមានសមត្ថកិច្ចក្នុងការចេញដីកាសម្រេចប្រកាសចាប់ផ្ដើមអាណាព្យាបាលសម្រាប់អនីតិជន គឺជាតុលាការនៃលំនៅឋានរបស់អនីតិជននោះ។ ការប្រកាសរបបអាណាព្យាបាលសម្រាប់អនីតិជនតុលាការអាចប្រកាសបានដោយឈរលើមូលដ្ឋានរួមមាន៖ **ការប្រកាសផ្អែកលើមតសាសន៍ (ខ.១) និងការប្រកាសផ្អែកលើពាក្យសុំ (ខ.២)។**

### ខ.១ ការប្រកាសផ្អែកលើមតកសាសន៍

កាលមតកជននៅមានជីវិត លោកត្រូវជាអ្នកមានអំណាចមេបាចំពោះអនីតិជន និងជាអ្នកដែលអាចកំណត់យកអ្នកណាជាអ្នកអាណាព្យាបាលសម្រាប់អនីតិជននៅក្នុងមតកសាសន៍បាន។ ក្នុងករណីនេះ តុលាការត្រូវសម្រេចតាមឆន្ទៈរបស់មតកជនជាចម្បង ផ្ទុយទៅវិញចំពោះអ្នកមានអំណាចមេបាដែលត្រូវបានតុលាការសម្រេចដកហូត ឬព្យួរវិញពុំមានសិទ្ធិកំណត់ជាអ្នកមានសិទ្ធិអាណាព្យាបាលសម្រាប់អនីតិជនបានឡើយ។ ទោះបីជា នៅក្នុងមតកសាសន៍បានកំណត់អំពីអ្នកអាណាព្យាបាលសម្រាប់អនីតិជនក៏ដោយ ក៏ពុំអាចបង្កើតអានុភាពគតិយុត្តនោះបានដែរ ដរាបណាពុំមានដីកាសម្រេចស្ដាពរពីតុលាការមានសមត្ថកិច្ច។

### ខ.២ ការប្រកាសផ្អែកលើពាក្យសុំ

ប្រសិនបើ រកមិនឃើញថាមានការបង្ហាញឆន្ទៈក្នុងការកំណត់ជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជននៅក្នុងមតកសាសន៍ទេនោះ តុលាការអាចសម្រេចតាមពាក្យសុំរបស់ញាតិក្នុង ៤ថ្នាក់ របស់អនីតិជនបានដោយប្រព្រឹត្តទៅដោយមេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់អនីតិជន នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬតំណាងអយ្យការបាន។[12]

[12] មាត្រា ១១៦៨ កថាខណ្ឌ២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ជាមូលដ្ឋាន ការសម្រេចសេចក្ដីរបស់តុលាការត្រូវពិចារណាលើស្ថានភាពផ្លូវកាយ ផ្លូវចិត្ត និងស្ថានភាពជីវភាពក៏ដូចជាទ្រព្យសម្បត្តិរបស់អនីតិជន វិជ្ជាជីវៈ និងប្រវត្តិរូបរបស់អ្នកដែលត្រូវធ្វើជា អ្នកអាណាព្យាបាលសម្រាប់អនីតិជន និងអត្ថិភាព ឬនត្ថិភាពនៃទំនាក់ទំនងផលប្រយោជន៍រវាងអ្នកអាណាព្យាបាលសម្រាប់អនីតិជន យោបល់របស់អនីតិជន និងស្ថានភាពផ្សេងៗទៀតជាដាច់ខាត។ ក្នុងករណី ដែលមានអ្នកអាណាព្យាបាលសម្រាប់អនីតិជនបានលាឈប់ ឬរបបអាណាព្យាបាលសម្រាប់អនីតិជនត្រូវបានលុបចោល នោះ តុលាការត្រូវធ្វើការជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនថ្មី តាមបញ្ញត្តិមាត្រា ១០៦៨ កថាខណ្ឌទី ២ នៃក្រមរដ្ឋប្បវេណី ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។ ដោយឡែក ដើម្បីធានានូវការអនុវត្តន៍ករណីយកិច្ចរបស់អ្នកអាណាព្យាបាលទូទៅបានពេញលេញ ច្បាប់ក៏បានបង្កើតឡើងឱ្យមាននូវប្រព័ន្ធត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន តាមនីតិវិធីជ្រើសតាំងដូចបានរៀបរាប់ខាងលើ។

## ៣.២ ករណីយកិច្ចរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន

ក្រោយពីមាន ការទទួលស្គាល់ដោយច្បាប់ជាធរមាន អំពីការគ្រប់លក្ខណសម្បត្តិជាអ្នកអាណាព្យាបាលសម្រាប់អនីតិជនរួចហើយនោះ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះនឹងត្រូវមានសិទ្ធិក៏ដូចជាករណីយកិច្ចមួយចំនួនដែលត្រូវតែធ្វើដើម្បីជាប្រយោជន៍សម្រាប់អនីតិជនក្នុងរបបសន្តតិកម្ម។ ករណីយកិច្ចទាំងអស់នោះ រួមមាន **ករណីយកិច្ចគ្រប់គ្រងថែរក្សាអនីតិជន (ចំណុច ក) ការគ្រប់គ្រងទ្រព្យសម្បត្តិ និងការតំណាង (ចំណុច ខ) និងករណីយកិច្ចគ្រប់គ្រងដោយប្រុងប្រយ័ត្ន (ចំណុច គ)**។

### ក. ករណីយកិច្ចគ្រប់គ្រងថែរក្សាអនីតិជន

យោងតាមមាត្រា ១០៧៩ កថាខណ្ឌទី១ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា បានចែងថា អ្នកអាណាព្យាបាលសម្រាប់អនីតិជនមានសិទ្ធិ និងករណីយកិច្ចដូចគ្នាទៅនឹងអ្នកមានអំណាចមេបាដែរ។ ការចែងដូចគ្នានេះ មិនមានន័យថាអ្នកអាណាព្យាបាលសម្រាប់អនីតិជនមានអំណាចមេបាចំពោះអនីតិជនឡើយ គឺគាត់គ្រាន់តែអនុវត្តន៍សិទ្ធិ និងករណីយកិច្ចដូចគ្នាទៅនឹងអ្នកមានអំណាចមេបាដែរ។ ចំពោះកិច្ចការមួយចំនួនដែលពាក់ព័ន្ធទៅនឹងការអប់រំ ការផ្ដល់ទីសំណាក់ ការដាក់ទណ្ឌកម្ម និងការអនុញ្ញាតឱ្យប្រកបអាជីវកម្ម ប្រសិនបើ មានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល ចាំបាច់ត្រូវមានការអនុញ្ញាតពីគាត់សិន។ ក្នុងករណី អ្នកអាណាព្យាបាលសម្រាប់អនីតិជនបានអនុវត្តន៍សិទ្ធិលើសពីទំហំនៃការកម្រិតសិទ្ធិតំណាងនោះ សកម្មភាពដែលបានធ្វើនឹងអាចជាមូលហេតុនៃការលុបចោលនៃរបបអាណាព្យាបាល។[13]

[13] មាត្រា ១១៩១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ខ. ការគ្រប់គ្រងទ្រព្យសម្បត្តិ និងការតំណាង

អ្នកអាណាព្យាបាលសម្រាប់អនីតិជន មានករណីយកិច្ចតំណាងឱ្យអនីតិជន នៅក្នុងការធ្វើសកម្មភាពនានា ដែលទាក់ទងទៅនឹងទ្រព្យសម្បត្តិរបស់អនីតិជន។ សកម្មភាពទាំងអស់នោះមានដូចជាៈ ការចុះកិច្ចសន្យាលក់ទិញ ការដាក់ពាក្យបណ្តឹងទាមទារជាអាទិ៍ ដោយសារតែអនីតិជន គឺជាអសមត្ថជននៅក្នុងការធ្វើសកម្មភាព ដូចនេះមានតែអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះទេ ទើបមានសិទ្ធិការពារផលប្រយោជន៍របស់អនីតិជននៅក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ និងការតំណាងក្នុងការធ្វើសកម្មភាពផ្សេងៗ។ ដើម្បីជៀសវាងវិវាទផលប្រយោជន៍ ក្រោយពេលចាប់ផ្តើមអាណាព្យាបាលសម្រាប់អនីតិជន អ្នកអាណាព្យាបាលសម្រាប់អនីតិជនត្រូវចាប់ផ្តើមស្រាវជ្រាវទ្រព្យសម្បត្តិរបស់អនីតិជន ឱ្យបានឆាប់រហ័សក្នុងអំឡុងពេល៣ខែ។ ការប្រព្រឹត្តនេះគិតចាប់ពីដីកាសម្រេចប្រកាសអាណាព្យាបាលសម្រាប់អនីតិជនចូលជាស្ថាពរ និងត្រូវធ្វើបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិនោះ។ ប្រសិនបើពុំដូចនេះទេ អនីតិជនដែលជាជនទន់ខ្សោយនៅតែបាត់បង់ផលប្រយោជន៍ ដោយសារខ្លួនពុំមានលទ្ធភាពអាចយល់ដឹងអំពីអត្ថិភាពនៃទ្រព្យរបស់ខ្លួន នេះជាហេតុដែលនាំឱ្យអ្នកអាណាព្យាបាលអាចឆ្លៀតឱកាសកេងចំណេញផលប្រយោជន៍របស់អនីតិជនបាន។

ម្យ៉ាងវិញទៀត ក្នុងករណីដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជនមានសិទ្ធិលើបំណុលចំពោះអនីតិជនអ្នកអាណាព្យាបាលនោះ ត្រូវរាយការណ៍អោយបានឆាប់រហ័សជូនអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន។

ប្រសិនបើ មានការខកខានការអនុវត្តន៍ករណីយកិច្ចនេះ (សិទ្ធិលើបំណុលរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន) ត្រូវរលត់ហើយ មិនអាចទាមទារវិញបានទេនៅពេលក្រោយដោយផ្អែកលើអាជ្ញាយុកាលនៃសិទ្ធិលើបំណុលធម្មតាបានឡើយ។ មួយវិញទៀត ករណីនៅក្នុងពេលអនុវត្តន៍សិទ្ធិ និងករណីយកិច្ចរបស់ខ្លួនអាចកើតមានភាពផ្ទុយគ្នារវាងផលប្រយោជន៍របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជន តាមពាក្យសុំដែលធ្វើឡើង តាមច្បាប់ ស្តីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនបណ្តឹង ផ្អែកតាមឧបសម្ព័ន្ធផ្នែកទី ៤ ចំណុចទី ២៦។ ក្នុងគោលបំណង មិនចង់ឱ្យការអនុវត្តន៍សិទ្ធិរបស់ខ្លួនធ្វើឱ្យកើតជា ផលប្រយោជន៍សម្រាប់ខ្លួនតែម្ខាងដោយសារតែអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដែលនេះគឺជាករណីយកិច្ចមួយត្រូវបានតែងតាំង។ ដូចនេះ រាល់ការចំណាយជាទូទៅក្នុងការអនុវត្តន៍សិទ្ធិ និងករណីយកិច្ចរបស់ខ្លួន ដូចជាការផ្គត់ផ្គង់ជីវភាពរស់នៅការចំណាយសម្រាប់ការព្យាបាលត្រូវជាបន្ទុកនៃទ្រព្យសម្បត្តិរបស់អនីតិជន។ ម្យ៉ាងទៀត ចំពោះតម្លៃតបនឹងការងារមើលថែរក្សាអនីតិជន ច្បាប់ក៏បានអនុញ្ញាតឱ្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនទទួលបាននូវកម្រៃដែលសម្រេចពីតុលាការនៅពេលប្រកាសចាប់ផ្តើមផងដែរ។

**គ. ករណីយកិច្ចគ្រប់គ្រងដោយប្រុងប្រយ័ត្ន អ្នកអាណាព្យាបាលសម្រាប់អនីតិជន**

ការគ្រប់គ្រងទៅលើអនីតិជនត្រូវបានអនុវត្តន៍សិទ្ធិ និងករណីយកិច្ចរបស់ខ្លួនក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត។ ក្នុងករណី មានវិវាទប៉ះពាល់ផលប្រយោជន៍រវាងអ្នកអាណាព្យាបាលសម្រាប់អនីតិជនជាមួយនឹងអនីតិជននោះ កាលបើអាណាព្យាបាលសម្រាប់អនីតិជនពុំបានសុំទៅតុលាការអោយមានការតែងតាំងអ្នកតំណាងពិសេសទេនោះ វាគឺជាការអនុវត្តន៍ករណីយកិច្ចទុច្ចរិត ដោយក្នុងស្ថានភាពបែបនេះ អនីតិជនអាចទាមទារសំណងនៃការខូចខាតដោយធ្វើសកម្មភាពឯករាជ្យ (ក្នុងប្ដឹងផ្ដល់តាមផ្លូវតុលាការ) ដោយខ្លួនឯងបានដោយពុំចាំបាច់មានការយល់ព្រមពីអ្នកតំណាងណាមួយឡើយ។

# ជំពូកទី ២

# លក្ខខណ្ឌដើម្បីឱ្យអនីតិជនទទួលបានសិទ្ធិសន្តិកម្ម

# ជំពូកទី ២

# លក្ខខណ្ឌដើម្បីឱ្យអនីតិជនទទួលបានសិទ្ធិសន្តតិកម្ម

## ១. លក្ខណសម្បត្តិក្នុងការក្លាយជាសន្តតិជន

សន្តតិជន គឺជាបុគ្គលដែលទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនតាមរយៈសន្តតិកម្ម។ ក្នុងនោះដែរ សន្តតិកម្មកើតឡើងដោយសារមូលហេតុនៃការបាត់ខ្លួន និងមរណភាពរបស់អ្នកផ្តើមសន្តតិកម្ម។ សន្តតិកម្ម ត្រូវបានចាប់ផ្តើមដោយសារមានមរណភាពរបស់មតកជន ហើយត្រូវស្វែងរកអ្នកដែលមានសិទ្ធិដើម្បីទទួលបន្តនូវទ្រព្យសម្បត្តិរបស់មតកជននោះ។ ចំណុចនេះមានន័យថា រាល់ការធ្វើសន្តតិកម្មគេមិនទទួលស្គាល់សន្តតិកម្ម នៅពេលដែលមតកជននៅរស់នោះទេ។ ការធ្វើសន្តតិកម្មមួយអាចចាប់ផ្តើមបាន នៅពេលដែលមតកជនបានទទួលមរណភាព និងនៅពេលមានការប្រកាសអំពីការបាត់ខ្លួនតែប៉ុណ្ណោះ។ ក្នុងករណីដែល មតកជនបានបាត់ខ្លួនមិនមានដំណឹងសោះអស់រយៈពេល៥ឆ្នាំ តុលាការអាចប្រកាសអំពីការបាត់ខ្លួនបានតាមពាក្យស្នើសុំរបស់សហព័ទ្ធ ជាអ្នកដែលត្រូវសន្មតថាជាសន្តតិជន ឬអ្នកដែលមានប្រយោជន៍តាមផ្លូវច្បាប់តាមការប្រកាសការបាត់ខ្លួន។[14]

សន្តតិកម្ម ចាប់ផ្តើមមានអានុភាពនៅពេលដែលសាសក្រមចេញជាស្ថាពរ។ ចំណុចនេះមានលក្ខណៈស្មុគស្មាញ ប្រសិនបើមតកជនបានបង្ហាញខ្លួនមកវិញបន្ទាប់ពីមានការប្រកាសអំពីការបាត់ខ្លួនរួច នាំឱ្យអានុភាពនៃសន្តតិកម្មត្រូវបានលុបចោលដោយមានការទាមទារពីសាមីខ្លួន។ នោះជាមូលហេតុ នាំឱ្យអ្នកត្រូវទទួលទ្រព្យសម្បត្តិបានបាត់បង់សិទ្ធិ ដោយសារតែការលុបចោលនូវការប្រកាសអំពីការបាត់ខ្លួន ហើយផលប្រយោជន៍ ដែលការទទួលបានត្រូវប្រគល់អោយម្ចាស់ដើមវិញ។ ទោះបីជាយ៉ាងណាក៏ដោយសិទ្ធិនិងករណីយកិច្ចមួយចំនួនរបស់មតកជនមិនត្រូវបានផ្ទេរទៅអោយសន្តតិជនទេ ពោលគឺសិទ្ធិនិងករណីយកិច្ចមួយចំនួនរបស់មតកជន (មានដូចជាសិទ្ធិ និងកាតព្វកិច្ចជាអាណាព្យាបាលជាដើម)។

ជាទូទៅ ដើម្បីក្លាយទៅជាសន្តតិជនតាមផ្លូវច្បាប់បុគ្គលទាំងអស់ត្រូវមានលក្ខណសម្បត្តិមួយចំនួនដូចជា ត្រូវមានជីវិតរស់នៅនាពេលចាប់ផ្តើមសន្តតិកម្ម ដោយពុំមែនជាអភ័ព្វបុគ្គលនៃសន្តតិកម្ម ឬពុំមែនជាបុគ្គលដែលត្រូវផ្តាច់ចេញពីមត៌កឡើយ។ ម្យ៉ាងវិញទៀត ប្រសិនបើបុគ្គលដែលជាសន្តតិជននោះជាជនបរទេសវិញ ឬក៏មិនមានសញ្ជាតិខ្មែរទេនោះ សន្តតិជននោះពុំមានសិទ្ធិទទួលបានដីធ្លីទេដោយបានចែងក្នុងមាត្រា ១១៥៥ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាផងដែរ ចំណែកុំឯក្នុងច្បាប់ភូមិបាលវិញ ក៏បានចែងដែលថា មានតែរូបវន្តបុគ្គលទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិនៅលើទឹកដីកម្ពុជា។ ការបង្ការដូចនេះ គឺជា

[14] មាត្រា ៤១ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

គោលបំណង ដើម្បីការពារទឹកដីជាតិរបស់យើងពីការលក់ទិញ ឬផ្ទេរទៅអោយជនបរទេសដែលនាំអោយមានការខូចប្រយោជន៍ជាតិ។ បន្ថែមពីនេះ បើយោងទៅតាមក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា សន្តតិជនត្រូវបានបែងចែកទៅជាច្រើនលំដាប់ផងដែរ ក្នុងគោលបំណងសម្គាល់នូវអាទិភាពរបស់សន្តតិជននីមួយៗថា **តើបុគ្គលណាមានអាទិភាពមុនគេក្នុងការទទួលបានមត៌កពីមតកជន?**

## ២. លក្ខណៈទូទៅ

### ២.១ លក្ខណៈទូទៅនៃសន្តតិជនតាមច្បាប់

សន្តតិជន គឺជាបុគ្គលដែលបន្ត ឬទទួលស្នងសិទ្ធិ និងកាតព្វកិច្ចនៅពេលដែលជននោះក្លាយជាសន្តតិជន។ ជាពិសេស បុគ្គលនោះត្រូវបានគោរពនូវលក្ខខណ្ឌមួយចំនួនទៀតដូចជា៖ មានជីវិតរស់នៅនាពេលចាប់ផ្ដើមសន្តតិកម្ម ឬមិនមែនជាអភ័ព្វបុគ្គលត្រូវបានផ្ដាច់ចេញមត៌ក ឬសញ្ជាតិខ្មែរជាអាទិ៍ ចំពោះមត៌កជាដីធ្លី ឬអចលនវត្ថុ។ ជាធម្មតា ជនដែលត្រូវសន្មតថាជាសន្តតិជនបាន គឺជាជនដែលមានជីវិតរស់នៅ ឬទារកក្នុងគភ៌នាពេលចាប់ផ្ដើមសន្តតិកម្មអាចទទួលសន្តតិកម្មបានលើកលែងតែ អភ័ព្វបុគ្គល ឬជនផ្ដាច់ចេញពីមត៌ក។ នៅក្នុងករណីផ្សេងទៀត ចំពោះសន្តតិជនដែលជាជនបានបាត់ខ្លួនវិញ នៅពេលដែលគាត់ត្រលប់មកវិញគាត់អាចទាមទារសិទ្ធិ ដើម្បីក្លាយជាសន្តតិជនវិញបាន។ យោងទៅតាមមាត្រា ៤៤ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានចែងថា ប្រសិនបើមានការបញ្ជាក់ថា បានទទួលមរណភាព នៅពេលខុសពីពេលដែលបានកំណត់នៅក្នុងមាត្រា ៤៣ (អានុភាពនៃការប្រកាសអំពីការបាត់ខ្លួនតាមពាក្យស្នើសុំរបស់សាមីខ្លួន ឬបុគ្គលដែលមានផលប្រយោជន៍)។ ចំណែកឯ បុគ្គលដែលត្រូវទទួលបានទ្រព្យសម្បត្តិដោយចំពោះ ដោយសារតែអានុភាពនៃការប្រកាសអំពីការបាត់ខ្លួនត្រូវបាត់បង់សិទ្ធិ ព្រោះការលុបចោលនូវការប្រកាសអំពីការបាត់ខ្លួនវិញនោះមានន័យថា បុគ្គលដែលបានបាត់ខ្លួនដោយពុំដឹងច្បាស់លាស់ថា នៅរស់ ឬក៏បានទទួលមរណភាព ដែលតុលាការបានប្រកាសការបាត់ខ្លួនតាមពាក្យស្នើសុំរបស់ជនមានប្រយោជន៍នោះហើយ ស្រាប់តែជននោះត្រលប់មកវិញ គាត់ត្រូវទទួលបានសិទ្ធិដោយទទួលបានមត៌កនៅក្នុងរបបសន្តតិកម្មនេះវិញ។ រីឯ បុគ្គលដែលទទួលបានទ្រព្យសម្បត្តិដោយសារអានុភាពនៃការប្រកាសអំពីការបាត់ខ្លួននោះ ត្រូវមានកាតព្វកិច្ចសងត្រលប់មកជនដែលបាត់ខ្លួននេះវិញនូវទ្រព្យដែលខ្លួនទទួលបាន។

### ២.២ បុគ្គលដែលមានសិទ្ធិជាសន្តតិជន

បុគ្គលដែលត្រូវបានចាត់ទុកជាសន្តតិជន ត្រូវទទួលចំណែកមត៌កត្រូវតែជាបុគ្គលទាំងឡាយណាដែលរស់រានមានជីវិត។[15] ហើយត្រូវទទួលបាននូវចំណែករបស់មតកជនដែលទាក់ទងទៅនឹងសមត្ថភាពខាង

[15] វចនានុក្រមសម្ដេចសង្ឃរាជ ជួន ណាត

អាស្រ័យផលរហូតដល់ថ្ងៃចាប់ផ្ដើមសន្តតិកម្ម ទោះបីជាទារកដែលស្ថិតនៅក្នុងគភ៌ ឬក៏ជារូបវន្តបុគ្គលក៏ដោយ។

### ២.២.១ ករណីសន្តតិជនជាទារកស្ថិតនៅក្នុងគភ៌

ទារកនៅក្នុងគភ៌ ក៏ចាត់ទុកថាជាសន្តតិជនទទួលបានចំណែកមត៌កពីមតកជនបានដែរ ប្រសិនបើទារកនោះ បានចាប់កំណើតមកហើយមានជីវិតរស់រានបាននៅក្រោយពេលដែលចាប់ផ្តើមសន្តតិកម្ម ទោះជាតាមច្បាប់ក្តី ឬតាមមតកសាសន៍ក្តី។[16] យោងតាមក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានបញ្ញត្តិអោយទារកក្នុងគភ៌របស់ម្តាយ ក៏អាចទទួលបានសិទ្ធិជាសន្តតិជនបានដែរតែលក្ខខណ្ឌនោះត្រូវតែរស់រានមានជីវិតក្រោយពេលកើត។ គោលការណ៍ចំពោះ ទារកនៅក្នុងគភ៌ត្រូវទទួលបានសិទ្ធិសន្តតិកម្ម ត្រូវបានកើតឡើងចាប់ពីពេលបើកសន្តតិកម្មមកម្ល៉េះ ដោយមិនមែនចាប់គិតពីថ្ងៃដែលកើតនោះទេ។ ការតាក់តែងច្បាប់បែបនេះ បានធ្វើអោយទារកក្នុងគភ៌មានសិទ្ធិទទួលបានផលប្រយោជន៍ដែលគេគួរតែទទួលបាន ដោយមានឋានៈជាសន្តតិជននៃសន្តតិកម្ម។ ហេតុនេះហើយ នៅពេលដែលទារកបានចាប់កំណើតមកទារកនឹងក្លាយជារូបវន្តបុគ្គល ពោល គឺទទួលបានបុគ្គលភាពគតិយុត្តរួមមានសិទ្ធិ និងកាតព្វកិច្ចទាំងឡាយណាដែលខ្លួននឹងអាចមាន។ ផ្ទុយទៅវិញ ប្រសិនបើទារកនៅក្នុងគភ៌នោះកើតមកហើយ ប៉ុន្តែបានបាត់បង់ជីវិតទៅវិញ មានន័យថា ទារកដែលបានបាត់បង់ជីវិតនោះមិនអាចក្លាយទៅជាសន្តតិជនទទួលបានចំណែកមត៌កដែលមាននៅពេលដែលសន្តតិកម្មចាប់ផ្តើមទេ គឺមិនគិតនាថ្ងៃដែលទារកចាប់កំណើតក្នុងផ្ទៃទេ។ ទារកក៏ជារូបវន្តបុគ្គលដែរ ដើម្បីអោយយល់កាន់តែច្បាស់ថែមទៀតនោះ យើងនឹងធ្វើការបកស្រាយនៅក្នុងចំណុច **២.២.២ ករណីសន្តតិជនជារូបវន្តបុគ្គល** ។

### ២.២.២ ករណីសន្តតិជនជា រូបវន្តបុគ្គល

យោងទៅតាម ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានបញ្ញត្តិអំពីបុគ្គលក្លាយជាម្ចាស់សិទ្ធិ និងមានកាតព្វកិច្ចរួមជាមួយរូបវន្តបុគ្គលដែលមានជីវិតក្រោយពីការកើតផងដែរ។ រូបវន្តបុគ្គល ក្នុងន័យនេះ សំដៅដល់មនុស្សពិតតាមធម្មជាតិដែលផ្ទុយទៅនឹងនីតិបុគ្គល។[17] ជាការពិតណាស់ សន្តតិជនដែលជារូបវន្តបុគ្គលមិនត្រឹមតែមានជីវិតរស់នៅនោះទេ សន្តតិជននោះក៏ត្រូវមានសមត្ថភាពគ្រប់គ្រាន់តាមផ្លូវច្បាប់ និងលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចសន្តតិកម្មផងដែរ។ ពោល គឺមិនមែនជាបុគ្គលដែលច្បាប់បានកំណត់ក្នុងការហាមឃាត់ ការធ្វើសកម្មភាពណាមួយ។[18] មួយវិញទៀត ក្នុងការគ្រប់គ្រង

[16] មាត្រា ៩ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[17] សទ្ទានុក្រម ក្រមរដ្ឋប្បវេណី ទំព័រ ១៩

[18] មាត្រា ១១៤៩ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ចាត់ចែងទៅលើចំណែកមត៌កដែលជាចំណែករបស់ខ្លួនបាន សន្តតិជននោះត្រូវតម្រូវឱ្យមានអាយុយ៉ាងហោច ណាស់១៨ (ដប់ប្រាំបី) ឆ្នាំផងដែរ។

មានករណីខ្លះ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានផ្តល់ឱ្យសិទ្ធិអោយសន្តតិជន ដែលមិនទាន់គ្រប់អាយុ ១៨ ឆ្នាំ (អនីតិជន) ក៏មានសិទ្ធិនៅក្នុងការចាត់ចែងចំណែកមត៌កបានដែរ ដូចជាករណីទទួលបានអត្តាធីនភាពពីតុលាការជាដើម។ ដោយមូលហេតុថា ជនទាំងអស់នោះអាចមានឯករាជ្យលើខ្លួនឯងបានក្នុងការសម្រេចចិត្តក៏ដូចជាធ្វើសកម្មភាពផ្សេងៗ ការទទួលនោះត្រូវធ្វើតាមរយៈការស្នើសុំរបស់សាមីខ្លួន ឬការយល់ឃើញថា មានផលប្រយោជន៍ចំពោះអនីតិជននោះឬអត់។ លក្ខខណ្ឌផ្សេងទៀត ក្នុងការទទួលបានអត្តាធីនភាពដោយពុំចាំបាច់មានការប្រកាសពីតុលាការគឺ អនីតិជនទាំងឡាយណាដែលបានរៀបអាពាហ៍ពិពាហ៍រួច ឬបានរៀបអាពាហ៍ពិពាហ៍ហើយតែលែងលះគ្នាវិញ ក៏អានុភាពនៃការមានអត្តាធីនភាពរបស់អនីតិជននៅតែមានដដែល។[19]

ចំពោះ សន្តតិជនជាជនបរទេសដែលមិនមានសញ្ជាតិខ្មែរ តែត្រូវទទួលបានចំណែកមត៌កតាមរយៈសន្តតិកម្ម ឬតាមអច្ច័យទានជាដីធ្លីនោះ លុះត្រាតែជននោះមានជាអគារសហកម្មសិទ្ធិចាប់ពី ១ ជាន់ឡើងទៅ ទើបអាចទទួលបានចំណែកសន្តតិកម្មនោះ។ ក្នុងករណីប្រសិនបើសន្តតិជន ដែលមានលំដាប់សន្តតិជនមុនទាំងអស់សុទ្ធតែមានសញ្ជាតិខ្មែរនោះ ដីធ្លីដែលជាចំណែកមត៌កត្រូវបម្លែងក្លាយជាទ្រព្យរបស់នីតិបុគ្គល ដើម្បីធ្វើការគ្រប់គ្រងចាត់ចែងចំណែកមត៌កនោះ ដោយសន្តតិជនទាំងអស់ក្នុងនាមជានីតិបុគ្គល។

**តើសន្តតិជនតាមច្បាប់មានប៉ុន្មានប្រភេទ ហើយត្រូវរៀបចំដោយដូចម្តេចខ្លះ?** យើងនឹងអាចយល់បានកាន់តែច្បាស់នៅក្នុងចំណុច **៣. ការកំណត់ពីសន្តតិជនតាមច្បាប់ខាងក្រោមនេះ**។

## ៣. ការកំណត់ពីសន្តតិជនតាមច្បាប់

ការកំណត់ពីសន្តតិជនទៅតាមច្បាប់ មានសារៈសំខាន់ណាស់នៅក្នុងការប្រព្រឹត្តទៅក្នុងការបែងចែកមត៌ក។ ការយល់ដឹងអំពីសន្តតិជន ជាការចាំបាច់ណាស់ក្នុងការពិភាក្សា ព្រោះថាសន្តតិជនជាជនដែលត្រូវបន្តនូវសិទ្ធិ និងករណីយកិច្ចពីមតកជន។ ជាធម្មតា នៅពេលដែលមតកជនណាម្នាក់បានទទួលមរណភាព តែងតែមានជនដែលត្រូវទទួលបន្តនូវទ្រព្យសម្បត្តិដែលមតកជនបានបន្សល់ទុក។ តាមច្បាប់ជនដែលទទួលបន្តនោះត្រូវបានច្បាប់កំណត់ថាជា សន្តតិជន នេះឯង។

ចំពោះការកំណត់អំពីញាតិដែលត្រូវទទួលសន្តតិកម្មបន្តពីមតកជនវិញ មានសារៈសំខាន់ណាស់ក្នុងការពិភាក្សាដោយមូលហេតុថា បុគ្គលខ្លះត្រូវបានថ្លោះសិទ្ធិពីសន្តតិកម្ម រីឯខ្លះទៀតមិនត្រូវបានទទួលស្គាល់

[19] មាត្រា ២១ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ដោយមតកជនជាដើម។ ដើម្បីទទួលបានសិទ្ធិ ជាសន្តតិជនលុះត្រាតែបុគ្គលនោះជាជនដែលមានជីវិតរស់នៅនា ពេលចាប់ផ្តើមសន្តតិកម្មទើបអាចទទួលសន្តតិកម្មនោះបាន។ ក្នុងករណី មតកជនមិនបានបន្សល់ទុកនូវមតកសាសន៍នោះទេ ច្បាប់នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់ថា **តើនរណាខ្លះជាសន្តតិជនដែលមានចែងយ៉ាងច្បាស់លាស់តាមច្បាប់ ។**

## ៣.១ លក្ខខណ្ឌទាក់ទងនឹងញាតិ

ការកំណត់អំពីញាតិក្នុងរបបសន្តតិកម្មមួយ ជាពិសេសនោះចាំបាច់ត្រូវគណនាដោយផ្អែកតាមក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា បានសេចក្តីថាបុគ្គលដែលអាចចាត់ទុកថាជាញាតិរបស់មតកជននិងគ្រប់លក្ខណសម្បត្តិអាចក្លាយជា សន្តតិជនបាននោះ គឺត្រូវមានលក្ខណសម្បត្តិដូចដែលបានធ្វើការបកស្រាយតាមចំណុចសំខាន់ៗ ដូចខាងក្រោមនេះ ៖

### ៣.១.១ លក្ខខណ្ឌពីកំណើត

#### ៣.១.១.១ ការសន្មតបិតុភាព

ទារកដែលបានចាប់កំណើតក្នុងគភ៌ប្រពន្ធ ដែលមានក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ត្រូវសន្មតថា ជាកូនរបស់ប្តី។ កូនដែលបានកើត នៅក្រោយអំឡុងពេល ១៨០ថ្ងៃ គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍ត្រូវបានបង្កើត ឬអំឡុងពេល ៣០០ ថ្ងៃគិតចាប់ពីថ្ងៃបានរំលាយ ឬលុបចោលអាពាហ៍ពិពាហ៍នោះត្រូវបានសន្មតថាមានគភ៌។ ក្នុងន័យនេះ ប្រសិនបើពេលមានចំណងអាពាហ៍ពិពាហ៍តាមច្បាប់នោះត្រូវបានហៅថា ការកំណត់អំពីបិតុភាពតាមការសន្មត ។[20]

ម្យ៉ាងវិញទៀត ការកំណត់បិតុភាពអាចប្រព្រឹត្តឡើងទៅបានតាមវិធីសម្រេចមួយទៀត គឺការកំណត់បិតុភាពតាមការទទួលស្គាល់។ ក្នុងការកំណត់តាមការទទួលស្គាល់បិតុភាពនេះ គឺជាការបង្ហាញឆន្ទៈរបស់ឪពុកទទួលស្គាល់កូន។ ហេតុនេះ ទើបការទទួលស្គាល់ដោយស្ម័គ្រចិត្តអាចអនុវត្តន៍បានចំពោះតែករណីដែលឪពុកចង់ទទួលស្គាល់កូនតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត ក្នុងករណីដែលកូនចង់ទទួលស្គាល់ឪពុកខ្លួនឯងប៉ុន្តែឪពុកមិនព្រមទទួលស្គាល់កូននោះវិញទេ ការប្រព្រឹត្តទៅមិនអាចប្រើប្រាស់តាមវិធីទទួលស្គាល់នេះបានទេ។ **ក្នុងករណីដែលឪពុកនោះជាអនីតិជន ឬជាជនក្រោមអាណាព្យាបាលទូទៅ តើអាចទទួលស្គាល់កូនបានដែរ ឬទេ?** ជាទូទៅ ប្រសិនបើឪពុកជាអនីតិជន ឬជាជនក្រោមអាណាព្យាបាលទូទៅ ឪពុកនោះក៏អាចទទួលស្គាល់កូនបាន ដោយមិនចាំបាច់មានការយល់ព្រមពីអ្នកតំណាងដែលច្បាប់បានកំណត់។ [21] ដោយឡែក

---

[20] មេធាវី ទេព បូផល "បុគ្គភាព និងអំណាចមេបា" (បទបង្ហាញក្នុងសិក្ខាសាលា, ១០ ឧសភា ២០១៥)

[21] មាត្រា៩៩៤ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ចំពោះឪពុកដែលជាជនក្រោមអាណាព្យាបាលទូទៅ គាត់អាចធ្វើការទទួលស្គាល់កូនបាន លុះត្រាតែមានស្មារតីយល់ដឹងយល់ដឹងខុសត្រូវប្រសើរជាងមុន។ ហេតុនេះប្រសិនបើ ឪពុកដែលស្ថិតនៅក្នុងស្ថានភាពដែលមិនដឹងអ្វីសោះ ថែមទាំងមិនមានសមត្ថភាពក្នុងការកំណត់អំពីបិតុភាពនោះ នាំអោយកូននោះមិនមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការក្លាយជាសន្តតិជនលំដាប់ទី ១ ទេ។ ថ្វីត្បិតតែ ការទទួលស្គាល់ផ្តោតទៅលើការបង្ហាញឆន្ទៈរបស់ឪពុកក៏ពិតមែន ប៉ុន្តែឆន្ទៈរបស់កូនក៏ជាចំណុចដែលត្រូវពិចារណាផងដែរ។ ច្បាប់បានកំណត់អំពីស្ថានភាព ដែលត្រូវទទួលស្គាល់ការយល់ព្រម និងស្ថានភាពដែលមានត្រឹមតែការបង្ហាញឆន្ទៈរបស់ឪពុក ដែលការទទួលស្គាល់កូនដោយមិនចាំបាច់មានការយល់ព្រមពីកូន ឬពីអ្នកតំណាងដែលច្បាប់បានកំណត់នោះទេ[22] ក្នុងការធ្វើបែបនេះអនីតិជនមិនអាចបង្ហាញឆន្ទៈយល់ព្រមបានទេ ដោយសារតែទំនាក់ទំនងនេះ ជាទំនាក់ទំនងដែលផ្សារភ្ជាប់នឹងបុគ្គល។ ហេតុនេះហើយទើប អ្នកតំណាងដែលច្បាប់បានកំណត់ក៏មិនអាចសម្រេចចំពោះសាមីខ្លួនបានដែរ។ ម្យ៉ាងវិញទៀត ការទទួលស្គាល់កូនជាអនីតិជនមានផលប្រយោជន៍ណាស់ដល់កូននោះ ទោះបីជាការទទួលស្គាល់នេះត្រឹមតែការបង្ហាញឆន្ទៈទទួលស្គាល់របស់ឪពុកក៏ដោយក៏វាជាការគ្រប់គ្រាន់ដែរ។ តាមរយៈ ការទទួលស្គាល់បិតុភាពចំពោះកូនដែលជា ជននៅក្រោមអាណាព្យាបាលទូទៅវិញ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ពុំបានបញ្ញត្តិអំពីករណីនេះនៅឡើយទេ ហើយក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ក៏ពុំបានបញ្ញត្តិមាត្រាណាមួយអំពីករណីក្នុងការហាមឃាត់ក្នុងការទទួលស្គាល់កូននោះដែរ ប៉ុន្តែជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅត្រូវចាំបាច់មានការយល់ព្រមពីសំណាក់អ្នកអាណាព្យាបាលទូទៅជាមុនសិន។[23]

### ៣.១.១.២ មាតុភាព

មាតុភាព សំដៅលើស្ត្រីដែលបានសំរាលកូន គឺជាម្តាយរបស់កូន។[24] ប្រសិនបើ ក្នុងករណីដែលមានការយកមេជីវិតរបស់ប្តីប្រពន្ធទៅដាក់បញ្ចូលក្នុងស្បូនរបស់ស្ត្រីម្នាក់ ដើម្បីអោយស្ត្រីនោះពរពោះ និងសម្រាលកូនជំនួស **តើក្នុងករណីនេះមាតុភាព និងបិតុភាពត្រូវសម្រេចដោយបែបណា?** ជាគោលការណ៍ ផ្អែកតាមមាត្រា ៩៨៧ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានចែងថា ស្ត្រីដែលបានសម្រាលកូនជាម្តាយរបស់កូន លើកលែងតែមានច្បាប់ពិសេសណាមួយ បានចែងទាក់ទងទៅនឹងការបង្កើតកូនសិប្បនិមិត្ត។[25] ដើម្បីជាដំណោះស្រាយល្អ ដើម្បីបង្កើតអោយមានទំនាក់ទំនងញាតិភាពជាមួយឪពុកបាន ឪពុកអាចធ្វើការទទួលស្គាល់កូនបានដូចមាន

[22] មាត្រា ៩៩៥ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[23] មេធាវី ទេព បូផល "បុត្តភាព និងអំណាចមេបា" (បទបង្ហាញក្នុងសិក្ខាសាលា, ១០ ឧសភា ២០១៥)

[24] មាត្រា៩៨៧ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[25] មេធាវី ទេព បូផល, "បុត្តភាព និងអំណាចមេបា" (បទបង្ហាញក្នុងសិក្ខាសាលា, ១០ ឧសភា ២០១៥)

បញ្ញត្តិនៅក្នុងមាត្រា ៩៩៣ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ឬតាមរយៈស៊ុំកូន។ ចំពោះស្ត្រីដែលផ្តល់មេជីវិតដើម្បីបង្កើតទំនាក់ទំនងញាតិភាពរវាងម្តាយ និងកូនអាចធ្វើឡើងបានតែតាមរយៈស៊ុំកូនប៉ុណ្ណោះ។

**៣.១.១.៣ ការទាមទារអោយទទួលស្គាល់**

ការទាមទារអោយទទួលស្គាល់កូនអាចប្រព្រឹត្តទៅបាន (ក្នុងករណីដែលឪពុកមិនព្រមទទួលស្គាល់កូន) កូនមិនអាចធ្វើការទទួលស្គាល់ឪពុក តាមវិធីទទួលស្គាល់តាមមាត្រា ៩៩៣ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាបានទេ ក្នុងករណីនេះកូនអាចទាមទារឱ្យឪពុកទទួលស្គាល់បាន ដោយកូននោះត្រូវអាចដាក់ពាក្យបណ្តឹងទាមទារសុំអោយទទួលស្គាល់ទៅតុលាការបាន។ ប្រសិនបើកូនបានទទួលមរណភាព បច្ឆាញាតិផ្ទាល់របស់កូននោះអាចដាក់ពាក្យបណ្តឹងទាមទារអោយទទួលស្គាល់ជនួសក្នុងអំឡុងពេល ១ ឆ្នាំដោយគិតចាប់ពីពេលដែលបានដឹងថា បុគ្គលដែលបានដាក់ពាក្យស្នើអោយទទួលស្គាល់នោះថាជា ឪពុក។[26] ចំណែកករណីមួយចំនួនដែលឪពុកបដិសេធក្នុងការទទួលស្គាល់នោះមានដូចជា ក្នុងស្ថានភាពដែលឪពុកមិនអាចបង្ហាញឆន្ទៈទទួលស្គាល់បាន ឪពុកបានទទួលបានមរណភាពជាដើម។ ផ្ទុយទៅវិញ កូនដែលធ្លាប់ត្រូវបានបដិសេធចំពោះការទទួលស្គាល់របស់ឪពុក កូននោះមិនអាចធ្វើពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់បានទេ។ ក្នុងការដាក់បណ្តឹងទាមទារឱ្យទទួលស្គាល់នេះ ត្រូវបានដោះស្រាយតាម ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ហើយត្រូវធ្វើឡើងដោយកូន (ដោយយកឪពុកមកធ្វើជាចុងចម្លើយ)។[27] ក្នុងករណី ដែលឪពុកទទួលមរណភាព កូននៅតែអាចធ្វើពាក្យបណ្តឹងទាមទារអោយទទួលស្គាល់បាន ដោយយកតំណាងអយ្យការធ្វើជាចុងចម្លើយ។ ប្រសិនបើក្នុងពេលដែលឪពុកជាចុងចម្លើយ (ក្នុងករណីបណ្តឹងទាមទារ) បានទទួលមរណភាពនៅពេលដែលតុលាការកំពុងចាត់ការបណ្តឹង តំណាងអយ្យការត្រូវទទួលបន្តនូវនីតិវិធីបណ្តឹងនោះ។ [28] ចំពោះករណី កូនដែលចង់ទាមទារការទទួលស្គាល់បិតុភាពបានទទួលមរណភាពនោះ អ្នកដលមានសិទ្ធិធ្វើបណ្តឹងជំនួសគឺបច្ឆាញាតិផ្ទាល់របស់កូននោះ។[29] ម្យ៉ាងទៀតក្នុងករណី កូនបានទទួលមរណភាព ក្រោយពីបានដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់បច្ឆាញាតិផ្ទាល់របស់កូននោះ អាចទទួលបន្តនូវនីតិវិធីបណ្តឹងនោះក្នុងអំឡុងពេល ១ ឆ្នាំ គិតចាប់ពីថ្ងៃដែលកូនបានទទួលមរណភាព។[30] ក្នុងករណីដែលកូន ឬបច្ឆាញាតិផ្ទាល់

[26] មាត្រា ១០០១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[27] មាត្រា ៣ ចំណុច ង និងមាត្រា ២៦ នៃច្បាប់ស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល

[28] មាត្រា១០០១ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ និងមាត្រា២៦ នៃច្បាប់ស្តីពីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល

[29] មាត្រា ១០០១ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[30] មាត្រា ២៦ កថាខណ្ឌទី ៣ នៃច្បាប់ស្តីពី បណ្តឹងទាក់ទងនឹងឋានៈបុគ្គល

របស់កូនជាអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់របស់កូន ឬបច្ឆាញាតិផ្ទាល់ជាអ្នកដាក់ពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់ជំនួសបាន។ ពិសេសជាងនេះទៅទៀត អនីតិជនក៏អាចធ្វើពាក្យបណ្តឹងទាមទារឱ្យទទួលស្គាល់ដោយខ្លួនឯងបានផងដែរ ឬប្រសិនបើអនីតិជននោះមានសមត្ថភាពខាងឆន្ទៈពេញលេញហើយនោះ។ [31] ដូចគ្នានេះដែរ ជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅក៏អាចធ្វើបណ្តឹងដោយខ្លួនឯងបានដែរ ប្រសិនបើជននៅក្រោមអាណាព្យាបាលទូទៅនោះមានសមត្ថភាពខាងឆន្ទៈពេញលេញ។

## ៣.២ លក្ខខណ្ឌទាក់ទងនឹងសន្តតិជន

សន្តតិកម្មតាមច្បាប់ គឺជាការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនដែលបានទទួលមរណភាព ឬបានបាត់ខ្លួនទៅកាន់សន្តតិជនម្នាក់ ឬច្រើននាក់ទៅតាមបញ្ញត្តិច្បាប់ដែលបានកំណត់។ សន្តតិកម្មតាមបញ្ញត្តិតាមក្រមរដ្ឋប្បវេណី បានធ្វើការចែកចេញជាពីរប្រភេទ គឺសន្តតិជន ដែលជាញាតិលោហិតរបស់មតកជន និងសន្តតិជនជានិច្ចដែលជាសហព័ទ្ធរបស់មតកជន។ រីឯ សន្តតិជនតាមច្បាប់ គេកំណត់អំពីសន្តតិជនដែលមានសិទ្ធិ និងកាតព្វកិច្ចរួមមានលំដាប់ថ្នាក់នៃអាទិភាពរបស់ខ្លួនម្នាក់ៗទៅតាមថ្នាក់ញាតិលោហិតខ្សែផ្ទាល់ក្នុង ៦ ថ្នាក់ និងសាខាញាតិផ្សេងទៀតជាអាទិ៍។ ការកំណត់អំពីសន្តតិជននេះ ពិតជាមានសារៈសំខាន់ណាស់ក្នុងការបែងចែងមត៌ក ទើបសន្តតិជនត្រូវបានបែងចែកយ៉ាងច្បាស់លាស់ទៅតាមលំដាប់ដែលកំណត់នៅក្នុងច្បាប់។ លំដាប់សន្តតិជន គឺជាឋានានុក្រមដែលបុគ្គលមានសិទ្ធិត្រូវមកចូលរួមក្នុងការទទួលបាននូវមត៌ករបស់មតកជន។ យោងតាមក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានកំណត់នូវលំដាប់សន្តតិជនជាបីលំដាប់មានដូចជា៖ បច្ឆាញាតិផ្ទាល់របស់មតកជនជា សន្តតិជនលំដាប់ទី ១ បុព្វញាតិផ្ទាល់របស់មតកជនជា សន្តតិជនលំដាប់ទី ២ និងបងប្អូនបង្កើតរបស់មតកជនជា សន្តតិជនលំដាប់ទី ៣ ដើម្បីអាចងាយស្រួលយល់នោះមានដូចជា លោកតាលោកយាយ ម្តាយឪពុក កូនបុព្វញាតិផ្ទាល់រួមទាំងកូនស្មុំ និងបងប្អូនបង្កើតជាដើម។ យើងអាចសម្គាល់បានថា ជនដែលជាសន្តតិជនក្នុងក្របខណ្ឌសន្តតិជនតាមច្បាប់ជាសាច់ញាតិរបស់មតកជន។

### ក.សន្តតិជនលំដាប់ទី ១

កូនរបស់មតកជន ជាសន្តតិជនលំដាប់ទី ១ ទោះបីជាកូននោះជាកូនបង្កើតក្តីកូនស្មុំក្តី ឬជាកូនឥតខាន់ស្លាក្តីត្រូវតែមានចំណែកស្មើៗគ្នា។[32] ក្នុងចំណុចនេះពាក្យថា កូនរបស់មតកជន មានន័យថា កូនដែលមានចំណងបុគ្គភាពគតិយុត្តដែលត្រូវបានទទួលស្គាល់តាមផ្លូវច្បាប់ ដែលការទទួលស្គាល់រាប់ទាំងកូនក្រៅ

[31] មាត្រា ៨ កថាខណ្ឌទី ១ នៃច្បាប់ស្តីពី បណ្តឹងទាក់ទងនឹងឋានៈបុគ្គល

[32] មាត្រា ១១៥៦ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ចំណងអាពាហ៍ពិពាហ៍ (កូនឥតខាន់ស្លា) ផងដែរ។ កូនទាំងអស់នេះ មានចំណែកត្រូវទទួលមត៌កដូចកូនបង្កើតដែលមានចំណងអាពាហ៍ពិពាហ៍ផងដែរ។[33] ចំពោះកូនបង្កើត ទោះបីជាកូនដែលកើតចេញពីឪពុកម្តាយដែលមានសំបុត្រអាពាហ៍ពិពាហ៍ ឬក៏កូនដែលកើតចេញពីចំណងអាពាហ៍ពិពាហ៍អនីតិសង្វាសក៏ដោយ ក៏ច្បាប់បែងចែកដូចទៅនឹងកូនដែលកើតចេញពីឪពុកម្តាយដែលមានសំបុត្រអាពាហ៍ពិពាហ៍ដែរ។ ជាធម្មតាអាពាហ៍ពិពាហ៍ និងអនីតិសង្វាសពុំមានចំណងគតិយុត្តទេ ប៉ុន្តែច្បាប់បានផ្តល់សិទ្ធិឱ្យកូននោះត្រូវទទួលបានមត៌កដូចគ្នាដែរ ប្រសិនបើកូននោះទទួលស្គាល់ដោយឪពុកតាមរយៈការជូនដំណឹងដល់មន្ត្រីអត្រានុកូលដ្ឋាន ឬតាមរយៈមតកសាសន៍។ ចំពោះកូនសុំក៏អាចក្លាយជាសន្តតិជនបានដែរ យោងតាមមាត្រា ១១៥៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ដែលបានចែងថា កូន គឺជាសន្តតិជនលំដាប់ទី ១ ទោះបីជាកូនរបស់មតកជននោះជាកូនបង្កើតក្តី ឬកូនសុំក្តីក៏បានចំណែកស្មើៗគ្នាដែរ។ ហេតុនេះហើយ ទោះបីជាកូនសុំដែលមិនជាប់សាច់ឈាមនឹងមតកជនក៏ដោយក៏កូនសុំនោះមានសិទ្ធិ និងកាតព្វកិច្ចដូចកូនដែលជាប់លោហិតផងដែរ (មិនថាកូនដែលសុំនោះ ជាកូនសុំដោយការសុំកូនធម្មតា ឬការសុំកូនពេញលេញក៏ដោយ កូននោះនៅតែជាបុគ្គលដែលមានសិទ្ធិធ្វើជាសន្តតិជនបាន)។ **ឧទាហរណ៍៖** តារា ដែលជាមតកជនមានកូនបង្កើតដែលមានឈ្មោះ ធីតា និង សោភា ព្រមទាំងមានកូនសុំម្នាក់ទៀតឈ្មោះ ភីរា ផងដែរ។ ដូចនេះយើងអាចមើលឃើញថា កូនទាំងបីរបស់លោក តារា នឹងក្លាយជាសន្តតិជនលំដាប់ទី ១ ទោះក្នុងកាលៈទេសៈណាក៏ដោយ។

រីឯកូនក្រៅចំណងអាពាហ៍ពិពាហ៍វិញ ទោះបីជាមានទំនាក់ទំនងបិតុភាពបង្កើតក៏ដោយ ប្រសិនបើទំនាក់ទំនងនោះមិនត្រូវបានទទួលស្គាល់តាមច្បាប់ទេ បុត្តភាពតាមផ្លូវច្បាប់ក៏មិនអាចទទួលស្គាល់បានដែរ។ ដូចនេះ កូនដែលមិនត្រូវបានទទួលស្គាល់នោះមិនអាចត្រូវទទួលបានចំណែកមត៌ក និងក្លាយជាសន្តតិជនរបស់ឪពុកបានឡើយ។ ជាទូទៅសំបុត្រកំណើត គឺជាភស្តុតាងមួយដ៏សំខាន់ក្នុងការបញ្ជាក់អំពីទំនាក់ទំនងគតិយុត្តរវាងកូន និងឪពុកម្តាយ។ វាជាកាតព្វកិច្ចចាំបាច់មួយរបស់ឪពុកម្តាយ ក្នុងការសុំចុះសំបុត្រកំណើតកូន ទោះបីជាឪពុកម្តាយនោះបានរៀបអាពាហ៍ពិពាហ៍ ឬមិនបានរៀបអាពាហ៍ពិពាហ៍ក៏ដោយ។ ការចុះអត្រានុកូលដ្ឋាន ជាតួនាទីរបស់មន្ត្រីអត្រានុកូលដ្ឋានដែលមានមេឃុំ ឬចៅសង្កាត់ស្ថិតនៅក្នុងដែនដីឃុំ ឬសង្កាត់បានគ្រប់គ្រងនោះ។

ចំណែកឯ ទារកដែលមានកំណើតនៅក្នុងគភ៌ ច្បាប់ក៏បានយកចិត្តទុកដាក់ផងដែរក្នុងការការពារប្រយោជន៍ចំពោះទារកដែលមិនទាន់បានកើត ព្រោះថាទារកអាចនឹងរស់រានមានជីវិត។ យោងតាមមាត្រា ៩

[33] ប៊ួយ ធីតា, អ៊ុន សក្កដា, ជុំ អឹម "មូលដ្ឋានគ្រឹះនៃសន្តតិកម្ម (ផ្នែកទី១)" (បទបង្ហាញក្នុងសហសាល សាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច )

ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានចែងថាករណីចំពោះទារកក្នុងគភ៌ នៅពេលចាប់ផ្តើមសន្តតិកម្ម ទារកមានកំណើតអាចកើតមករស់រានមានជីវិត គឺទារកអាចនឹងទទួលបានទ្រព្យពីសន្តតិកម្មនោះបាន។

**ខ.សន្តតិជនលំដាប់ទី ២**

សន្តតិជនលំដាប់ទី ២ សំដៅទៅលើបុព្វញាតិផ្ទាល់។ ប្រសិនបើ មតកជនពុំមានបច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនទេ នោះបុព្វញាតិផ្ទាល់របស់មតកជននឹងត្រូវក្លាយជាសន្តតិជន។ [34] ប្រសិនបើបុព្វញាតិផ្ទាល់មានចំនួនច្រើននាក់ បុព្វញាតិនីមួយៗត្រូវទទួលចំណែកស្មើៗគ្នា។ បុព្វញាតិផ្ទាល់របស់មតកជន សំដៅលើជនដែលស្ថិតក្នុងថ្នាក់ញាតិខ្ពស់ជាងខ្លួនមានដូចជាឪពុកម្តាយ ជីដូនជីតា ជីដូនទូតជីតាទូតជាដើម។ មូលហេតុដែល គេបានកំណត់យកបុព្វញាតិផ្ទាល់ (បុគ្គលដែលបានរៀបរាប់ខាងលើនេះ) ជាសន្តតិជនលំដាប់ទី ២ ដោយគេយល់ថា អ្នកទាំងអស់នោះជាជនដែលទទួលបានការគោរពពីមតកជន និងជាអ្នកដែលបានមើលថែទាំ ក៏ដូចជាចិញ្ចឹមបីបាច់ដល់មតកជនដែលជាកូន ឬចៅ។ នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ក៏បានកំណត់ដែលថា បុព្វញាតិផ្ទាល់ ដែលមានលំដាប់ថ្នាក់ជិតជាងគេទៅនឹងមតកជន ជាអ្នកដែលមានអាទិភាពទទួលបានចំណែកមត៌កពីសន្តតិកម្មនោះ។ នោះជាមូលហេតុដែលនាំឲ្យឪពុកម្តាយរបស់មតកជននឹងក្លាយជាសន្តតិជនលំដាប់ទី ២ មុនជីដូនជីតា។ ចំពោះឪពុកម្តាយ ដែលក្លាយជាសន្តតិជននោះនឹងត្រូវទទួលបានទ្រព្យសម្បត្តិស្មើៗគ្នា តែប្រសិនបើមតកជនមានតែម្តាយ ឬឪពុកតែម្ខាងដែលនៅរស់នោះ គាត់នឹងទទួលបានមត៌កតែម្នាក់ឯង។ ម្យ៉ាងទៀតប្រសិនបើ ឪពុកម្តាយរបស់មតកជនបានទទួលមរណភាពមុនមតកជននោះ ជីដូនជីតារបស់មតកជន នឹងត្រូវក្លាយជាសន្តតិជនហើយទទួលសន្តតិកម្មពីមតកជននោះ។ ប្រសិនបើគ្មានជីដូនជីតាទៀតនោះ អ្នកដែលទទួលចុងក្រោយគេគឺ ជីដូនទូតជីតាទូត ប៉ុន្តែករណីចុងក្រោយនេះកម្រនឹងកើតមានឡើងណាស់។ **ហេតុអ្វី បានជាបងប្អូនបង្កើតមិនស្ថិតក្នុងសន្តតិជនលំដាប់ទី ២ បែរជាបុព្វញាតិផ្ទាល់ក្លាយជាសន្តតិជនលំដាប់ទី ២ ទៅវិញ?** បានជាបុព្វញាតិផ្ទាល់ក្លាយជាសន្តតិជនលំដាប់ទី ២ ព្រោះថាបុព្វញាតិផ្ទាល់ គឺជាញាតិខ្សែបណ្តោយ ហើយបងប្អូនបង្កើតជាញាតិខ្សែទទឹង។ ចំពោះ ការរាប់ខ្សែត្រូវចាប់ផ្តើមរាប់ពីមតកជនទៅក្រោមដែលមាន ៣ ថ្នាក់ក្នុងនោះ ដែលមានដូចជាកូន ចៅ និងចៅទួត បន្ទាប់មករាប់ឡើងលើវិញមាន ៣ ថ្នាក់ដូចគ្នារួមមានឪពុកម្តាយ ជីដូនជីតា និងជីដូនជីតាទួត ចុងក្រោយគេរាប់ខ្សែទទឹងដែលមានបងប្អូនបង្កើតនេះឯង។ បន្ថែមពីនេះ បុព្វញាតិផ្ទាល់ គឺជាអ្នកដែលត្រូវគោរពបូជា ហេតុនេះហើយបានជាទុកច្បាប់អាទិភាពទៅលើបុព្វញាតិផ្ទាល់វិញ។ ប្រសិនបើ មតកជនពុំមាន

[34] មាត្រា ១១៥៩ កថាខណ្ឌទី ១ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ទាំងបច្ចាញាតិផ្ទាល់ និងបុព្វញាតិផ្ទាល់នោះមត៌កនឹងត្រូវផ្ទេរទៅអោយសន្តតិជនលំដាប់ទី ៣ ដែលត្រូវជាបងប្អូនបង្កើតរបស់មតកជន។

**គ. សន្តតិជនលំដាប់ទី ៣**

សន្តតិជនលំដាប់ទី ៣ នេះ សំដៅទៅដល់បងប្អូនបង្កើតរបស់មតកជន។ ទោះបីជា បងប្អូនបង្កើតរបស់មតកជនមានចំនួនប៉ុន្មានក៏ដោយក៏ម្នាក់ៗត្រូវទទួលបានចំណែកស្មើៗគ្នាជានិច្ចដែរ។ [35] ប៉ុន្តែ ចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុក ឬម្តាយតែម្ខាងដូចគ្នាទៅនឹងមតកជនអាចទទួលបានតែ ១ ភាគ ២ (មួយភាគពីរ) នៃចំណែកមត៌ករបស់បងប្អូនដែលមានឪពុក និងម្តាយទាំងសងខាងដូចគ្នា។ **ឧទាហរណ៍ថា ៖** លោក ប៊ុរី ជាមតកជនបានទទួលមរណភាពដោយពុំមានបុត្រ ហើយលោកក៏ពុំមានឪពុកម្តាយផងដែរ ដោយឪពុកម្តាយរបស់លោកបានទទួលមរណភាពដូចគ្នា។ ប៉ុន្តែលោក ប៊ុរី មានបងប្អូនបង្កើតចំនួន ២ នាក់គឺ លោក សីហា និងកញ្ញា ទេពី។ ក្នុងនោះដែរ ឪពុករបស់លោក ប៊ុរី នៅពេលនៅរស់បានមានកូនស្រីម្នាក់ទៀត ឈ្មោះ នារី ដែលមានម្តាយខុសគ្នាពីលោក ប៊ុរី ។ ដូចនេះ សន្តតិជនរបស់លោក ប៊ុរី មានដូចជា សីហា ទេពី និងនារី។ ក្នុងការបែងចែកចំណែកវិញ នារី បានទទួលស្មើនឹងពាក់កណ្តាលនៃចំណែកមត៌ករបស់លោក សីហា និង កញ្ញាទេពី ដែលជាបងប្អូនបង្កើតរបស់ឪពុកម្តាយរួមគ្នា។ នោះនាំឱ្យលោកសីហា និងកញ្ញា ទេពី ទទួលបានចំណែកមត៌កម្នាក់ ២ ភាគ ៥ រីឯ នារី ទទួលបាន ១ ភាគ ៥ តែប៉ុណ្ណោះ។

**មូលហេតុអ្វី បានជាបងប្អូនបង្កើតម្តាយ ឬឪពុកតែម្ខាងដូចគ្នា ត្រូវបានចំណែកតែពាក់កណ្តាលនៃចំណែកមត៌ករបស់បងប្អូនដែលមានឪពុក និងម្តាយទាំងសងខាងដូចគ្នា?** ជាធម្មតា ប្រសិនបើកាបែងចែកទ្រព្យសម្បត្តិរវាងបងប្អូនបង្កើតដែលមានឪពុក និងម្តាយទាំងសងខាងដូចគ្នាស្មើទៅនឹងចំណែករបស់ឪពុក ឬម្តាយទាំងសងខាងស្មើគ្នា វាហាក់ដូចជាមិនសមរម្យទោះបីជាបងប្អូនគ្នាបង្កើត ប៉ុន្តែជាប់សាច់ឈាមគ្នាតែម្ខាង ហេតុនេះហើយទើប ច្បាប់កំណត់អោយបងប្អូនបង្កើតឪពុក ឬម្តាយតែម្ខាងដូចគ្នាទទួលបានចំណែកតែពាក់កណ្តាល។ ម្យ៉ាងទៀត ប្រសិនបើច្បាប់មិនកំណត់ចំណែកឱ្យទៅបងប្អូនបង្កើតឪពុក ឬម្តាយតែម្ខាងក៏ដូចជាមិនសមរម្យ ព្រោះថាយ៉ាងហោចណាស់បានកើតជាបងប្អូនបង្កើតហើយ គ្រាន់តែមានឪពុក ឬម្តាយដូចគ្នាតែម្ខាង ហេតុនេះ គួរទទួលបានចំណែកពាក់កណ្តាលដែរ។[36]

បន្ទាប់ពីបានសិក្សាសន្តតិជនទាំង ៣ លំដាប់រួច យើងពុំទាន់បានឃើញលេចឡើងនៅ សហព័ទ្ធ **តើបុគ្គលដែលជាសហព័ទ្ធនោះ មិនមានសិទ្ធិទទួលសន្តតិកម្ម ឬក៏យ៉ាងដូចម្តេច?**

---

[35] មាត្រា ១១៦០ កថាខណ្ឌទី ១ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[36] មាត្រា ១១៦០ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

## ឃ. សន្តតិជនជានិច្ច

ក្រៅពីសន្តតិជនទាំងបីលំដាប់នោះហើយ សហព័ទ្ធក៏ជាសន្តតិជនម្នាក់ដែរ ប៉ុន្តែជាសន្តតិជនជានិច្ច ដោយយោងតាមក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា ១១៦១ បានចែងថា សហព័ទ្ធរបស់មតកជន គឺត្រូវតែក្លាយជាសន្តតិជនជានិច្ច ទោះបីជាមាន ឬគ្មានសន្តតិជនផ្សេងទៀតក៏ដោយ។ មានន័យថា ច្បាប់អនុញ្ញាតអោយសហព័ទ្ធក្លាយជាសន្តតិជន និងត្រូវទទួលបានចំណែកមត៌ករបស់មតកជន។ សហព័ទ្ធបានទទួលសិទ្ធិ ជាសន្តតិជនដោយសារចំណងអាពាហ៍ពិពាហ៍បង្កើតបានជាទំនាក់ទំនងគតិយុត្តជាមួយគ្នា។ ជាគោលការណ៍ សហព័ទ្ធ ដែលក្លាយជាសន្តតិជនត្រូវមានលំដាប់ស្មើគ្នាជាមួយនឹងសន្តតិជនដែលជាញាតិលោហិតនោះ ដោយមិនគិតអំពី ជាបច្ឆាញាតិផ្ទាល់ ឬបុព្វញាតិផ្ទាល់ ឬបងប្អូនបង្កើតរបស់មតកជនឡើយ។ ក្នុងចំណោមលំដាប់ទាំងបីក្នុងរបបសន្តតិកម្ម ទោះបីក្នុងលំដាប់ណាមួយក៏ដោយក៏មានចំណែករបស់សហព័ទ្ធនៅក្នុងនោះដែរ។ ក្នុងករណី ដែលសហព័ទ្ធរបស់មតកជនត្រូវក្លាយជាសន្តតិជន ហើយមានបុគ្គលផ្សេងទៀតក្រៅពីសហព័ទ្ធក្លាយជាសន្តតិជនដែរនោះ សហព័ទ្ធត្រូវមានលំដាប់ស្មើគ្នានឹងបុគ្គលនោះ។ ចំពោះ ការបែងចែកចំណែកមត៌កក្នុងករណីសន្តតិជនជាកូន សហព័ទ្ធត្រូវទទួលបានចំណែកស្មើនឹងកូននីមួយៗ។ រីឯ ក្នុងករណីមតកជនមិនមានកូននោះមត៌កត្រូវផ្ទេរទៅឪពុកម្ដាយ ដោយទ្រព្យសម្បត្តិត្រូវចែកជា បីចំណែកស្មើៗគ្នាដោយមួយចំណែកបានទៅឪពុក មួយចំណែកបានទៅម្ដាយ និងមួយចំណែកទៀតបានទៅសហព័ទ្ធ។ ប្រសិនបើ មានតែម្ដាយ ឬឪពុកនៅរស់នាំអោយទ្រព្យសម្បត្តិនោះចែកជាពីរចំណែកវិញ ម្ដាយ ឬឪពុកដែលនៅរស់នោះពាក់កណ្ដាល និងសហព័ទ្ធបានពាក់កណ្ដាល។ ប្រសិនបើមតកជនពុំមានទាំងឪពុកម្ដាយ ទាំងកូននោះ ទ្រព្យនោះនឹងត្រូវផ្ទេរទៅអោយបងប្អូនបង្កើតដោយចែកជាពីរចំណែក មួយចំណែកជារបស់សហព័ទ្ធ និងមួយចំណែកទៀតត្រូវចែកអោយបងប្អូនបង្កើតស្មើៗគ្នា។

ក្នុងករណី សហព័ទ្ធដែលបានបាត់ខ្លួន មុនពេលដែលមានសន្តតិកម្មបានកើតឡើងដោយពុំមាននរណាម្នាក់ដឹងអំពីការបាត់ខ្លួននោះថាស្លាប់ ឬក៏នៅទីកន្លែងណា[37] ជនដែលមានប្រយោជន៍ពាក់ព័ទ្ធជាមួយជនដែលបានបាត់ខ្លួននោះអាចធ្វើបណ្ដឹងទៅតុលាការខាងលំនៅដ្ឋានរបស់ជនបាត់ខ្លួននោះបាន ដើម្បីធ្វើការសន្មត់អំពីការបាត់ខ្លួន។ សាលក្រម ដែលបានប្រកាសអំពីការបាត់ខ្លួននោះត្រូវបានចាត់ទុកថាជាសំបុត្រមរណភាព។ ប្រសីនបើ ជនបាត់ខ្លួននោះត្រលប់មកវិញនោះ ជនដែលមានប្រយោជន៍ពាក់ព័ន្ធអាចសុំប្ដឹងទៅតុលាការសុំមោឃភាពសាលក្រមអំពីការប្រកាសអំពីការបាត់ខ្លួននោះបាន។ ដូចនេះ ទ្រព្យសម្បត្តិរបស់មតកជនត្រូវផ្ទេរទៅអោយសហព័ទ្ធដែលបានរកឃើញវិញនោះ នៅក្នុងករណីដែលទ្រព្យនោះគង់នៅ។ ក៏ប៉ុន្តែ

[37] អម សុផាណារ៉ាត, នីតិរដ្ឋប្បវេណី (មេរៀនថ្នាក់បរិញ្ញាបត្រឆ្នាំទី២, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច)

ប្រសិនបើ ទ្រព្យនោះបានផ្ទេរទៅឱ្យតតិយជនរួចរាល់ហើយនោះ គឺមិនអាចប្រគល់ទៅអោយសហព័ទ្ធវិញបានទេ ព្រោះថាបុគ្គលនោះមិនមានសិទ្ធិទៀតឡើយ។

**ខ. សន្តតិជនជំនួស**

ដោយឡែក មានករណីផ្សេងទៀតអាចនឹងកើតមានឡើងក្រោយពីបានរកឃើញសន្តតិជនត្រឹមត្រូវតាមច្បាប់រួចហើយ ប្រសិនបើកូនដែលជាសន្តតិជននោះបានទទួលមរណភាពនៅមុនពេល ឬព្រមគ្នានឹងពេលចាប់ផ្តើមសន្តតិកម្ម ឬករណីមួយទៀតបានបាត់បង់សិទ្ធិសន្តតិកម្ម (ដោយមូលហេតុអភ័ព្វបុគ្គលនៃសន្តតិកម្ម ឬដោយការផ្តាច់មត៌ក) កូនរបស់សន្តតិជននោះនឹងក្លាយជាសន្តតិជនជំនួស។[38] នោះបានន័យថាបុគ្គលដែលមានសិទ្ធិក្លាយ ជាសន្តតិជនស្របច្បាប់រួចហើយ ប៉ុន្តែបែរជាបានបាត់បង់ជីវិតដោយប្រការណាមួយវិញនោះ ប្រសិនបើបុគ្គលនោះមានកូនដែលមានជីវិតរស់នៅ កូននោះនឹងត្រូវបន្តជាសន្តតិជនជំនួសបាន។ សន្តតិជនជំនួសនោះនឹងអាចមានសិទ្ធិ និងកាតព្វកិច្ចពេញទីដូចសន្តតិជនដែលបានទទួលមរណភាពនោះដែរ។ ក្នុងករណី បុគ្គលរកឃើញហើយតែមិនមានសិទ្ធិ ជាសន្តតិជន (បុគ្គលនោះបានថ្លោះសិទ្ធិហើយក្លាយជាអភ័ព្វបុគ្គល ឬដោយសារការផ្តាច់ចេញពីមត៌ក) នោះកូនរបស់ជននោះនឹងនៅក្លាយទៅជាសន្តតិជនជំនួសមានន័យថាទោះបីជាសន្តតិជនដែលបានបាត់បង់សិទ្ធិ និងកាតព្វកិច្ចដោយសារថ្លោះសិទ្ធិក៏ដោយ ក៏ច្បាប់នៅតែអនុញ្ញាតឱ្យកូនរបស់ជននោះមានសិទ្ធិបន្តក្លាយជាសន្តតិជនជំនួសបានផងដែរ។ ហេតុនេះ មត៌កត្រូវតែមានអ្នកមកទទួលជំនួសបុគ្គលជាសន្តតិជនដែលបានទទួលមរណភាព ឬជាបុគ្គលដែលជាសន្តតិជនដែលបានទទួលមរណភាព ឬបុគ្គលដែលបានថ្លោះសិទ្ធិជាសន្តតិជន។ ក្នុងការទទួលបន្តនូវសន្តតិកម្មជំនួសមានចែងក្នុងកថាខណ្ឌទី ១ មាត្រា ១១៥៧ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានចែងពីមូលហេតុ អភ័ព្វបុគ្គលនៃសន្តតិកម្ម ឬដោយការផ្តាច់មត៌កពីសន្តតិជននាំអោយកូនរបស់សន្តតិជនក្លាយជាសន្តតិជនជំនួសបន្តទៀត។ ប្រសិនបើ កូន និងចៅរបស់មតកជនបានទទួលមរណភាពទៀតនោះ ចៅទួតនឹងទទួលមត៌កបន្តទៀត (ការទទួលមត៌កបន្តបន្ទាប់គ្នា)។ គេអនុវត្តន៍បែបនេះជាបន្តបន្ទាប់ផងដែរ ប្រសិនបើចៅទួតមានមូលហេតុដូចនេះទៀត។ នៅក្នុងការអនុវត្តន៍សន្តតិកម្មជំនួសបន្តបន្ទាប់បែបនេះ អាចអនុវត្តន៍បានតែសន្តតិជនដែលជាកូនរបស់មតកជន (បច្ឆាញាតិផ្ទាល់របស់មតកជន) តែប៉ុណ្ណោះ។ ប៉ុន្តែ ក្នុងករណីដែលបងប្អូនបង្កើតដែលជាសន្តតិជនលំដាប់ទី ៣ ជាអ្នកទទួលបានមត៌កវិញច្បាប់បានទទួលស្គាល់សន្តតិកម្មជំនួសត្រឹមតែមួយតំណប៉ុណ្ណោះ[39] ពោលគឺ ក្មួយរបស់មតកជនអាចក្លាយជាសន្តតិជនជំនួសបាន។

[38] មាត្រា ១១៥៧ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[39] មាត្រា ១១៦០ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ចំណែកមត៌កនៃសន្តតិជន ត្រូវបានគេអនុវត្តន៍ដូចគ្នាទៅនឹងចំណែកមត៌កដែលបុព្វញាតិផ្ទាល់ទទួលបាន ដោយត្រូវបានបែងចែកចំណែកស្មើៗគ្នា។ លើកលែងតែក្នុងករណីដែលមានបច្ឆាញាតិផ្ទាល់ច្រើននាក់ នោះត្រូវបែងចែកស្មើៗគ្នា រវាងបច្ឆាញាតិទាំងឡាយដែលជាសន្តតិជនជំនួសដោយធៀបទៅនឹងចំណែកមត៌ករបស់បុព្វញាតិរបស់ពួកគេទទួលបាន។ **ឧទាហរណ៍៖** លោក សេរី ដែលជាមតកជន មានកូនចំនួន ៤ នាក់ គឺ ធីតា នារី បុរី និងកុសល។ ក្នុងពេលនោះ លោកកុសលបានទទួលមរណភាព (មុនពេលដែលចាប់ផ្តើមសន្តតិកម្ម) ដោយបន្សល់ទុកកូនចំនួន ចំនួន ២ មានឈ្មោះ កេសា និងខេសា។ ករណីនេះ កូនរបស់លោកសេរីត្រូវទទួលចំណែកស្មើៗគ្នា ដោយម្នាក់ត្រូវទទួលបាន ១ ភាគ ៤។ ចំណែក ទ្រព្យរបស់លោកកុសលវិញត្រូវបានប្រគល់ទៅអោយសន្តតិជនជំនួសគឺកូនរបស់គាត់ដោយទទួលបាន ១ ភាគ ៤ នៃចំណែករបស់លោកកុសល ១ ភាគ ៤ នោះនាំអោយទទួលបាន ១ភាគ៨។

## ៤. ការបាត់បង់សិទ្ធិជាសន្តតិជន

ក្រោយពីបានសិក្សាទៅលើសិទ្ធិជាសន្តតិជនហើយ យើងងាកមកស្វែងយល់លក្ខខណ្ឌដែលនាំឱ្យបាត់បង់សិទ្ធិជាសន្តតិជនវិញម្តង។ បន្ទាប់ពីបានពិនិត្យយ៉ាងច្បាស់លាស់នៅក្នុងក្រមរដ្ឋប្បវេណីរួច បុគ្គលជាសន្តតិជន ដែលមិនមានលក្ខណៈច្បាស់លាស់ ដូចទៅនឹងសន្តតិជននៅក្នុងក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាទេនោះ បុគ្គលនោះនឹងបាត់បង់សិទ្ធិជាសន្តតិជន ដែលអាចហៅបានថា នត្ថិភាព មានន័យថា ភាពគ្មាន ឬភាវៈដែលគ្មាន។[40] ដោយឡែក មានលក្ខខណ្ឌមួយចំនួនអាចអោយអនីតិជនដែលជាសន្តតិជនក្លាយទៅជាជនដែលមិនអាចទទួលសន្តតិកម្មបាន ដូចជា អភ័ព្វបុគ្គល និងបុគ្គលដែលត្រូវបានផ្តាច់ចេញពីមត៌ក (ដោយការសម្រេចរបស់មតកជនកាលនៅរស់រានមានជីវិត)។

### ៤.១ ករណីអភ័ព្វបុគ្គល

អភ័ព្វបុគ្គល ជាជនដែលគ្មានលក្ខណសម្បត្តិក្នុងការទទួលបាននូវសន្តតិកម្ម ដោយសារមានហេតុណាមួយក្នុងចំណោមហេតុដែលបានចែងក្នុងក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។ យោងតាម មាត្រា ១១៥០ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា បានចែងថា សន្តតិជន អាចក្លាយជាជនគ្មានលក្ខណសម្បត្តិក្នុងការទទួលបាននូវសន្តតិកម្ម ដោយមូលហេតុថា[41] ៖

- ទី១ ទទួលទោស ដោយចេតនាបានធ្វើឃាត ឬប៉ុនប៉ងលើមតកជន ឬអ្នកមានលំដាប់សន្តតិកម្មមុន ឬស្មើ ទោះបីជាដោយប្រយោលក្តី ឬដោយផ្ទាល់ក្តី ដែលក្នុងន័យនេះ សន្តតិជនអាចជាបុគ្គលដែលពាក់ព័ន្ធ

---

[40] រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត, នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ,ទំព័រ ៤៤៣

[41] មាត្រា ១១៥០ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

នឹងអំពើព្រហ្មទណ្ឌ ក្រោយពីចោទប្រកាន់ និងសាលក្រមចូលជាស្ថាពរ។ ជាក់ស្តែង បុគ្គលដែលបានទទួលទោស ក្រោយពេលត្រូវបានរកឃើញថាមានចេតនាចង់សម្លាប់មតកជន ឬលើជនដែលមានលំដាប់សន្តតិកម្មខ្ពស់ជាង ឬលំដាប់ស្មើគ្នា ត្រូវចាត់ទុកសន្តតិជននេះជាអភ័ព្វបុគ្គលនៃរបបសន្តតិកម្ម។

• ទី២ បុគ្គលណាដែលបានដឹងអំពីការសម្លាប់របស់មតកជនតែមិនបានរាយការណ៍ ឬមិនបានប្តឹង មានន័យថា បុគ្គលនោះមិនបានធ្វើសកម្មភាពសម្លាប់មតកជនទេ ប៉ុន្តែគាត់បានដឹងអំពីការធ្វើឃាតនោះ ហើយមិនហ៊ានប្តឹង ដោយសារការភ័យខ្លាច ឬដើម្បីផលប្រយោជន៍អ្វីមួយ។ ផ្ទុយទៅវិញច្បាប់ក៏បាន លើកលែងផងដែរ ប្រសិនបើគាត់ ជាជនដែលមានបញ្ហាខ្សោយខាងស្មារតីដែលមិនអាចវិនិច្ឆ័យបានថា តើទង្វើដែលគាត់បានឃើញនោះជាទង្វើត្រឹមត្រូវ ឬក៏ខុស ដោយហេតុថាគាត់ជាសាច់លោហិតខ្សែផ្ទាល់ ឬជាសហព័ទ្ធនឹងគ្នា ព្រោះច្បាប់បានពិចារណាទៅលើមនោសញ្ចេតនាដែលស្ថិតនៅក្នុងស្ថានភាពមួយពិបាកក្នុងការដាក់ពាក្យប្តឹង។

• ទី៣ ក្នុងការដែលគេបានរកឃើញថា បុគ្គលណាមួយបានរារាំងមតកជនក្នុងការលុបចោល ឬបង្ខំការកែប្រែមតកសាសន៍ ដែលវាជាទង្វើមួយហៅថា សន្តតិកម្មដោយការឆបោក ឬគំរាមគំហែង។ ការរារាំងការលុបចោល ឬកែប្រែមតកសាសន៍ដោយមានការឆបោក ឬគំរាមគំហែងនោះត្រូវបានអលទ្ធភាពអនុវត្តន៍ ព្រោះវាជាមតកសាសន៍ ដែលមិនបានកើតចេញពីឆន្ទៈផ្ទាល់របស់មតកជន ទោះបីជាស្ថិតនៅក្នុងការប្រើប្រាស់មធ្យោបាយណាក៏ដោយ ដើម្បីតែផលប្រយោជន៍នោះបុគ្គលនោះនឹងក្លាយជា អភ័ព្វបុគ្គល។

• ទី៤ បុគ្គលដែលបានក្លែងបន្លំ បំផ្លាញចោល ឬក៏លាក់ទុកលិខិតមតកសាសន៍ ស្តីពីសន្តតិម្មរបស់មតកជន ក្នុងគោលបំណងចង់បិទបាំងដើម្បីផលប្រយោជន៍ណាមួយ ឬដើម្បីចង់បានទ្រព្យទាំងមូល ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនដែលមិនចង់អោយមានអ្នកណាដឹងនោះ ជាអំពើមួយដែលធ្វើអោយជននោះបានប្រាស់ចាកសិទ្ធិជាសន្តិជន។

## ៤.២ បុគ្គលត្រូវបានផ្តាច់ពីមត៌ក

ចំពោះបុគ្គលមួយប្រភេទទៀត ដែលមិនត្រូវបានទទួលមត៌កពីមតកជន គឺបុគ្គលដែលត្រូវបានផ្តាច់ពីមត៌ក ដោយសារតែមតកជនដែលជាម្ចាស់ទ្រព្យមានឆន្ទៈមិនប្រគល់ទ្រព្យសម្បត្តិទៅឱ្យសន្តតិជននោះទេ។ នៅមុនពេលទទួលមរណភាព ម្ចាស់ទ្រព្យអាចផ្តាច់មត៌កពីសន្តតិជនបានតាមរយៈផ្លូវតុលាការ ឬតាមការកំណត់នៅក្នុងមតកសាសន៍។[42] នៅក្នុងន័យនេះ មានលក្ខខណ្ឌតម្រូវឱ្យមានការបង្ហាញឆន្ទៈពីមតកជនពេលនៅរស់ និងការត្រួតពិនិត្យភាពត្រឹមត្រូវនៃពាក្យស្នើសុំរបស់មតកជននោះពីតុលាការ។ សកម្មភាពដែលច្បាប់បានចែងនោះមានដូចតទៅ៖

[42] មេធាវី អ៊ីវ ប៉ូលី, (វិភាគទានច្បាប់), ការបែងចែកមត៌ក ១៥ មករា ២០១៨ ទំព័រ ៣

- ទី ១ បុគ្គលដែលបានធ្វើបាបចំពោះមតកជន
- ទី ២ បុគ្គលដែលបានប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ
- ទី ៣ បុគ្គលដែលអាចមើលថែទាំមើលមតកជន ពេលដែលមានជំងឺប៉ុន្តែបែរជាមិនមកថែទាំ
- ទី ៤ បុគ្គលដែលបានទទួលសាលក្រម ឬសាលដីកាផ្តន្ទាទោសឱ្យជាប់ពន្ធនាគារអស់មួយជីវិត
- ទី ៥ បុគ្គលដែលបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរគួរឱ្យកត់សម្គាល់ជាអាទិ៍។

**ក.ការផ្តាច់មត៌កតាមរយៈតុលាការ**

ការផ្តាច់មត៌កពីសន្តតិជនតាមផ្លូវតុលាការនេះ មតកជនដែលមានឆន្ទៈផ្តាច់មត៌កពីសន្តតិជនត្រូវដាក់ពាក្យសុំដីកាសម្រេចផ្តាច់មត៌កទៅតុលាការសមត្ថកិច្ច ដោយភ្ជាប់មកជាមួយហេតុផលដែលអាចទទួលយកបាន។[43] ក្នុងករណីសន្តតិជន ដែលមតកជនបានផ្តាច់សិទ្ធិជាសន្តតិជនហើយនោះបានធ្វើការប្រើអំពើហិង្សា ការជេរប្រមាថទៅលើមតកជន ដែលតាមទំនៀមទំលាប់គេអាចហៅបានថា អំពើរមិលគុណចំពោះអ្នកមានគុណធ្វើអោយប្រាស់ចាកសីលធម៌ដែលនេះគេអាចហៅថា កូនអកត្តញ្ញូ ។ ដូចនេះច្បាប់មិនបានអនុញ្ញាតអោយបុគ្គលរូបនោះទទួលបានអ្វីឡើយសម្រាប់អំពើដែលបានប្រព្រឹត្តមកលើមតកជននោះទេ។ សកម្មភាពក្នុងការចេញសាលដីការ ឬសាលក្រមក្នុងការផ្តន្ទាទោសដោយដកសិទ្ធិក្នុងការទទួលបានមត៌ក ឬអាចអោយជាប់ពន្ធនាគារទៅតាមការវិនិច្ឆ័យរបស់តុលាការ។ ដោយតុលាការត្រូវពិចារណាថា **តើការផ្តាច់មត៌កពីសន្តតិជនរបស់មតកជននេះ មតកជនមានបំណងចង់ផ្តាច់មតកសាសន៍តាមអំពើទាំងនោះ ឬជាកលល្បិចរបស់មតកជនដោយសារមូលហេតុ មិនស្រលាញ់កូនស្មើគ្នា ឬមិនចង់ចែកទៅអោយកូនស៊ុំដែលមិនមែនជាសាច់ឈាមបង្កើត ឬក៏យ៉ាងណា?** នោះហើយជាចំណុចដែលត្រូវពិចារណា ដោយហេតុថាមនុស្សចាស់ស្មារតីឆែវឆាវ មិនមានស្មារតីពិចារណាដោយសារការខឹងមួយពេល។

**ខ. ការផ្តាច់មត៌កតាមរយៈមតកសាសន៍**

ជាគោលការណ៍ ការផ្តាច់មត៌កពីសន្តតិជនតាមរយៈមតកសាសន៍ គឺអាចធ្វើឡើងដោយមិនចាំបាច់ដាក់ពាក្យស្នើសុំទៅតុលាកា រដើម្បីផ្តាច់មត៌កចេញពីសន្តតិជននោះទេ។ ម្ចាស់ទ្រព្យអាចអនុវត្តន៍វិធីម្យ៉ាងទៀតដោយធ្វើការសរសេរតាមរយៈមតកសាសន៍ បានសេចក្តីថាម្ចាស់បណ្តាំបានធ្វើមតកសាសន៍ផ្តាច់មត៌កចេញពីសន្តតិជន ពេលនោះអ្នកប្រតិបត្តិមតកសាសន៍ត្រូវដាក់ពាក្យសុំទៅតុលាការឱ្យផ្តាច់មត៌កពីសន្តតិជននោះ

[43] មាត្រា ១១៥១ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ខណៈពេលដែលមតកសាសន៍នោះបង្កើតអានុភាព។ ប៉ុន្តែមតកជន ពេលនៅរស់ក៏អាចដាក់ពាក្យសុំទៅតុលាការ ឱ្យលុបចោលនូវការផ្តាច់មត៌កពីសន្តតិជនថ្លោះសិទ្ធិនៅពេលណាក៏បាន។[44]

ការផ្តាច់មត៌កពីសន្តតិជនតាមរយៈតុលាការក្តី ឬក៏តាមរយៈមតកសាស៍ក្តី សន្តតិជននោះនឹងត្រូវបានថ្លោះសិទ្ធិនៅក្នុងការទទួលយកចំណែកមត៌ក ទោះបីបុគ្គលនោះជាកូនបង្កើតក្តី ឬក៏ជាសន្តតិជនជានិច្ចរបស់មតកជនក៏ក្តី។ ម្យ៉ាងវិញទៀត ដូចដែលបានរៀបរាប់ខាងលើទាក់ទងទៅនឹងសន្តតិជនជាអភ័ព្វបុគ្គល ប្រសិនបើសន្តតិជនដែលបានកាត់ផ្តាច់ពីសន្តតិកម្មរួចហើយ ក្រោយមកមានអានុភាពក្នុងការធ្វើការកាន់កាប់មត៌កក៏ដោយ ក៏ត្រូវបានចាត់ទុកថាជាសន្តតិជនកាន់កាប់មត៌កដោយទុច្ចរិត (ដោយមានអានុភាពតាំងពីពេលចាប់ផ្តើមសន្តតិកម្មមកម្ល៉េះ)។

[44] មេធាវី អ៊ុំ ប៉ូលី, (វិភាគទានច្បាប់), ការបែងចែកមត៌ក ១៥ មករា ២០១៨ ទំព័រ ៤

# ជំពូកទី ៣
# សិទ្ធិផ្សេងៗរបស់អនីតិជនក្នុងការ ទទួលបានសិទ្ធិសន្តិកម្ម

# ជំពូកទី ៣

# សិទ្ធិផ្សេងៗរបស់អនីតិជនក្នុងការទទួលបានសិទ្ធិសន្តតិកម្ម

សន្តតិកម្ម គឺជារបត់ដែលអាចធ្វើអោយមានការផ្លាស់ប្តូរនូវទំនាក់ទំនងគតិយុត្តរវាងមតកជន និងសន្តតិជនព្រមទាំងឋានៈរបស់ជនទាំងនោះផងដែរ។ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានកំណត់យកនូវ គោលកាណ៍ទទួលបន្តដោយស្វ័យប្រវត្តិក្នុងរបបសន្តតិកម្ម ដែលនាំអោយសន្តតិជនមានសិទ្ធិនៅក្នុងការសម្រេចចិត្តក្នុងការទទួលយក ឬមិនទទួលយកនូវចំណែកមត៌កទៅតាមការគិតពិចារណារបស់ខ្លួន។ ការទទួលយកនូវគោលការណ៍នេះ គឺដើម្បីធានានូវជីវភាពអ្នកជំនាន់ក្រោយដោយផ្តល់អាទិភាពដល់សន្តតិជននៅក្នុងការគិតពិចារណា ក្នុងករណីដែលកាតព្វកិច្ចមានច្រើនជាងសិទ្ធិ និងផលប្រយោជន៍។ មុននឹងឈានទៅដឹង អំពីសិទ្ធិសម្រេចផ្សេងៗរបស់អនីតិជននៅក្នុងសន្តតិកម្ម យើងត្រូវតែស្វែងយល់អំពីសិទ្ធិអនីតិជនដែលទទួលបានអត្តាធីនភាពជាមុនសិន។ មិនត្រឹមតែសិទ្ធិដែលទទួលអត្តាធីនភាពនោះទេ ក្នុងនោះយើងខ្ញុំក៏បានរៀបរាប់អំពីការយល់ព្រម និងការបោះបង់ផងដែរ។ ជាពិសេសនោះ សិទ្ធិនៅក្នុងការបែងចែកមតកសាសន៍ក៏មានរៀបរាប់ក្នុងជំពូកនេះផងដែរ។

## ១. សិទ្ធិអនីតិជនដែលទទួលបានអត្តាធីនភាព

យើងបានដឹងហើយថាក្នុងការធ្វើមតកសាសន៍ គឺអាចប្រព្រឹត្តទៅបានដោយបុគ្គលគ្រប់រូបរួមទាំងនីតិជន និងអនីតិជនដែលទទួលបានអត្តាធីនភាព (រួចផុតពីអាណាព្យាបាល ឬអំណាចមេបាសម្រាប់អនីតិជនទើបអាចធ្វមតកសាសន៍បាន)។ [45] ការធ្វើមតកសាសន៍សម្រាប់អនីតិជនអាចកើតឡើងបាន លុះត្រាតែជនទាំងអស់នោះមានសមត្ថភាពខាងឆន្ទៈ ដែលអាចយល់ដឹងខុសត្រូវ និងមានសភាពជាសះស្បើយពីជំងឺផងដែរ។[46] ដោយសារតែអានុភាពនេះហើយ ទើបអនីតិជននោះអាចធ្វើសកម្មភាពនៅក្នុងការសម្រេចចិត្ត និងមានសិទ្ធិក្នុងការទទួលផលប្រយោជន៍ពីសន្តតិកម្មបានដោយមិនចាំបាច់មានការអនុញ្ញាតពីម្តាយឪពុក (អ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន) នោះទេ។ អនីតិជន ព្រមទាំងអាចធ្វើសកម្មភាពក្នុងកិច្ចសន្យាដោយអាចបង្កើត កែប្រែ ឬរំលត់កាតព្វកិច្ចបាន និងអាចធ្វើនូវសកម្មភាពឯកតោភាគីបានថែមទៀតផង។ អនីតិជនណាក៏ដោយ ដែលមានអាយចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ឡើងទៅដែលអាចធានារ៉ាប់រង ទ្រទ្រង់ជីវភាព និងផ្គត់ផ្គង់តម្រូវការក្នុងជីវភាពដោយខ្លួនឯងបាន និងមិនស្ថិតនៅក្រោមអំណាចមេបា ឬរបបអាណាព្យាបាលអនីតិជននោះទេ។ ជាពិសេស ពួកគេនឹងក្លាយជាបុគ្គលមានលក្ខណសម្បត្តិ

---

[45] មាត្រា១១៦៨ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃ ក្រមរដ្ឋប្បវេណី

[46] មាត្រា១១៧៦ សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃ ក្រមរដ្ឋប្បវេណី

គ្រប់គ្រាន់ ដើម្បីឱ្យតុលាការដែលមានសមត្ថកិច្ចអាចធ្វើការវិនិច្ឆ័យ និងធ្វើការប្រកាសនូវអត្តាធីនភាពឱ្យបុគ្គលទាំងអស់នោះបាន ដោយមិនមានផលប៉ះពាល់ធ្ងន់ធ្ងរដល់បុគ្គលនោះទេ ព្រោះអនីតិជននោះមានសមត្ថភាពគ្រប់គ្រាន់ស្មើនឹងនីតិជនហើយ (អាចធ្វើសកម្មភាពដោយមិនរងនូវការកម្រិតសមត្ថភាពដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា)។ រីឯ អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយវិញ ក៏ដូចគ្នាដែរ គឺនឹងទទួលបាននូវអត្តាធីនភាពធ្វើឱ្យជននោះបានដល់នីតិភាពដែលពោរពេញទៅដោយសិទ្ធិ និងកាតព្វកិច្ចតាមផ្លូវច្បាប់ ដោយមិនមានការកម្រិតសមត្ថភាពខុសពីនីតិជនឡើយ។ អនីតិជន ដែលទទួលអត្តាធីនភាពនោះសំដៅទៅដល់សន្តតិជនតាមលំដាប់មានដូចជា ៖ សន្តតិជនលំដាប់ទី ១ ដែលជាកូន សន្តតិជនលំដាប់ទី ២ ដែលជាឪពុកម្តាយ ឬជីដូនជីតា សន្តតិជនលំដាប់ទី ៣ ជាបងប្អូន សន្តតិជនជានិច្ច ដែលជាសហព័ទ្ធ និងសន្តតិជនជំនួស ដែលពួកគេទាំងអស់នោះមិនទាន់មានអាយុគ្រប់ ១៨ ឆ្នាំជាដើម។ ប្រសិនបើ ពួកគេជាអនីតិជនដែលបានត្រូវទទួលអត្តាធីនភាពដោយប្រការណាមួយដែលបានរៀបរាប់ខាងលើនោះ ពួកគេនឹងត្រូវទទួលបានសិទ្ធិដូចទៅនឹងនីតិជនដែរ។ នៅពេលដែលមានសន្តតិកម្មកើតឡើង ពួកគេអាចទទួលបានទ្រព្យសម្បត្តិដែលមតកជនបានរៀបរាប់នៅក្នុងបណ្តាំ ឬប្រសិនបើមិនមានការបែងចែកដោយបណ្តាំនោះទេ ពួកគេក៏អាចទទួលបានតាមការបែងចែករបស់តុលាការផងដែរ។ មួយវិញទៀត ជនទាំងអស់នោះក៏អាចមានសិទ្ធិក្នុងការចាត់ចែងទ្រព្យសម្បត្តិដែលទទួលបានទៅតាមតម្រូវការរបស់ពួកគេផងដែរ។

សបញ្ជាក់អោយឃើញថា ការទទួលបានអត្តាធីនភាព គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ចំពោះអនីតិជន ដែលមានបំណងចង់មានសមត្ថភាពតាមផ្លូវច្បាប់ក្នុងការធ្វើសកម្មភាពបានដូចនីតិជននៅក្នុងការអនុវត្តន៍សន្តតិកម្មរបស់ខ្លួននោះ។ ចំណុចបន្ទាប់ខាងក្រោម យើងនឹងរៀបរាប់អំពីសិទ្ធិនៅក្នុងការយល់ព្រម ឬបោះបង់សន្តតិកម្មរបស់អនីតិជន (**២.ការយល់ព្រមទទួលស្គាល់ និងការបោះបង់ចំពោះសន្តតិកម្ម)។**

## ២. ការយល់ព្រមទទួលស្គាល់ និងការបោះបង់ចំពោះសន្តតិកម្ម

ការយល់ព្រមទទួលស្គាល់ និងការបោះបង់ចំពោះសន្តតិកម្ម ជាចំណុចសំខាន់មួយដែលទាក់ទងទៅនឹងទ្រព្យអកម្ម។ ការយល់ព្រម និងការបោះបង់សន្តតិកម្មដើរតួរសំខាន់ណាស់ក្នុងការការពារផលប្រយោជន៍របស់សន្តតិជន ដើម្បីកុំឱ្យសន្តតិជននោះ ដោយសារតែទទួលសន្តតិកម្មត្រូវក្ស័យធនដោយមូលហេតុថាមតកជនមានបំណុល ដែលគេហៅថា ទ្រព្យអកម្មច្រើនជាងទ្រព្យសកម្ម។ ការប្រើវិធីនេះ ដើម្បីជៀសវាងនូវការទទួលបន្តនូវបំណុលបន្តពីសន្តតិជន (បំណុលឪពុកម្តាយ កូនជាអ្នកសង)។ នេះជាមូលហេតុ ដែលនាំឱ្យក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា បានកំណត់នូវការជ្រើសរើសយកគោលការណ៍ទទួលបន្តស្វ័យប្រវត្តិនេះព្រោះថាច្បាប់មានគោលបំណងដើម្បីការពារសន្តតិជន។ គោលការណ៍ទទួលបន្តដោយ

ស្វ័យប្រវត្តិនេះ គឺជាគោលការណ៍មួយដែលអាចអោយសន្តតិជនត្រូវទទួលទាំងស្រុងនូវសិទ្ធិ និងករណីយកិច្ចទាំងអស់របស់មតកជន។ ប្រសិនបើ មតកជនបន្សល់ទុកនូវកាតព្វកិច្ចច្រើនពេក សន្តតិជនទទួលបន្តនូវកាតព្វកិច្ចទាំងនោះនឹងអាចខូចប្រយោជន៍ធ្ងន់ធ្ងរដោយសារសន្តតិកម្ម។ មូលហេតុនេះហើយ ដែលនាំឱ្យក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា បង្កើតឱ្យមានរបបបោះបង់នូវសន្តតិកម្ម ឬការយល់ព្រមដោយមានកម្រិត ដើម្បីជៀសវាងនូវស្ថានភាពនេះ។

មួយវិញទៀតនៅក្នុងករណី សន្តតិជនបានទទួលមរណភាពនៅមុនពេលធ្វើការយល់ព្រម ឬបោះបង់ក្នុងអំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ១២៥៨ ក្នុងក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានបកស្រាយខាងលើដោយការគណនាត្រូវបានធ្វើឡើងដោយគិតចាប់ពីពេលដែលសន្តតិជននោះបានដឹងថា សន្តតិកម្មរបស់ខ្លួនបានចាប់ផ្តើម។ **ឧទាហរណ៍៖** មតកជន លោក ភានិត មានសន្តតិជនចំនួនពីរនាក់គឺ លោក សុខ និងលោក សៅ។ បន្ទាប់មក លោក សៅ បានទទួលមរណភាពដោយមិនទាន់បានធ្វើការយល់ព្រម ឬបោះបង់មត៌កនៅឡើយទេ ប៉ុន្តែលោកមានលោក សេរី ជាសន្តតិជនជំនួស។ អំឡុងពេលបានជិតដល់សម្រាប់លោក សេរី ក្នុងការធ្វើការយល់ព្រម ឬក៏បោះបង់សន្តតិកម្មចំពោះមត៌ករបស់លោក សៅ ដែរ ប៉ុន្តែប្រសិនបើលោក សេរី បានបោះបង់នូវសន្តតិកម្មរបស់លោក សៅ នោះលោក សេរី ក៏មិនអាចធ្វើការយល់ព្រម ឬបោះបង់សន្តតិកម្មចំពោះមត៌ករបស់លោក ភានិត បានដែរ។ មានន័យថា លោក សេរី បានបោះបង់ចោលមត៌កទាំងអស់របស់លោក សៅ និងលោក ភានិត រួចហើយ។ លោក សេរី អាចធ្វើការយល់ព្រម ឬបោះបង់ចោលនូវសន្តតិកម្មចំពោះមត៌ករបស់លោក ភានិត នៅក្នុងករណីដែលបានយល់ព្រមនូវសន្តតិកម្មចំពោះមត៌ករបស់លោក សៅ ប៉ុណ្ណោះ។

ម្យ៉ាងវិញទៀត ប្រសិនបើសន្តតិជនជាអនីតិជន ឬជនក្រោមអាណាព្យាបាលទូទៅវិញ អំឡុងពេលនៃការកំណត់ក្នុងមាត្រា ១២៤៨ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ត្រូវគណនាដោយគិតចាប់ពីពេលអ្នកតំណាងដែលច្បាប់បានកំណត់នោះបានដឹងថា សន្តតិកម្មចំពោះជនដែលជាអនីតិជន ឬជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅចាប់ផ្តើមហើយ។ មានន័យថា ដើម្បីឱ្យសន្តតិជនដែលជាអនីតិជន ឬជនស្ថិតក្រោមអាណាព្យាបាលទូទៅធ្វើការបង្ហាញឆន្ទៈថាយល់ព្រម ឬបោះបង់មត៌កបានចាំបាច់ត្រូវមានការធ្វើការសម្រេចចិត្តពីអ្នកដែលមានសិទ្ធិអំណាចមេបា ឬអាណាព្យាបាលជាមុនសិន។

## ២.១ ការយល់ព្រមទាំងស្រុង

ក្នុងចំណុចនេះ ការយល់ព្រមទាំងស្រុងមានសារៈសំខាន់ណាស់សម្រាប់សន្តតិជនក្នុងការបែងចែកសន្តតិកម្ម។ ការយល់ព្រមទាំងស្រុង គឺជាករណីមួយដែលសន្តតិជនបានទទួលយល់ព្រមទាំងស្រុងនូវ

សន្តតិកម្ម ជារួម សន្តតិជនត្រូវទទួលបន្តដោយគ្មានកម្រិតនូវសិទ្ធិ[47] និងកាតព្វកិច្ចរបស់មតកជនដែលតម្រូវឱ្យមានការបង្ហាញឆន្ទៈគ្រប់គ្រាន់ដោយមិនបាច់ដាក់ពាក្យស្នើសុំទៅកាន់តុលាការ ដូចករណីក្នុងយល់ព្រមដោយមានកម្រិត ឬការបោះបង់សន្តតិកម្មនោះទេ។ មួយវិញទៀត ទោះបីជាក្នុងករណីសន្តតិជនបានធ្វើការយល់ព្រមទទួលដោយមានកម្រិត ឬបោះបង់សន្តតិកម្មក៏ដោយ ប្រសិនបើសន្តតិជនបានធ្វើសកម្មភាពណាមួយក្នុងចំណោមសកម្មភាពខាងក្រោមនេះ ត្រូវចាត់ទុកថាបានយល់ព្រមទាំងស្រុង ( ការយល់ព្រមទាំងស្រុងតាមផ្លូវច្បាប់ )[48] ដូចជា៖

- សន្តតិជនបានចាត់ចែងមត៌កទាំងអស់នោះ ឬមួយភាគលើកលែងតែសកម្មភាពថែរក្សា និងត្រឹមជាការគ្រប់គ្រង។
- បើសន្តតិជនមិនបានយល់ព្រមដោយកម្រិត ឬបោះបង់ក្នុងអំឡុងពេល ៣(បី)ខែ គិតចាប់ពីពេលដែលបានដឹងថាសន្តតិកម្មចំពោះខ្លួនបានចាប់ផ្តើម លើកលែងតែមានពាក្យសុំពន្យារទៅកាន់តុលាការ។
- ទោះបីជាសន្តតិជនបានយល់ព្រមដោយកម្រិត ឬបោះបង់ក៏ដោយ តែបើសន្តតិជនបានលាក់មត៌កទាំងអស់ ឬមួយភាគ ឬបានប្រើប្រាស់មត៌កទាំងនោះដើម្បីខ្លួន លើកលែងតែក្រោយពេលជនដែលបានក្លាយជាសន្តតិជន ដោយសារការបោះបង់របស់សន្តតិជនលំដាប់មុនបានយល់ព្រម។

ក្នុងករណី សន្តតិជននៅលំដាប់បន្តបន្ទាប់បានយល់ព្រមនោះ សន្តតិកម្មនេះនឹងត្រូវលើកទៅឱ្យសន្តតិជនលំដាប់បន្ទាប់ពីនោះទៀត ដើម្បីអោយមានសន្ទនាភាព និងសង្គតិភាពតាមផ្លូវច្បាប់។ ហេតុនេះ ប្រសិនបើសន្តតិជនលំដាប់មុនបានធ្វើសកម្មភាពបែបនេះ នោះសន្តតិជនលំដាប់បន្ទាប់អាចធ្វើការទាមទារឱ្យសន្តតិជនលំដាប់មុនប្រគល់មត៌កមកវិញ ឬទាមទារឱ្យសងសំណងនៃការខូចខាតបាន។

### ២.១.១ និតីវិធី

នៅក្នុងនីតិវិធីនៃការយល់ព្រមទាំងស្រុង សន្តតិជនអាចសម្តែងឆន្ទៈរបស់ខ្លួនបាននៅក្នុងការយល់ព្រមទៅលើសន្តតិកម្មបដោយអាចធ្វើការចាត់ចែងលើមត៌កដែលទទួលបានទាំងអស់ ឬមួយភាគនៃចំណែកនោះ។ ដោយសារតែអនីតិជនបានបង្ហាញឆន្ទៈ និងសកម្មភាពជាម្ចាស់កម្មសិទ្ធិនេះហើយ ទើបគេអាចកំណត់បានថា សន្តតិជនបានយល់ព្រមទាំងស្រុងលើសកម្មភាពនេះ ពីព្រោះថាពួកគេបានចាត់ចែងដើម្បីផលប្រយោជន៍ពីមត៌កទាំងអស់នោះ ដែលនេះជាការដែលបានបង្ហាញអោយឃើញថា សន្តតិជនបានចាត់ទុកទ្រព្យនៃសន្តតិកម្មជាទ្រព្យរបស់ខ្លួន និងបានអាស្រ័យផលទៅលើទ្រព្យទាំងអស់នោះ។

---

[47] មាត្រា ១២៥៤ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[48] មេធាវី អ៊ីវ ប៉ូលី ,(វិភាគទានច្បាប់), ការបែងចែកមត៌ក

ក្រៅពីការបង្ហាញឆន្ទៈ ក៏មានករណីមួយទៀតដែលច្បាប់ជាអ្នកកំណត់ថាសន្តតិជននោះទទួលយកទាំងស្រុងតែម្តង។ ទោះបីជា មិនបានបង្ហាញឆន្ទៈក៏ដោយក៏ពេលដែលសន្តតិជនមិនបានបង្ហាញឆន្ទៈយល់ព្រមដោយកម្រិត ឬបោះបង់នូវសន្តតិកម្មនោះក្នុងអំឡុងពេល ៣ (បី) ខែទេ ច្បាប់នឹងបើកសិទ្ធិអោយពួកគេសម្រេចចិត្ត។ ក្នុងករណីនេះ ច្បាប់បានកំណត់ថាជននោះទទួលយកទាំងស្រុង ឬយ៉ាងណាប្រសិនបើអំឡុងពេលនោះគាត់មិនបានសម្រេចចិត្តអ្វីទាំងអស់។

### ២.១.២ អានុភាព

បន្ទាប់ពីបានធ្វើការយល់ព្រមហើយនោះ ការសម្រេចមួយនេះនឹងមានអានុភាពចំពោះសន្តតិជន។ ដូចនេះ ប្រសិនបើសន្តតិជនបានយល់ព្រមទាំងស្រុងហើយមានន័យថា ទោះជាមត៌កនោះមានជាប់បំណុលច្រើនយ៉ាងណាក៏ដោយ ឬរហូតដល់តម្លៃនៃមត៌កនោះទៀតក៏សន្តតិជនត្រូវមានសិទ្ធិ និងកាតព្វកិច្ចសងបំណុលដែលមាននោះដែរ។

## ២.២ ការយល់ព្រមដោយកម្រិត

ការយល់ព្រមដោយមានកម្រិត គឺជាករណីដែលសន្តតិជនយល់ព្រម ដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និងអច្ច័យទានរបស់មតកជនបានត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្ម មានន័យថា សន្តតិជនក្លាយទៅជាកូនបំណុលដោយទទួលនូវសន្តតិកម្មនៃកាតព្វកិច្ចទាំងអស់របស់មតកជន ប៉ុន្តែសន្តតិជនអាចកម្រិតនូវការទទួលខុសត្រូវរបស់ខ្លួនបានត្រឹមកម្រិតនៃមត៌ក[49] លើកលែងតែសន្តតិជននៃសន្តតិកម្មស្ម័គ្រចិត្តសងដោយខ្លួនឯង។ ប៉ុន្តែនៅក្នុងករណីដែលមានសហសន្តតិជន ការយល់ព្រមដោយមានកម្រិតនេះត្រូវធ្វើឡើងរួមគ្នាទាំងអស់។ ទៀតសោត ការយល់ព្រមដោយមានកម្រិតតម្រូវឱ្យមាននីតិវិធីនៃការជម្រះបញ្ជី ការធ្វើបែបនេះ ដើម្បីឱ្យមានសមភាពនៅក្នុងការសងចំពោះម្ចាស់បំណុលរបស់មតកជន ដោយសហសន្តតិជនត្រូវយល់ស្របជាមួយគ្នាចំពោះការសង ដោយហេតុថាប្រសិនបើមានតែសន្តតិជនមួយចំនួនយល់ព្រម ព្រមទាំងបានអះអាងនូវចំណែកមត៌កនោះនឹងធ្វើឱ្យការជម្រះបញ្ជីទៅលើមត៌កទាំងអស់មិនអាចធ្វើទៅរួចទេ។

ខាងក្រោមនេះគឺជា នីតិវិធី និងអានុភាពនៃការយល់ព្រមដោយមានកម្រិត។

### ២.២.១ នីតិវិធី

នៅក្នុងនីតិវិធីនៃការយល់ព្រមដោយមានកម្រិត សន្តតិជនត្រូវធ្វើបញ្ជីសារពើភណ្ឌហើយត្រូវដាក់ពាក្យស្នើសុំអំពីការយល់ព្រមដោយកម្រិតនេះទៅកាន់តុលាការ នៅក្នុងអំឡុងពេល ដែលបានចែងនៅក្នុង

[49] មាត្រា ១២៥៦ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

មាត្រា ១២៤៨ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ពោលគឺ ៣ (បី) ខែ ដោយគិតចាប់ពីថ្ងៃដែលសន្តតិជនបានដឹងអំពីការចាប់ផ្តើមសន្តតិកម្មរបស់ខ្លួនកើតមាន។ ក្នុងករណីមានសហសន្តតិជន គឺតម្រូវឱ្យសហសន្តតិជនទាំងអស់នោះដាក់ពាក្យស្នើសុំទៅកាន់តុលាការ ដើម្បីយល់ព្រមចំពោះការយល់ព្រមដោយមានកម្រិតនោះ។ ទោះបីជា ការធ្វើឡើងនេះផុតអំឡុងពេលសម្រាប់សន្តតិជនណាមួយក៏ដោយក៏គេអាចគិតចាប់ពីពេលដែលសន្តតិជនក្រោយគេបានដឹង អំពីការចាប់ផ្តើមសន្តតិកម្មមកធ្វើជាមូលដ្ឋានដែរ។ ជាគោលការណ៍ នៅពេលដាក់ពាក្យសុំទៅកាន់តុលាការ សន្តតិជនត្រូវដាក់បញ្ជីសារពើភ័ណ្ឌនៃមត៌កដោយអមមកជាមួយមត៌កសកម្ម និងមត៌កអកម្ម (ដែលសន្តិជនទទួលបានបន្តពីមតកជន នៅពេលចាប់ផ្តើមសន្តតិកម្ម) ក្នុងកម្រិតមួយដែលសន្តតិជនអាចដឹង ដោយហេតុថាប្រសិនបើមិនមានការបញ្ជាក់ឱ្យច្បាស់លាស់នោះទេនឹងត្រូវបានចាត់ទុកថាជា ការយល់ព្រមទាំងស្រុងដូចដែលមានចែងនៅក្នុងមាត្រា ១២៥៩ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

### ២.២.២ អានុភាព

បន្ទាប់ពីបានដឹងអំពីនីតិវិធីនៃការយល់ព្រមដោយមានកម្រិតរួចរាល់ហើយ យើងក៏ត្រូវដឹងអំពីអានុភាពនៃការយល់ព្រមដោយកម្រិតផងដែរ។ ដោយមានខ្លឹមសារថា ម្ចាស់បំណុលរបស់មតកជនមិនអាចទាមទារឱ្យសន្តតិជនទទួលខុសត្រូវចំពោះទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជនបានឡើយ។ ទោះបីជាដូច្នេះក៏ដោយ តាមគោលការណ៍មត៌កនោះត្រូវធ្លាក់ទៅសន្តតិជន ប៉ុន្តែជាលក្ខណៈសារធាតុ ទ្រព្យសម្បត្តិដែលជាមត៌កត្រូវធ្វើការជម្រះបញ្ជីផ្សេងៗពីទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់សន្តតិជនជាមុនសិន ហេតុនេះសិទ្ធិលើបំណុលកាតព្វកិច្ចរបស់សន្តតិជន និងមត៌កមិនអាចរលត់ដោយព្យាកុលនោះទេ។

## ៣. ការបោះបង់ចោលសន្តតិកម្ម

សន្តតិជនត្រូវតែចាំបាច់មានការយល់ដឹង និងស្វះស្វែងរកជំនួយផ្នែកច្បាប់អំពីការបោះបង់សន្តតិកម្មនេះមិនថាជានីតិជនក្តី ឬអនីតិជនក្តី ដោយវាជាមូលហេតុមួយអាចរំដោះសន្តតិជនពីកាតព្វកិច្ចមួយចំនួនបាន។

### ៣.១ នីតិវិធី

បន្ទាប់ពីមានឆន្ទៈនៅក្នុងការបោះបង់សន្តតិកម្មហើយ សន្តតិជននោះមិនអាចធ្វើការបោះបង់ដោយផ្ទាល់មាត់បានទេ មានន័យថាសន្តតិជននោះ ត្រូវចាំបាច់ធ្វើការបោះបង់ទៅតាមនីតិវិធីនៃការបោះបង់សន្តតិកម្ម គឺត្រូវដាក់ពាក្យសុំទៅកាន់តុលាការ[50] ក្នុងអំឡុងពេល ៣ (បី)ខែ គិតចាប់ពីពេលដឹងថាសន្តតិកម្មចាប់ផ្តើម

[50] មាត្រា ១២៤៨ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ចំពោះខ្លួនកើតមានឡើង។ លើកលែង តែមានពាក្យសុំពន្យារពេលទៅតុលាការ ហើយតុលាការបានអនុញ្ញាត ដោយយោងតាម ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា មាត្រា ១២៦០។ យោងតាមមាត្រា ១១៨៦ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា បានចែងថា សន្តតិកម្មត្រូវចាប់ផ្តើមនៅលំនៅឋានរបស់មតកជន នាពេលមរណភាព។ នេះជាការបង្ហាញពីករណីមានការចាំបាច់មួយក្នុងការអន្តរាគមន៍របស់តុលាការចំពោះសន្តតិកម្ម ដូចជាការបោះបង់សន្តិកម្មនេះជាដើម។

រីចំណែកឯ ក្នុងករណីសន្តតិជនដែលចង់ការបោះបង់សន្តិកម្មជាអនីតិជន ឬជាជនស្ថិតនៅក្រោមអាណាព្យាបាលវិញនោះ សន្តតិជននោះមិនអាចដាក់ពាក្យសុំទៅតុលាការដោយខ្លួនឯងបានទេ។ លើកលែងតែអនីតិជនទាំងអស់នោះទទួលបានអត្តាធីនភាព [51] និងមានការយល់ព្រមពីសំណាក់អ្នកមានអំណាចមេបាតែប៉ុណ្ណោះ។ បន្ថែមពីនេះទៅទៀត ទោះបីជាអនីតិជននោះទទួលបាននូវការយល់ព្រមពីសំណាក់អ្នកដែលមានអំណាចមេបា ឬអ្នកអាណាព្យាបាលទូទៅក៏ដោយក៏សន្តតិជនជាអនីតិជននោះ មិនមានលក្ខណសម្បត្តិគ្រប់គ្រាន់នៅក្នុងការដាក់ពាក្យសុំមកតុលាការបានដដែល។ ដើម្បីឱ្យសន្តតិជនជាអនីតិជន អាចធ្វើការដាក់ពាក្យសុំបោះបង់សន្តតិកម្មមកតុលាការបាន គឺតម្រូវអោយសន្តតិជនជាអនីតិជននោះ មានអ្នកតំណាងដែលច្បាប់បានកំណត់ ទើបអាចធ្វើការដាក់ពាក្យសុំបាន។[52] ដោយឡែក ក្នុងករណីមានការតែងតាំងអ្នកត្រួតពិនិត្យសម្រាប់អាណាព្យាបាលទូទៅ ឬអាណាព្យាបាលរបស់អនីតិជននោះ អ្នកអាណាព្យាបាលទូទៅ ឬអាណាព្យាបាលរបស់អនីតិជនត្រូវមានការទទួលយល់ព្រមពីអ្នកត្រួតពិនិត្យជាមុនសិន។[53]

## ៣.២ អានុភាព

ការបោះបង់សន្តតិកម្មមានអានុភាពបាន នៅពេលដែលតុលាការបានចេញដីកាសម្រេចអនុញ្ញាតឱ្យបុគ្គលជាសន្តតិជនបោះបង់ចោលសន្តតិកម្មរបស់ខ្លួន។ អានុភាពនៃការបោះបង់សន្តតិកម្ម មាននៅក្នុងមាត្រា ១២៦១ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា បានចែងថា បុគ្គលដែលបានបោះបង់ចោលសន្តតិកម្មត្រូវចាត់ទុកបុគ្គលនោះមិនមែនជាសន្តតិជនតាំងពីដំបូងមកម៉្លេះ។ ក្នុងន័យនេះមានន័យថា ការបោះបង់សន្តតិកម្ម គឺមានភាពប្រតិសកម្ម ដែលការចាត់ទុកសន្តតិជនដែលបានបោះបង់សន្តតិកម្មមិនមែនជា សន្តតិជនតាំងពីដំបូង[54] ដែលនេះបង្ហាញឱ្យឃើញថាតាំងពីដំបូងមកគឺ សន្តតិជននោះមិនអាចទទួលបានផលអ្វីពីមត៌កនោះទេ។ ប៉ុន្តែពេលខ្លះ មានភាពមិនច្បាស់លាស់អំពីពេលវេលាដែលគេចាត់ទុកថា តាំងពីដំបូងនោះថាវាគិតចាប់

[51] មាត្រា ២២ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[52] មាត្រា ១៧ នៃច្បាប់ស្តីពី នីតិវិធីរដ្ឋប្បវេណីមិនមែនជាបណ្តឹង

[53] មាត្រា ១០៩០ និង ១១២៦ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[54] មាត្រា ១២៦១ នៃក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ពីពេលណា។ ក្នុងចំណុចនេះ យើងអាចបកស្រាយបានថា សន្តតិកម្មចាប់ផ្តើមពេលដែលមតកជនបានទទួលមរណភាព។ ដូច្នេះសិទ្ធិ និងកាតព្វកិច្ចរបស់សន្តតិជនគឺ កើតឡើងនៅពេលដែលសន្តតិកម្មចាប់ផ្តើមនេះឯង ដែលជាហេតុនាំឱ្យយើងអាចបកស្រាយបានថា ពេលវេលាតាំងពីដំបូងនេះ គឺគិតចាប់ពីពេលដែលសន្តតិកម្មចាប់ផ្តើម។

ទោះជាយ៉ាងណាក៏ដោយ កាលៈទេសៈនេះអាចនឹងមានការប្រែប្រួលនៅពេលដែលយើងរាប់បញ្ចូលផលប្រយោជន៍ពិសេស។ ផលប្រយោជន៍ពិសេស សំដៅទៅលើប្រទានកម្មនៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬហេតុការណ៍ផ្សេងទៀត ឬដើម្បីមូលធននៃជីវភាពរស់នៅ និងអច្ច័យទាន ដែលបានប្រគល់ទៅឱ្យសន្តតិជន។ ប្រសិនបើមានផលប្រយោជន៍ពិសេស តម្លៃនៃប្រទានកម្ម ឬអច្ច័យទាន ត្រូវរាប់បញ្ចូលទៅក្នុងមត៌កនៅពេលសន្តតិកម្មបានចាប់ផ្តើម។

## ៤. ការកំណត់ចំណែកដែលសន្តតិជនទទួលបាន

ការបែងចែកមត៌កក្នុងប្រទេសកម្ពុជានៅមានកម្រិតនៅឡើយ។ ដោយហេតុថា ប្រជាពលរដ្ឋនៅប្រទេសកម្ពុជាមួយចំនួនធំមិនសូវបានចាប់អារម្មណ៍ និងយល់ច្បាស់អំពីការអនុវត្តន៍សន្តតិកម្មនោះទេ។ ប្រសិនបើ យើងក្រឡេកទៅមើលស្ថានភាពជីវភាពរស់នៅសព្វថ្ងៃ ជាពិសេសនៅតាមបណ្តាខេត្តមួយចំនួនវិញ ការអនុវត្តន៍សន្តតិកម្មស្ទើរតែពុំមានទាល់តែសោះទៅលើការបែងចែកទ្រព្យសម្បត្តិ និងមិនបានគិតគូរអំពីបញ្ហាផ្សេងៗដែលអាចកើតមានដោយសារសន្តតិកម្មឡើយ។ ជួនកាល វាអាចបណ្តាលអោយមានជម្លោះក្នុងគ្រួសារ និងឈានទៅដល់ការបែកបាក់ជាដើម។ ដោយសារតែបញ្ហានេះហើយ ទើបច្បាប់បានតម្រូវអោយមានការបែងចែកសន្តតិកម្មជាពីរ គឺការបែងចែកតាមការស្រុះស្រួលគ្នា និងការបែកចែកតាមផ្លូវតុលាការដើម្បីជៀសវាងនូវបញ្ហាដោយសារ សន្តតិកម្ម។

### ៤.១ ការបែងចែកតាមការស្រុះស្រួលគ្នា

ជាទូទៅ នៅក្នុងការបែងចែងមត៌កមួយ មុននឹងឈានទៅដល់ការបែងចែកតាមរយៈតុលាការ សហសន្តតិជនត្រូវធ្វើការនិយាយផ្សះផ្សាគ្នាជាមុនសិន។ គួរយល់ថា ក្នុងការផ្សះផ្សាគ្នាតាមរយៈស្រុះស្រួលគ្នា មានភាពងាយស្រួលដល់សហសន្តិជន ដូចជា បង្ការកុំអោយមានជម្លោះក្នុងគ្រួសារដែលអាចកើតមានដោយសារទ្រព្យ ដែលទ្រព្យនោះបានធ្វើអោយបងប្អូនមិនស្គាល់គ្នាមើលមុខគ្នាមិនចំ ជួនកាលអាចនឹងឈានដល់ការបែកបាក់គ្រួសារផងដែរ។ ការបែកចែកតាមការស្រុះស្រួលគ្នា អាចប្រព្រឹត្តទៅបានដោយត្រូវការភាគីសំខាន់មួយ។ ភាគីសំខាន់នោះដើរតួរ ជាអ្នកសម្របសម្រួលសម្រាប់ឱ្យភាគីវិវាទប្រាស្រ័យទាក់ទង និងចរចារគ្នាក្នុងការដោះស្រាយបញ្ហាដែលកើតមាន ដើម្បីជារនាំងមិនអោយបងប្អូនសាច់ញាតិឈ្លោះគ្នា ផ្ទុយទៅវិញ

ការធ្វើការស្រុះស្រួលគ្នាក្នុងការសម្រួលចំណែកមត៌កមានភាពងាយស្រួល។ នេះដោយសារតែជា ប្រពៃណីទំនៀមទំលាប់ខ្មែរ ត្រូវចេះស្រលាញ់ និងអត់ឱនអោយគ្នាទៅវិញទៅមកត្រូវចេះដោះស្រាយបញ្ហាដោយសន្តិវិធី គ្រួសារត្រូវចេះស្រលាញ់គ្នា និងសាមគ្គីគ្នា។

ការចាប់ផ្តើមសន្តតិកម្មនេះ ត្រូវបានធ្វើឡើងនៅក្នុងរយៈពេលមួយខែក្រោយពេលដែលមតកជនបានទទួលមរណភាព ដើម្បីទុកពេលវេលាក្នុងការគោរពវិញ្ញាណខណ្ឌរបស់មតកជន។ [55] ប្រសិនបើសហសន្តតិជនធ្វើការបែងចែកមត៌ក នៅក្នុងពេលដែលច្បាប់បានហាមឃាត់នោះ ការបែងចែកពុំមានសុពលភាពឡើយ។ ចំណែកឯ នីតិវិធីនៃការបែងចែកតាមការស្រុះស្រួលគ្នាវិញ គឺមិនត្រូវមានទម្រង់ជាលាយល័ក្ខណអក្សរទេ[56] ប៉ុន្តែក្នុងករណីដែលមានការផ្ទេរសិទ្ធិ គឺតម្រូវអោយមានលិខិតយថាភូតពីសំណាក់សារការី។[57]ការបែងចែកនេះត្រូវធ្វើឡើងតាមដោយច្បាស់លាស់ ពុំមែនចេះតែបែងចែកនោះទេ គឺត្រូវពិនិត្យអោយបានត្រឹមត្រូវនូវស្ថានភាព ទំហំ ប្រភេទ និងលក្ខណៈនៃវត្ថុ ឬសិទ្ធិនៅក្នុងមត៌កទៅនឹងស្ថានភាពជីវភាពរបស់សន្តតិជនម្នាក់ៗ។[58] ក្នុងការធ្វើបែបនេះ ពិតជាមានសមភាពដល់សហសន្តតិជនណាស់ ដែលអាចធ្វើអោយសន្តតិជនម្នាក់ៗស្រលាញ់គ្នាទៅវិញទៅមក ដោយចែកគ្នាដល់សន្តតិជនដែលខ្វះខាតជាងខ្លួនជាដើម។ ប្រសិនបើការបែងចែកដោយស្រុះស្រួលគ្នានៅតែមិនមានលទ្ធផលនោះ គេអាចធ្វើការបែងចែកតាមផ្លូវតុលាការវិញម្តង ដែលមានរៀបរាប់នៅចំណុច **៤.២ ការបែងចែកតាមផ្លូវតុលាការ** ។

**តើមូលហេតុអ្វីទើបត្រូវបែងចែកតាមផ្លូវតុលាការ ប្រសិនបើការបែងចែកស្រុះស្រួលគ្នាមានលក្ខណៈងាយស្រួលជាង?** យើងនឹងអាចស្វែងរកចម្លើយនៅក្នុងចំណុចខាងក្រោមនេះ។

### ៤.២ ការបែងចែកតាមផ្លូវតុលាការ

ប្រជាពលរដ្ឋនៅប្រទេសកម្ពុជាមួយចំនួន មិនមានទម្លាប់នៅក្នុងការបែងចែកទ្រព្យសម្បត្តិតាមផ្លូវតុលាការទេ ពួកគេតែងតែជ្រើសយកការបែងចែកមត៌កតាមការស្រុះស្រួលគ្នាដោយហេតុថា កាធ្វើបែនោះមានលក្ខណៈងាយស្រួល ថែមទាមងចំណេញទាំងពេលវេលា និងថវិកាផងដែរ។ ក៏ប៉ុន្តែវាមានមូលហេតុខ្លះ ដែលការបែងចែកត្រូវធ្វើតាមផ្លូវតុលាការផងដែរ ដោយសារតែការបែងចែកមានភាពមិនស្រុះស្រួលគ្នា និងពិភាក្សាគ្នាមិនបានសម្រេចជាដើម។

[55] មាត្រា ១២៦៦ កថាខណ្ឌទី ១ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[56] មាត្រា ១២៦៦ កថាខណ្ឌទី ២ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[57] មាត្រា ១២៦៦ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[58] មាត្រា ១២៦៧ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ជាទូទៅក្នុងការដោះស្រាយ តុលាការជាអ្នកដើរតួយ៉ាងសំខាន់នៅក្នុងការបែងចែកជំនួសសន្តតិជន ដែលនឹងត្រូវអនុវត្តន៍ នៅពេលដែលសហសន្តតិជនធ្វើការបែងចែកមត៌កដោយមិនស្រុះស្រួលគ្នានោះ។ នៅក្នុងការប្រព្រឹត្តតាមផ្លូវតុលាការនោះ គឺត្រូវចាប់ផ្តើមដោយពាក្យបណ្តឹងពីសន្តតិជនណាម្នាក់ដាក់ពាក្យសុំមកតុលាការ នៅក្នុងការបែងចែកមត៌ក។

**តើការបែងចែកតាមផ្លូវតុលាការ មានលក្ខណៈដូចម្តេចទើបធ្វើអោយសន្តតិជនគ្រប់រូបសុខចិត្ត?**

ជាគោលការណ៍ ក្នុងការធ្វើបែងចែកមត៌កតាមផ្លូវតុលាការនេះ ត្រូវធ្វើឡើងតាមគោលការណ៍យុត្តិធម៌ ដោយស្មើភាពគ្នា មិនមានភាពលំអៀងទៅខាងណាមួយ។ ជាពិសេសនោះ តុលាការត្រូវពិចារណាទៅតាមមតិភាគច្រើន ប៉ុន្តែមតិភាគច្រើនរបស់សហសន្តតិជនក៏ត្រូវពិចារណាដែរ ប្រសិនបើមិនមានភាពសមរម្យនោះទេ តុលាការត្រូវដោះស្រាយតាមនីតិវិធីផ្សេងណាដែលសមរម្យ អាចធ្វើអោយសហសន្តតិជនយល់ព្រមនឹងការបែងចែករបស់តុលាការ។ ការបែងចែកនោះ អាចប្រព្រឹត្តទៅបានដូចទៅនឹងការបែងចែកស្រុះស្រួលគ្នាដែរ ដោយតុលាការត្រូវពិនិត្យទៅតាមប្រភេទស្ថានភាពនៃវត្ថុ និងស្ថានភាពផ្សេងៗ ដូចជា៖ មុខរបរ ស្ថានភាពផ្លូវកាយ ស្ថានភាពផ្លូវចិត្ត និងស្ថានភាពជីវភាពរបស់សន្តតិជនម្នាក់ៗ។ ចំពោះទ្រព្យ ដែលមិនអាចធ្វើការបែងចែកបាន តុលាការអាចលក់បាន រួចយកប្រាក់ដែលបានមកនោះធ្វើជាកម្មវត្ថុនៃការបែងចែកមត៌ក។

គួរកត់សម្គាល់ថា ក្នុងការស្រាវជ្រាវសន្តតិកម្មនេះមានសារៈសំខាន់ណាស់ក្នុងការបែងចែកមត៌ក។ នៅពេលដែលធ្វើការបែងចែកមត៌កសហសន្តតិជនត្រូវធ្វើការស្វែងរក ឬស្រាវជ្រាវឱ្យបានច្បាស់លាស់ថា មតកជនបានទទួលស្គាល់កូនពេលដែលនៅមានជីវិតដែរ ឬទេ។ ជាពិសេសនោះ គឺសហសន្តតិជនមិនត្រូវធ្វើការលាក់បាំងថា គ្មានសន្តតិជនផ្សេងឡើយទោះបីជា សន្តតិជននោះជាបងប្អូនឪពុក ម្តាយទីទៃ ឬធ្វើការហាមឃាត់មិនឱ្យសន្តតិជននោះចូលរួមក្នុងការបែងចែកមត៌ក។ ប្រសិនបើមានករណីនេះកើតឡើង ក្រោយពេលដែលការបែងចែករួចរាល់ នោះការបែងចែកនឹងត្រូវចាត់ទុកជាមោឃៈ។[59]

[59] មាត្រា ១២៧៤ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

# សេចក្តីសន្និដ្ឋាន
# និងអនុសាសន៍

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងតាមរយៈការស្រាវជ្រាវប្រធានបទ សិទ្ធិសន្តតិកម្មរបស់អនីតិជននៅកម្ពុជា ខាងលើមួយរយៈកន្លងមកនេះនាំអោយយើងអាចសន្និដ្ឋានបានថា សន្តតិកម្មនៅប្រទេសកម្ពុជា ត្រូវបានអនុវត្តន៍យ៉ាងខ្ជាប់ខ្ជួនសម្រាប់បុគ្គលគ្រប់រូបមិនថាជននោះជានីតិជនក្តី ឬអនីតិជនក្តី គឺត្រូវមានសិទ្ធិស្មើគ្នា ដែលមានចែងយ៉ាងច្បាស់លាស់នៅក្នុងក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។ ជាពិសេសនោះ គឺសិទ្ធិអនីតិជនដែលជាផ្នែកមួយសំខាន់នៅក្នុងអត្ថបទនេះ ដោយហេតុថា មុននឹងបានក្លាយជានីតិជន បុគ្គលរូបនោះក៏ធ្លាប់ជាអនីតិជនដែរ គឺត្រូវតែមានការកំណត់ពិសេសអំពីសិទ្ធិសម្រាប់ពួកគេទាំងនៅក្នុងសង្គម ទាំងនៅក្នុងគ្រួសារក្នុងគោលបំណងដើម្បីការពារការខាតបង់ប្រយោជន៍ណាមួយ ដោយសារតែពួកគេជា បុគ្គលនៅភាពទន់ខ្សោយទាំងកាយសម្បទា និងបញ្ញាស្មារតី។

នៅពេលដែលមានសន្តតិកម្មកើតឡើង សន្តតិជនដែលពាក់ព័ន្ធត្រូវបានច្បាប់ធ្វើការសម្របសម្រួលដោយមានការផ្តល់នូវសិទ្ធិក្នុងការសម្រេចចិត្តថាទទួលយក ឬក៏បោះបង់ចោលនូវសន្តតិកម្មដែលមានចំពោះខ្លួន ដោយធ្វើតាមនីតិវិធីផ្សេងៗ និងបង្ហាញពីអានុភាពផងដែរ។ ដូចនេះហើយទើបតម្រូវអោយសន្តតិជនពិចារណាអោយបានច្បាស់លាស់មុននឹងជ្រើសរើសថា យល់ព្រមតាមវិធីណាមួយ ជៀសវាងអានុភាពនៃការសម្រេចចិត្តរបស់ខ្លួននោះមានការប៉ះពាល់ទៅដល់ប្រយោជន៍ទៅថ្ងៃអនាគត។ ក្រៅពីការយល់ព្រមរបស់សន្តតិជននោះ ច្បាប់ក៏អនុញ្ញាតអោយសន្តតិជនបានសម្រេចចិត្តក្នុងការបោះបង់ផងដែរ ក្នុងលក្ខខណ្ឌដែលសន្តតិជនមិនចង់បាន ឬមិនពេញចិត្ត។ ការសម្រេចចិត្តនេះមានសារៈសំខាន់ណាស់ក្នុងរបបសន្តតិកម្មចំពោះសន្តតិជន ប្រសិនបើសម្រេចចិត្តមិនបានត្រឹមត្រូវទេនោះ វាអាចធ្វើអោយប៉ះពាល់ដល់ជនដែលមានប្រយោជន៍នៅក្នុងសន្តតិកម្ម ដូចជាសន្តតិជនលំដាប់ក្រោយៗជាដើម។

របបសន្តតិកម្មនៅប្រទេសកម្ពុជា គឺត្រូវមានសន្តតិជនជាអ្នកបន្តនូវសិទ្ធិ និងករណីយកិច្ចពីមតកជន ប៉ុន្តែប្រសិនបើមតកជនកាលពេលនៅមានជីវិតពុំបានតាក់តែងនូវបណ្តាំមត៌ក នោះវាជាបញ្ហាដ៏ស្មុគស្មាញមួយដែលពិបាកក្នុងការដោះស្រាយ។ លុះត្រាតែសហសន្តតិជន មានការស្រុះស្រួលគ្នាក្នុងការបែងចែកចំណែក និងមួយវិញទៀតមានស្មារតីពឹងខាងផ្លូវតុលាការក្នុងការដោះស្រាយ ប្រសិនបើភាគីនោះមិនចុះសម្រុងគ្នា។ ហេតុនេះហើយទើបក្រោយពេលមរណភាពរបស់មតកជនរួចមក នាំអោយមាននីតិវិធីមួយកើតឡើងគឺ ការបែងចែងមត៌កទៅតាមវិធីដែលអាចធ្វើអោយសន្តតិជនគ្រប់រូបពេញចិត្ត និងស្មើភាពគ្នា។

សរុបមកខាងលើនេះគឺជាសិទ្ធិ និងកាតព្វកិច្ចរបស់សន្តតិជននៅក្នុងសន្តតិកម្ម។ ដំណើរការអនុវត្តន៍ចំពោះសន្តតិជន ទាំងអនីតិជន និងទាំងនីតិជន គឺមានលក្ខណៈស្រដៀងគ្នា ដោយខុសគ្នាត្រង់ថាសន្តតិកម្ម

របស់សន្តតិជនដែល ជាអនីតិជនមានអាណាព្យាបាលទូទៅ ឬអាណាព្យាបាលសម្រាប់អនីតិជនជាផ្នែកមួយដ៏សំខាន់ក្នុងការធានាសិទ្ធិស្របច្បាប់ផ្សេងៗ សម្រាប់អនីតិជនដែលត្រូវទទួលបាន នៅពេលក្លាយជាសន្តតិជន។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានធ្វើការស្រាវជ្រាវនៃប្រធានបទ **សិទ្ធិសន្តតិកម្មរបស់អនីតិជន** នេះរួចមក នាងខ្ញុំទាំងពីរបានយល់ឃើញថាការបានកំណត់អោយអនីតិជន ជាសន្តតិជនទៅតាមច្បាប់មានលក្ខណៈចាំបាច់ណាស់ ដែលអាចអោយពួកគេទទួលបាននូវការយល់ដឹង ដោយមិនមានការកេងចំណេញពីមនុស្សចាស់ ឬអ្នកដែលមានអំណាចដោយហេតុ នៅក្នុងសង្គមបច្ចុប្បន្ននៅតាមតំបន់ ឬប្រជាជនដែលមិនបានដឹងអំពីច្បាប់ មិនបានធ្វើការបែងចែងមត៌កដោយធ្វើបណ្តាំអ្វីឡើយ និងតែងតែមានជម្លោះនៅពេលដែលមតកជនបានទទួលមរណភាព។

នៅក្នុងករណីដែលបានរៀបរាប់ខាងលើនេះ សូមអោយមន្រ្តីដែលមានសមត្ថកិច្ចក៏ដូចជាក្រសួងដែលពាក់ព័ន្ធរួមគ្នាធ្វើការផ្សព្វផ្សាយ និងចែកចាយព័ត៌មានអំពីច្បាប់អោយមានភាពទូលំទូលាយ ដល់ប្រជាពលរដ្ឋជិតឆ្ងាយទោះមិនមានប្រព័ន្ធអ៊ីនធឺណេតក្តី ទូរទស្សន៍ក្តី ក៏ត្រូវប្រកាសបិទផ្សាយ ឱ្យពួកគាត់បានដឹង និងប្រតិបត្តិតាម ដោយមិនមានការប្រកែករែកញែក នៅពេលក្រោយការប្រកាសច្បាប់ឱ្យប្រើប្រាស់។ មួយវិញទៀតនាងខ្ញុំសុំអោយមន្រ្តីមានសមត្ថកិច្ចក្នុងក្រសួងយុត្តិធម៌ ត្រូវធ្វើការផ្សព្វផ្សាយអោយបានទូលំទូលាយនូវច្បាប់សំខាន់ៗ ដូចជាក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ក្រមព្រហ្មទណ្ឌ ក៏ដូចជាក្រមនីតិវិធីជាដើម និងច្បាប់ដែលពាក់ព័ន្ធផ្សេងៗ
ដែលទាក់ទងនឹងសន្តតិកម្ម ជាពិសេសអនីតិជនក្នុងការធ្វើសន្តតិកម្ម ដើម្បីធានានូវភាពយុត្តិធម៌ថែមទាំងពន្លឿននូវការដោះស្រាយរឿងក្តីរបស់ប្រជាជនអោយកាន់តែរហ័ស ជាពិសេសអនីតិជនតែម្តង ក្នុងគោលការណ៍មានភាពស្មើគ្នាចំពោះនីតិជន និងអនីតិជននូវចំពោះមុខច្បាប់។

ជាចុងក្រោយ នាងខ្ញុំសូមអោយរាជរដ្ឋាភិបាល ឬក៏ដូចជាមន្រ្តី ដែលមានសមត្ថកិច្ចពាក់ព័ន្ធធ្វើការស្នើសុំទៅរដ្ឋសភាដើម្បីសហការគ្នាបង្កើតច្បាប់ថ្មីៗដែលពាក់ព័ន្ធ និងការពារជាផលប្រយោជន៍ដល់អនីតិជនដោយហេតុថា នៅក្នុងច្បាប់ដែលនាងខ្ញុំបានអានក៏ដូចជាសិក្សាស្រាវជ្រាវមានការទាក់ទងនឹងអនីតិជនមានចំនួនតិចនៅឡើយ ដែលជាមូលហេតុពិបាកសម្រាប់អនីតិជននូវក្នុងការសិក្សាស្វែងយល់ និងតទល់ចំពោះមុខច្បាប់។ ជាពិសេសនោះ ក៏អាចអោយប្រជាពលរដ្ឋដែល ជាអនីតិជនបានយល់ដឹងអោយកាន់តែស៊ីជម្រៅនូវសិទ្ធិដែលខ្លួនត្រូវមាន។

# ឯកសារយោង

# ឯកសារយោង

## វិធានច្បាប់

- ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
- សទ្ទានុក្រម ផ្នែករដ្ឋប្បវេណី
- ច្បាប់ស្តីពី នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង ឆ្នាំ២០១១
- សេចក្តីកំណត់មាត្រានីមួយៗ ក្រមរដ្ឋប្បវេណី  នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩
- ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាជប៉ុន ឆ្នាំ១៨៩៦
- សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ស្តីពី បណ្តឹងទាក់ទងនឹងឋានៈបុគ្គល

## សៀវភៅបោះពុម្ព

- លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត , ញាតិ និងសន្តតិកម្ម, មេរៀនសង្ខេប បោះពុម្ពលើទី៥
- មេធាវី អ៊ុំ ប៉ូលី , ការបែងចែកមត៌ក ( វិភាគទានច្បាប់ )
- មេធាវី អ៊ុំ ប៉ូលី , សន្តតិកម្ម, មេរៀនសង្ខេប ( សម្រាប់សមាជិកគណៈមេធាវី )
- លោកសាស្ត្រាចារ្យ ហេង បូរ៉ា , នីតិកាតព្វកិច្ច និងកិច្ចសន្យា សម្រាប់ថ្នាក់បរិញ្ញាបត្រ ឆ្នាំទី ៣
- លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, នីតិព្រហ្មទណ្ឌ និងគ្រួសារ
- វចនានុក្រមសម្តេចសង្ឃរាជ ជួន ណាត
- ឯកសាររបស់ក្រុមការងារសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច នៃមេរៀនក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ១ របស់ក្រសួងយុត្តិធម៌

## ឯកសារស្រាវជ្រាវ

- គង់ ស៊ីម៉េង និងវ៉ាន់ សម្ភស្ស, ឆ្នាំ២០១៨, សន្តតិកម្មសម្រាប់អនីតិជន សារណាបញ្ចប់ការសិក្សា, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- សំម ឬទ្ធីរដ្ឋា និង កែវ វុទ្ធី , ឆ្នាំ២០១៩, សិទ្ធិអនីតិជនតាមការកំណត់ក្នុងក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា
- គឹម វឌ្ឍនៈ និង សែម ស៊ីនរិន្ទ, ឆ្នាំ ២០១៧, ការយល់ព្រម និងការបោះបង់សន្តតិកម្ម

## ឯកសារធ្វើបទបង្ហាញ

- លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត សិក្ខាសាលា ស្តីពី សន្តតិកម្ម , ០៩ កញ្ញា ឆ្នាំ២០២១

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

- ឧបសម្ព័ន្ធទី ១ ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
- ឧបសម្ព័ន្ធទី ២ សទ្ទានុក្រម ផ្នែករដ្ឋប្បវេណី
- ឧបសម្ព័ន្ធទី ៣ ច្បាប់ស្តីពី នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនជាបណ្តឹង ឆ្នាំ២០១១
- ឧបសម្ព័ន្ធទី ៤ សេចក្តីកំណត់មាត្រានីមួយៗ ក្រមរដ្ឋប្បវេណី  នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩
- ឧបសម្ព័ន្ធទី ៥ ច្បាប់ស្តីពី បណ្តឹងទាក់ទងនឹងឋានៈបុគ្គល

# ឧបសម្ព័ន្ធទី១

# ក្រមរដ្ឋប្បវេណី

# នៃព្រះរាជាណាចក្រកម្ពុជា

# ព្រះរាជក្រម

នស/រកម/១២០៧/០៣០

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា ៩.–** ទារកនៅក្នុងគភ៌

១-ទារកដែលនៅក្នុងគភ៌នាពេលមានអំពើអនីត្យានុកូល បើទារកនេះមានកំណើតនៅពេលក្រោយ អាចទាមទារនូវសំណងនៃការខូចខាតដែលបានកើតឡើងពេលដែលខ្លួននៅក្នុងគភ៌ ដោយអំពើអនីត្យានុកូលនោះបាន ។

២-ទារកដែលនៅក្នុងគភ៌នាពេលដែលចាប់ផ្ដើមសន្តតិកម្ម បើទារកនោះមាន

## កថាភាគទី ១

## អនីតិជន

**មាត្រា ១៧.–** អត្ថន័យនៃអនីតិជន

អនីតិជន សំដៅទៅលើជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។



**មាត្រា ១៨.–** សិទ្ធិលុបចោលសកម្មភាព

សកម្មភាពដែលអនីតិជនបានធ្វើដោយមិនបានទទួលការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចលុបចោលបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះសកម្មភាពដែលទទួលសិទ្ធិ ឬ ឱ្យរួចផុតពីកាតព្វកិច្ច ឬ សកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ។

**មាត្រា ១៩.–** ការចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនអនុញ្ញាតឱ្យចាត់ចែង

អនីតិជនអាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឱ្យចាត់ចែង ដោយកំណត់គោលបំណង ក្នុងទំហំនៃគោលបំណងនេះបាន ។ ម្យ៉ាងទៀត អនីតិជនក៏អាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឱ្យចាត់ចែងដោយមិនបានកំណត់គោលបំណងបានដែរ ។

**មាត្រា ២០.–** អនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម

១-អនីតិជនដែលបានទទួលការអនុញ្ញាតឱ្យប្រកបអាជីវកម្មមួយប្រភេទ ឬ ច្រើនប្រភេទ ពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវមានសមត្ថភាពដូចនីតិជន ចំពោះមុខជំនួញនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើបានដឹងច្បាស់ថា អនីតិជននោះមិនអាចបំពេញកិច្ចការអាជីវកម្មនោះបាន អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនអាចលុបចោល ឬ កម្រិតនូវការអនុញ្ញាតនៃការប្រកបអាជីវកម្មនោះបាន ។

**មាត្រា ២០.–** អនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម

១-អនីតិជនដែលបានទទួលការអនុញ្ញាតឱ្យប្រកបអាជីវកម្មមួយប្រភេទ ឬ ច្រើនប្រភេទ ពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវមានសមត្ថភាពដូចនីតិជន ចំពោះមុខជំនួញនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើបានដឹងច្បាស់ថា អនីតិជននោះមិនអាចបំពេញកិច្ចការអាជីវកម្មនោះបាន អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនអាចលុបចោល ឬ កម្រិតនូវការអនុញ្ញាតនៃការប្រកបអាជីវកម្មនោះបាន ។

**មាត្រា ២១.–** ល័ក្ខខ័ណ្ឌនៃអត្តាធីនភាព

១-ក្នុងករណីដែលអនីតិជនដែលបានដល់អាយុ ១៦ (ដប់ប្រាំមួយ) ឆ្នាំ ទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ តុលាការអាចប្រកាសនូវអត្តាធីនភាពរបស់អ្នកនោះបាន

តាមពាក្យសុំរបស់អនីតិជននោះ ប្រសិនបើតុលាការយល់ឃើញថា អត្តាធីនភាពស្របនឹងផលប្រយោជន៍របស់អនីតិជននោះ ។ ក្នុងករណីនេះ តុលាការត្រូវសួរយោបល់ពីអ្នកមានសិទ្ធិអំណាចមេបា ។

២-អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ត្រូវទទួលអត្តាធីនភាព ដោយមិនចាំបាច់មានការប្រកាសពីតុលាការទេ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ទោះបីភាគីលែងលះគ្នាក៏ដោយ ក៏អានុភាពនៃអត្តាធីនភាព មិនត្រូវរលត់ឡើយ ។

**មាត្រា ២២.–** អានុភាពនៃអត្ថាធីនភាព

អនីតិជនដែលទទួលអត្ថាធីនភាព ត្រូវបានចាត់ទុកថា បានដល់នីតិភាព ។

**មាត្រា ២៣.–** កិច្ចសន្យាការងាររបស់អនីតិជន

១-ទោះបីជាមានបញ្ញត្តិនៃមាត្រា ១០៥៣ (ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង) និង មាត្រា ១០៨០ (ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង) នៃក្រមនេះក៏ដោយ ក៏អ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន មិនអាចធ្វើកិច្ចសន្យាការងារជំនួសអនីតិជនបានដែរ ។

២-កិច្ចសន្យាដែលផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនមានអានុភាពចំពោះសាមីអនីតិជនឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះករណីដែលសាមីអនីតិជនផ្តល់សច្ចានុមតិលើកិច្ចសន្យានោះ ។

៣-ក្នុងករណីដែលយល់ឃើញថា កិច្ចសន្យាការងាររបស់អនីតិជនអាចធ្វើឱ្យខូចផលប្រយោជន៍ដល់អនីតិជននោះ អ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ ស្ថាប័នរដ្ឋបាល អាចរំលាយកិច្ចសន្យានោះ ឆ្ពោះទៅអនាគតបាន ។

**មាត្រា ៤១.–** ល័ក្ខខ័ណ្ឌដើម្បីធ្វើការប្រកាសអំពីការបាត់ខ្លួន

១-ប្រសិនបើពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬ ទទួលមរណភាពក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ តុលាការអាចប្រកាសបានថា បុគ្គលនោះបានបាត់ខ្លួនតាមពាក្យសុំរបស់សហព័ទ្ធ អ្នកដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី អ្នកទទួលប្រាក់ធានារ៉ាប់រង អ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឪពុកម្តាយ ឬ អ្នកផ្សេងទៀតដែលមានផលប្រយោជន៍សំខាន់តាមផ្លូវច្បាប់ក្នុងការប្រកាសអំពីការបាត់ខ្លួន ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះត្រូវយកមកអនុវត្តផងដែរ ចំពោះករណីបុគ្គលដែលចូលទៅតំបន់ដែលមានសង្គ្រាម បុគ្គលដែលមានវត្តមាននៅក្នុងនាវាដែលបានលិច ឬ បុគ្គលដែលបានជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងទៀតដែលអាចនាំឱ្យទទួលមរណភាព ហើយពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬ ទទួលមរណភាពក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក្រោយពីចប់សង្គ្រាម ក្រោយពីនាវាបានលិច ឬ ក្រោយពីគ្រោះថ្នាក់ផ្សេងទៀតនោះ បានកន្លងផុតទៅ ។

## កថាភាគទី ២
## ការសម្រេចអំពីបុត្តភាព

**មាត្រា ៩៨៧.–** មាតុភាព

ស្ត្រីដែលបានសម្រាលកូន គឺជាម្តាយរបស់កូន ។

**មាត្រា ៩៩៤.–** សមត្ថភាពក្នុងការទទួលស្គាល់

ដើម្បីទទួលស្គាល់ ទោះបីជាឪពុកជាអនីតិជន ឬ ជាជននៅក្រោមអាណាព្យាបាលទូទៅក៏ដោយ ក៏ពុំចាំបាច់មានការយល់ព្រម ពីអ្នកតំណាងដែលច្បាប់បានកំណត់ឡើយ ។

**មាត្រា ៩៩៥.–** ការទទួលស្គាល់របស់ឪពុក

១-ឪពុកអាចទទួលស្គាល់កូនដែលជាអនីតិជនបាន ។

២-ទោះជាទារកនៅក្នុងគភ៌ក៏ដោយ ក៏ឪពុកអាចទទួលស្គាល់កូននោះបាន ដោយទទួលការយល់ព្រមពីម្តាយ ។

**មាត្រា ១០០១.–** បណ្ដឹងទាមទារឱ្យទទួលស្គាល់

១-កូន អាចដាក់ពាក្យបណ្ដឹងទាមទារឱ្យទទួលស្គាល់បាន ។ ប៉ុន្តែ កូនដែលមិនបានយល់ព្រម តាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៩៩៦ (ការទទួលស្គាល់កូនជានីតិជន និង កូនដែលបានទទួលមរណភាព) នៃក្រមនេះ ពុំអាចទាមទារឱ្យទទួលស្គាល់បានឡើយ ។

២-ប្រសិនបើកូនបានទទួលមរណភាព បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្ដឹងទាមទារឱ្យទទួលស្គាល់បាន ។

៣-កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្ដឹងទាមទារឱ្យទទួលស្គាល់បាន ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ដោយគិតចាប់ពីពេលដែលបានដឹងថាជាឪពុក ។

៤-ក្នុងករណីដែលកូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ ជាអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ នៅពេលដែលខ្លួនបានដឹងថាជាឪពុក អំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ត្រូវគណនា គិតចាប់ពីពេលដែលកូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ បានក្លាយជានីតិជន ឬ ពេលដែលមានការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ ដែលបានកំណត់នៅក្នុងមាត្រា ២៧ (ការលុបចោលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ) នៃក្រមនេះ ។

៥-កូន ឬ បច្ឆាញាតិផ្ទាល់របស់កូន អាចដាក់ពាក្យបណ្ដឹងទាមទារឱ្យទទួលស្គាល់បាន នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីថ្ងៃមរណភាពរបស់ឪពុក ប្រសិនបើបានដឹងថាជាឪពុក នៅក្រោយមរណភាពរបស់ឪពុក ។

៦-បណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ អ្នកតំណាងដែលច្បាប់បានកំណត់របស់កូន ឬ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចដាក់ពាក្យបណ្ដឹងទាមទារឱ្យទទួលស្គាល់ ជំនួសជនទាំងនោះបាន ។

**មាត្រា ១០៩០.–** ការកម្រិតសិទ្ធិតំណាងដែលច្បាប់បានកំណត់ និង សិទ្ធិយល់ព្រម

ប្រសិនបើមានអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដើម្បីធ្វើអាជីវកម្ម ឬ ធ្វើសកម្មភាពដែលបានកំណត់នៅក្នុងមាត្រា ៣០ (សិទ្ធិលុបចោលសកម្មភាព) នៃក្រមនេះ ជំនួសអនីតិជននៅក្រោមអាណាព្យាបាល ឬ ដើម្បីយល់ព្រមឱ្យអនីតិជននៅក្រោមអាណាព្យាបាល ប្រកបអាជីវកម្ម ឬ ធ្វើសកម្មភាពនោះ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវទទួលការយល់ព្រមពីអ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះការទទួលប្រាក់ដើម ។

## ផ្នែកទី ៣
## ភាពគ្រប់លក្ខណសម្បត្តិជាសន្តតិជន

**មាត្រា ១១៤៩.-** បុគ្គលដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ជាសន្តតិជន ជាអាទិ៍

១-មានតែជនដែលមានជីវិតរស់នៅ នាពេលចាប់ផ្តើមសន្តតិកម្ម ក្រៅពីបុគ្គលដែលបញ្ញត្តចាប់ពីមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) រហូតដល់មាត្រា ១១៥២ (ការផ្តាច់មត៌កពីសន្តតិជន ដោយមតកសាសន៍) ខាងក្រោមនេះទេ ទើបអាចទទួលសន្តតិកម្មបាន ។

២-ទោះមានបញ្ញត្តិដូចកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ បញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រា ៩ (ទារកនៅក្នុងគភ៌) នៃក្រមនេះ ត្រូវយកមកអនុវត្ត ចំពោះទារកដែលនៅក្នុងគភ៌ ។

**មាត្រា ១១៥០.-** អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍

បុគ្គលដែលបានកំណត់ដូចខាងក្រោមនេះ ពុំអាចក្លាយជាសន្តតិជន ឬ ពុំអាចទទួលទ្រព្យសម្បត្តិតាមមតកសាសន៍បានឡើយ :

ក-បុគ្គលដែលបានទទួលទោស ដោយមានចេតនាធ្វើឃាត ឬ ប៉ុនប៉ងធ្វើឃាតលើមតកជន ឬ លើជនដែលមានលំដាប់សន្តតិកម្មមុន ឬ លំដាប់ស្មើគ្នា ទោះដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តី ។

ខ-បុគ្គលដែលដឹងអំពីការសម្លាប់មតកជន តែមិនបានរាយការណ៍ ឬ មិនបានប្តឹង ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបុគ្គលនោះ មិនអាចវិនិច្ឆ័យអំពើល្អ ឬ អាក្រក់បាន ឬ ករណីដែលអ្នកសម្លាប់ជាសហព័ទ្ធ ឬ ញាតិលោហិតខ្សែផ្ទាល់របស់បុគ្គលនោះ ។

គ-បុគ្គលដែលបានរារាំងមតកជនក្នុងការធ្វើ លុបចោល ឬ កែប្រែមតក-សាសន៍ស្តីពីសន្តតិកម្ម ដោយការឆបោក ឬ គម្រាមកំហែង ។

ឃ-បុគ្គលដែលបានឱ្យមតកជនធ្វើ លុបចោល ឬ កែប្រែមតកសាសន៍ស្តីពីសន្តតិកម្ម ដោយការឆបោក ឬ គម្រាមកំហែង ។

ង-បុគ្គលដែលបានក្លែង កែបន្លំ បំផ្លាញចោល ឬ លាក់ទុកនូវលិខិតមតក-សាសន៍ស្តីពីសន្តតិកម្មរបស់មតកជន ។

**មាត្រា ១១៥១.-** ការផ្ដាច់មត៌កពីសន្ដតិជន

១-មតកជន កាលនៅរស់ អាចដាក់ពាក្យសុំទៅតុលាការ ឱ្យផ្ដាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្ដតិជននោះ មិនឱ្យទទួលសន្ដតិកម្មបាន បើជនដែលត្រូវបានសន្មតថាជាសន្ដតិជនដែលមានភាគបម្រុង បានប្រព្រឹត្តនូវសកម្មភាពដែលបានកំណត់ខាងក្រោមនេះ :

ក-បើបានធ្វើបាបចំពោះមតកជន ។

ខ-បើបានប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ ។

គ-បើអាចមកមើលថែទាំមតកជននៅពេលដែលមានជម្ងឺ ប៉ុន្ដែមិនមកថែទាំ ។

ឃ-បើត្រូវបានទទួលសាលក្រម ឬ សាលដីកាផ្ដន្ទាទោសឱ្យជាប់ពន្ធនាគារមួយជីវិត ។

ង-បើបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរគួរឱ្យកត់សំគាល់ ជាអាទិ៍ ។

មតកជន ក៏អាចបង្ហាញឆន្ទៈអំពីការផ្ដាច់មត៌កនេះ តាមមតកសាសន៍បានដែរ ។

២-ជនដែលត្រូវបានសន្មតថាជាសន្ដតិជនដែលបានទទួលការទាមទារផ្ដាច់មត៌កនេះ អាចធ្វើវិវាទអំពីអត្ថិភាព ឬ នត្ថិភាព នៃមូលហេតុនៃការផ្ដាច់មត៌កនេះ នៅក្នុងការសម្រេចសេចក្ដីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ។

## ជំពូកទី ២
## សន្ដតិកម្មតាមច្បាប់

### ផ្នែកទី ១
### សន្ដតិជន

**មាត្រា ១១៥៦.-** សន្ដតិជនដែលមានលំដាប់ទី ១

១-កូនរបស់មតកជន ត្រូវក្លាយជាសន្ដតិជនដែលមានលំដាប់ទី ១ ។

២-កូនរបស់មតកជន ទោះបីជាកូនបង្កើតក្ដី ឬ កូនសុំក្ដី ត្រូវមានចំណែកមត៌កស្មើៗគ្នា ។

**មាត្រា ១១៥៧.–** សន្តតិកម្មជំនួស

១-បើកូនរបស់មតកជន បានទទួលមរណភាព នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ឬ បានបាត់បង់សិទ្ធិសន្តតិកម្ម ដោយត្រូវនឹងល័ក្ខខ័ណ្ឌដែលបានកំណត់ក្នុងបញ្ញត្តិនៃមាត្រា ១១៥០ (អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍) ខាងលើនេះ ឬ ដោយការផ្តាច់មត៌ក កូនរបស់បុគ្គលនោះ ត្រូវក្លាយទៅជាសន្តតិជនជំនួស ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះបុគ្គលដែលមិនមែនជាបច្ឆាញាតិផ្ទាល់របស់មតកជន ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តជាបន្តបន្ទាប់ ចំពោះករណីដែលមានមូលហេតុដូចបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដដែលនេះ ចំពោះអ្នកទទួលសន្តតិកម្មជំនួស ។

**មាត្រា ១១៥៩.–** សន្តតិជនដែលមានលំដាប់ទី ២

១-បើមតកជនពុំមានបច្ឆាញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជនទេ បុព្វញាតិផ្ទាល់របស់មតកជននោះ ត្រូវក្លាយជាសន្តតិជន ។ ប៉ុន្តែ រវាងបុគ្គលដែលមានថ្នាក់ញាតិខុសគ្នា ត្រូវយកបុព្វញាតិដែលនៅជិតជាង ជាមុន ។

២-ប្រសិនបើបុព្វញាតិផ្ទាល់ដែលត្រូវក្លាយជាសន្តតិជន មានចំនួនច្រើននាក់ បុព្វ-ញាតិផ្ទាល់នីមួយៗត្រូវទទួលចំណែកមត៌កស្មើៗគ្នា ។

**មាត្រា ១១៦០.–** សន្តតិជនដែលមានលំដាប់ទី ៣

១-បើមតកជនពុំមានទាំងបច្ឆាញាតិផ្ទាល់ ទាំងបុព្វញាតិផ្ទាល់ ដែលត្រូវក្លាយជាសន្តតិជនទេ បងប្អូនបង្កើតរបស់មតកជននោះ ត្រូវក្លាយជាសន្តតិជន ។

២-បើបងប្អូនបង្កើតមានចំនួនច្រើននាក់ បងប្អូនបង្កើតម្នាក់ៗត្រូវបានចំណែកមត៌កភាគស្មើៗគ្នា ។ ប៉ុន្តែ ចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុក ឬ ម្តាយតែម្ខាងដូចគ្នា ត្រូវមាន ១ ភាគ ២ (មួយភាគពីរ) នៃចំណែកមត៌ករបស់បងប្អូនដែលមានឪពុក និង ម្តាយទាំងសងខាងដូចគ្នា ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ១១៥៧ (សន្តតិកម្មជំនួស) និង បញ្ញត្តិនៃមាត្រា ១១៥៨ (ចំណែកមត៌ក ក្នុងករណីនៃសន្តតិកម្មជំនួស) ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបងប្អូនបង្កើតរបស់មតកជនដែលត្រូវក្លាយជាសន្តតិជន យោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ បានទទួលមរណភាពនៅមុនពេលចាប់ផ្តើមសន្តតិកម្ម ។

## ជំពូកទី ៣
## សន្តតិកម្មតាមមតកសាសន៍

### ផ្នែកទី ១
### សមត្ថភាពក្នុងការធ្វើមតកសាសន៍

**មាត្រា ១១៦៨.-** បុគ្គលដែលអាចធ្វើមតកសាសន៍បាន

១-បុគ្គលដែលជានីតិជន និង អនីតិជនដែលបានអត្តាធីនភាពរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬ អំណាចមេបា អាចធ្វើមតកសាសន៍បាន ។

២-បញ្ញត្តិនៃមាត្រា ២៦ (សិទ្ធិលុបចោលសកម្មភាព) និង មាត្រា ៣០ (សិទ្ធិលុប

**មាត្រា ១១៩១.-** ការលុបចោលដោយការបដិសេធលិខិតមតកសាសន៍ ជាអាទិ៍

បើម្ចាស់បណ្តាំបានបំផ្លាញច្បាប់ដើមនៃមតកសាសន៍ ដោយចេតនា ត្រូវចាត់ទុកថាបានលុបចោលមតកសាសន៍ ចំពោះផ្នែកដែលត្រូវបានបំផ្លាញនោះ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលម្ចាស់បណ្តាំបានបំផ្លាញវត្ថុ ដែលជាកម្មវត្ថុនៃមតកសាសន៍ ដោយចេតនា ។

## ជំពូកទី ៥
## ការយល់ព្រម និង ការបោះបង់សន្តតិកម្ម

### ផ្នែកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១២៤៨.-** អំឡុងពេលនៃការយល់ព្រម ឬ ការបោះបង់

១-សន្តតិជន ត្រូវធ្វើការយល់ព្រម ឬ ការបោះបង់សន្តតិកម្ម ទាំងស្រុង ឬ ដោយកម្រិត នៅក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីពេលដែលបានដឹងថា សន្តតិកម្មចំពោះខ្លួន បានចាប់ផ្តើម ។ ប៉ុន្តែ អំឡុងពេលនេះ អាចពន្យារទៀតបាន តាមពាក្យសុំរបស់សន្តតិជនទៅតុលាការ ។

២-សន្តតិជន អាចធ្វើការស្រាវជ្រាវមត៌កបាន នៅមុនពេលធ្វើការយល់ព្រម ឬ ការបោះបង់ ។

## ផ្នែកទី ២
## ការយល់ព្រម

**មាត្រា ១២៥៤.–** ការយល់ព្រមទាំងស្រុង

បើសន្តតិជនបានយល់ព្រមទាំងស្រុង ត្រូវទទួលបន្តដោយគ្មានកម្រិត នូវសិទ្ធិ និង កាតព្វកិច្ចរបស់មតកជននោះ ។

**មាត្រា ១២៥៦.–** ការយល់ព្រមដោយមានកម្រិត

១-សន្តតិជនអាចយល់ព្រម ដោយបម្រុងទុកនូវសំណងកាតព្វកិច្ច និង អច្ច័យទានរបស់មតកជនបាន ត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្ម តែប៉ុណ្ណោះ ។

២-បើសន្តតិជនមានច្រើននាក់ ការយល់ព្រមដោយកម្រិតនេះ អាចធ្វើបាន លុះត្រាតែសហសន្តតិជននោះបានធ្វើដោយរួមគ្នាទាំងអស់ ។

**មាត្រា ១២៦១.–** អានុភាពនៃការបោះបង់

បុគ្គលដែលបានបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថា បុគ្គលនោះមិនមែនជាសន្តតិជនតាំងពីដំបូងមក ។

## ផ្នែកទី ២
## ការបែងចែកមត៌ក

**មាត្រា ១២៦៦.–** ការពិភាក្សាបែងចែកមត៌ក

១-សហសន្តតិជនអាចចាប់ផ្តើមពិភាក្សាបែងចែកមត៌ក នៅពេលណាក៏បាន បើអំឡុងពេល ១ (មួយ) ខែ បានកន្លងផុត ក្រោយពីការចាប់ផ្តើមសន្តតិកម្ម ។ ប៉ុន្តែ ចំពោះការផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិលើមត៌ក ដោយសារលទ្ធផលនៃការបែងចែកមត៌ក ត្រូវអនុ-លោមតាមបញ្ញត្តិនៃមាត្រា ១២៧៧ (ការហាមឃាត់មិនឱ្យផ្លាស់ប្តូរឈ្មោះម្ចាស់សិទ្ធិ) នៃក្រមនេះ ឬ ចំពោះករណីដែលមតកជនហាមឃាត់ការបែងចែកមត៌កតាមមតកសាសន៍ ការបែងចែកមត៌កពុំអាចធ្វើបានឡើយ នៅក្នុងអំឡុងពេលដែលហាមឃាត់នោះ ។

២-ដើម្បីផ្ទេរសិទ្ធិចំពោះវត្ថុតាមការបែងចែកមត៌ក ការបែងចែកត្រូវធ្វើជាលាយល័ក្ខណ៍អក្សរទៅតាមទម្រង់នីមួយៗ ដែលចាំបាច់នៅក្នុងការផ្ទេរសិទ្ធិនោះ ។

**មាត្រា ១២៦៧.–** មូលដ្ឋាននៃការបែងចែក

១-បើពុំបានកំណត់វិធីបែងចែកនៅក្នុងមតកសាសន៍ទេ ការបែងចែកមត៌កនេះ ត្រូវធ្វើដោយពិចារណាទៅលើប្រភេទ និង លក្ខណៈនៃវត្ថុ ឬ សិទ្ធិដែលមាននៅក្នុងមត៌ក ឬ អាយុ មុខរបរ ស្ថានភាពផ្លូវកាយ និង ផ្លូវចិត្ត ស្ថានភាពជីវភាព របស់សហសន្តតិជននីមួយៗ និង ស្ថានភាពផ្សេងទៀត ។

២-ក្នុងករណីដែលការបែងចែកបណ្ដាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់តម្លៃ បើយល់ឃើញថាសមរម្យ សហសន្តតិជនអាចឱ្យសហសន្តតិជនណាម្នាក់ ធ្វើលទ្ធកម្មទ្រព្យសម្បត្តិនោះបាន ដោយដាក់ល័ក្ខខ័ណ្ឌឱ្យបង់ប្រាក់សម្រួល ចំពោះសហសន្តតិជនផ្សេងទៀត តាមការពិភាក្សា ។

**មាត្រា ១២៧៤.–** ការទាមទាររបស់ជនដែលត្រូវបានទទួលស្គាល់ក្រោយការបែងចែកមត៌ក

ក្នុងករណីដែលជនដែលបានក្លាយជាសន្តតិជន ដោយសារជននោះត្រូវបានទទួលស្គាល់ ក្រោយពេលមតកជនបានទទួលមរណភាព មានបំណងទាមទារឱ្យបែងចែកមត៌ក

បើសហសន្តតិជនផ្សេងទៀតបានបែងចែកមត៌ក ឬ បានធ្វើការចាត់ចែងផ្សេងទៀតចំពោះមត៌ក ជននោះមានសិទ្ធិទាមទារឱ្យសងដោយតម្លៃតែប៉ុណ្ណោះ ។

# ឧបសម្ព័ន្ធទី ២

# សន្ទានុក្រម ផ្នែករដ្ឋប្បវេណី

១៨៤. **អត្រានុកូលដ្ឋាន**
Eng. **c**ivil status
Fr. **é**tat-civil

ចំណងរួមភ្ជាប់សញ្ជាតិទៅនឹងរដ្ឋ និងឋានៈនៅក្នុងគ្រួសារ ហើយដែលបង្កើតឱ្យមានសិទ្ធិ និង ករណីយកិច្ច ។

ឧ. លិខិតអត្រានុកូលដ្ឋានរួមមាន សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ សំបុត្រមរណភាព ។

១៨៥. **អធិកលាភ**
Eng. **a**dded value
Fr. **l**a plus-value

តម្លៃលើសនៃទ្រព្យណាមួយពីតម្លៃមុន។

១៨៦. **អធិការ**
Eng. **i**nspector
Fr. **i**nspecteur

តាមក្រមរដ្ឋប្បវេណី មានន័យថា បុគ្គលដែលតុលាការជ្រើសតាំង តាមការទាមទាររបស់អភិបាល ដើម្បីធ្វើការស្រាវជ្រាវអំពីទ្រព្យសម្បត្តិ ដែលជាវិភាគទានក្រៅពីប្រាក់ ឬទ្រព្យសម្បត្តិ ដែលបុគ្គលណាម្នាក់ បានសន្យានៅក្នុងលក្ខន្តិកៈនៃការបង្កើតនីតិបុគ្គល ថានឹងធ្វើអនុប្បទានទៅឱ្យនីតិបុគ្គលនោះ ក្រោយពីការបង្កើតនីតិបុគ្គល ។

១៨៧. **អនីតិជន**
Eng. **m**inor
Fr. **m**ineur

ជន ដែលមិនទាន់គ្រប់អាយុតាមច្បាប់កំណត់ ឬ ជនដែលមានអាយុក្រោម ១៨ឆ្នាំ ។

១៨៨. **អនុតំណាង**
Eng. **s**econdary representative
Fr. **s**ous-représentant

អ្នកដែលជ្រើសតាំងឡើង ដោយអ្នកតំណាង ហើយដែលមានសិទ្ធិ និងករណីយកិច្ចចំពោះម្ចាស់សិទ្ធិ ដូចអ្នកតំណាងដែរ ។

១៨៩. **អនុប្បទាន**
Eng. **t**ransfer / **a**ssignment
Fr. **c**ession

ការផ្ទេរសិទ្ធិ ឬទ្រព្យសម្បត្តិរបស់បុគ្គលណាម្នាក់ ដែលជាអនុប្បទាយីទៅឱ្យបុគ្គលម្នាក់ទៀតដែលជាអនុប្បទានិក ។

ឧ. អនុប្បទានភាគហ៊ុន ( ការលក់ភាគហ៊ុន) ។

១៩០. **អភ័ព្វបុគ្គល**
Eng. **p**erson disqualified for succession
Fr. **i**ndigne

បុគ្គលដែលពុំអាចក្លាយជាសន្តតិជន ឬពុំអាចទទួលទ្រព្យសម្បត្តិតាមមតកសាសន៍បាន ។

១៩១. **អភិបាល**
Eng. **m**anager / **m**anagement
Fr. **g**érant / **g**estion

១-អ្នកគ្រប់គ្រង ការគ្រប់គ្រង ។

២-តាមក្រមរដ្ឋប្បវេណី មានន័យថា អង្គភាពមួយដើម្បីអនុវត្តកិច្ចការរបស់នីតិបុគ្គល ។

១៩២. **អយ្យការ**
Eng. **p**ublic prosecution / prosecution departement
Fr. **p**arquet / ministère public

ស្ថាប័ន ដែលមានសិទ្ធិធ្វើបណ្ដឹងអាជ្ញា និងការពារផលប្រយោជន៍សាធារណៈ ។

# ស

១៣៩. **សកម្មភាព**
Eng. act
Fr. acte

តាមក្រមរដ្ឋប្បវេណីមានន័យថា ការបង្ហាញឆន្ទៈ តាមរយៈកិច្ចសន្យា ឬជាឯកតោភាគី ។

១៤០. **សកម្មភាពសុពល**
Eng. valid act
Fr. acte valuable

សកម្មភាព ដែលធ្វើឡើងស្របតាមលក្ខខណ្ឌតម្រូវ ដោយច្បាប់ និងមានអានុភាពតាមផ្លូវច្បាប់ ។

១៤១. **សកម្មភាពឯកតោភាគី**
Eng. unilateral act
Fr. acte unilatéral

សកម្មភាព ដែលបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ច ដោយការបង្ហាញឆន្ទៈនៃការចាត់ចែងទ្រព្យ ដោយភាគីតែម្ខាង ឬដោយអនុវត្តសិទ្ធិ ដែលបានទទួលតាមកិច្ចសន្យា ឬតាមបញ្ញត្តិនៃច្បាប់ ។

១៤២. **សច្ចានុមតិ**
Eng. ratification
Fr. ratification

១-ការយល់ព្រមទទួលស្គាល់ ដែលមានអានុភាពប្រតិសកម្ម ។
ឧ.ក្មេងម្នាក់ (១៧ឆ្នាំ) ធ្វើកិច្ចសន្យាមួយ កិច្ចសន្យានោះមិនពេញលក្ខណៈច្បាប់ទេ ។ តែបើក្មេងនោះ ផ្តល់សច្ចានុមតិ (ផ្តល់ការយល់ព្រម) លើកិច្ចសន្យានោះ ក្រោយពេលវាធំពេញវ័យ (១៨ឆ្នាំ) កិច្ចសន្យានោះ ក្លាយជាកិច្ចសន្យាពេញលក្ខណៈច្បាប់ ។
២-ការទទួលស្គាល់របស់ភាគី ចំពោះសកម្មភាពបណ្តឹង ដែលបានធ្វើឡើង ដោយបុគ្គលដែលខ្វះសិទ្ធិតំណាងដោយអាណត្តិ ហើយការទទួលស្គាល់នោះត្រូវមានអានុភាពប្រតិសកម្មតាំងពីពេលដែលសកម្មភាពនោះបានធ្វើឡើង ។

១៤៣. **សន្តតិកម្ម**
Eng. succession
Fr. succession

ការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ ឬច្រើននាក់ តាមឆន្ទៈ ឬតាមច្បាប់ ។

១៤៤. **សន្តតិជន**
Eng. successor
Fr. héritier

ជន ដែលទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនតាមរយៈសន្តតិកម្ម ។

១៤៥. **សមត្ថជន**
Eng. person of full capacity
Fr. capable / personne capable

ជនទាំងឡាយ ក្រៅពីជននៅក្រោមអាណាព្យាបាលទូទៅ និងក្រៅពីជននៅក្រោមហិតូបត្ថម្ភ និងអនីតិជន លើកលែងអនីតិជន ដែលទទួលបានអត្តាធីនភាព ។

១៤៦. **សមត្ថភាព**
Eng. capacity
Fr. capacité

លក្ខណសម្បត្តិរបស់បុគ្គល ដែលតម្រូវដោយច្បាប់រួមមាន :
-លក្ខណសម្បត្តិ ដែលអាចក្លាយជាម្ចាស់សិទ្ធិ និងកាតព្វកិច្ច (សមត្ថភាពទទួលសិទ្ធិ) ។
-លក្ខណសម្បត្តិ ដែលអាចយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធផលតាម

# ស

១៣៩. **សកម្មភាព**

Eng. **a**ct
Fr. **a**cte

តាមក្រមរដ្ឋប្បវេណីមានន័យថា ការបង្ហាញឆន្ទៈ តាមរយៈកិច្ចសន្យា ឬជាឯកតោភាគី។

១៤០. **សកម្មភាពសុពល**

Eng. **v**alid act
Fr. **a**cte valuable

សកម្មភាព ដែលធ្វើឡើងស្របតាមលក្ខខណ្ឌតម្រូវ ដោយច្បាប់ និងមានអានុភាពតាមផ្លូវច្បាប់។

១៤១. **សកម្មភាពឯកតោភាគី**

Eng. **u**nilateral act
Fr. **a**cte unilatéral

សកម្មភាព ដែលបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ច ដោយការបង្ហាញឆន្ទៈនៃការចាត់ចែងទ្រព្យ ដោយភាគីតែម្ខាង ឬដោយអនុវត្តសិទ្ធិដែលបានទទួលតាមកិច្ចសន្យា ឬតាមបញ្ញត្តិនៃច្បាប់។

១៤២. **សច្ចានុមតិ**

Eng. **r**atification
Fr. **r**atification

១-ការយល់ព្រមទទួលស្គាល់ ដែលមានអានុភាពប្រតិសកម្ម។

ឧ.ក្មេងម្នាក់ (១៧ឆ្នាំ) ធ្វើកិច្ចសន្យាមួយ កិច្ចសន្យានោះមិនពេញលក្ខណៈច្បាប់ទេ។ តែបើក្មេងនោះ ផ្តល់សច្ចានុមតិ (ផ្តល់ការយល់ព្រម) លើកិច្ចសន្យានោះ ក្រោយពេលវាធំពេញវ័យ (១៨ឆ្នាំ) កិច្ចសន្យានោះ ក្លាយជាកិច្ចសន្យាពេញលក្ខណៈច្បាប់។

២-ការទទួលស្គាល់របស់ភាគី ចំពោះសកម្មភាពបណ្តឹង ដែលបានធ្វើឡើងដោយបុគ្គលដែលខ្វះសិទ្ធិតំណាងដោយអាណត្តិ ហើយការទទួលស្គាល់នោះត្រូវមានអានុភាពប្រតិសកម្មតាំងពីពេលដែលសកម្មភាពនោះបានធ្វើឡើង។

១៤៣. **សន្តតិកម្ម**

Eng. **s**uccession
Fr. **s**uccession

ការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនទៅឱ្យសន្តតិជនម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់។

១៤៤. **សន្តតិជន**

Eng. **s**uccessor
Fr. **h**éritier

ជន ដែលទទួលបន្តនូវសិទ្ធិ និងករណីយកិច្ចរបស់មតកជនតាមរយៈសន្តតិកម្ម។

១៤៥. **សមត្ថជន**

Eng. **p**erson of full capacity
Fr. **c**apable / **p**ersonne capable

ជនទាំងឡាយ ក្រៅពីជននៅក្រោមអាណាព្យាបាលទូទៅ និងក្រៅពីជននៅក្រោមហិតូបត្ថម្ភ និងអនីតិជន លើកលែងអនីតិជន ដែលទទួលបានអត្តាធីនភាព។

១៤៦. **សមត្ថភាព**

Eng. **c**apacity
Fr. **c**apacité

លក្ខណសម្បត្តិរបស់បុគ្គល ដែលតម្រូវដោយច្បាប់រួមមាន :

-លក្ខណសម្បត្តិ ដែលអាចក្លាយជាម្ចាស់សិទ្ធិ និងកាតព្វកិច្ច (សមត្ថភាពទទួលសិទ្ធិ)។

-លក្ខណសម្បត្តិ ដែលអាចយល់ដឹង និងវិនិច្ឆ័យបានអំពីលទ្ធផលតាម

# រ ល

១២៦. **រតនសម្បត្តិ**
Eng. **a**ncestral heirloom
Fr. **s**ouvenir de famille

១-តាមន័យទូទៅ : វត្ថុដែលមានតម្លៃ។

២-តាមក្រមរដ្ឋប្បវេណី មានន័យថា ចលនវត្ថុប្រចាំត្រកូល ដែលជាកេរដំណែលពីបុព្វជន។

១២៧. **រូបវន្តបុគ្គល**
Eng. **n**atural person
Fr. **p**ersonne physique

មនុស្សពិតតាមធម្មជាតិ ដែលផ្ទុយនឹងនីតិបុគ្គល។

១២៨. **រូបិយវត្ថុ**
Eng. **m**oney
Fr. **m**onnaie

ឧបករណ៍កំណត់ដោយច្បាប់ ដែលប្រើប្រាស់ជាមធ្យោបាយសម្រាប់ដោះដូរ។

ឧ. ប្រាក់រៀល ជារូបិយវត្ថុរបស់ព្រះរាជាណាចក្រកម្ពុជា។

១២៩. **លក្ខន្តិកៈ**
Eng. **m**emorandum and articles of association / **b**y(e)-laws
Fr. **s**tatut

លិខិតបង្កើតនីតិបុគ្គល ដែលមានចុះនិទ្ទេសចាំបាច់ ខ្វះមិនបាន អំពីចំណុចសំខាន់ៗដូចជា គោលបំណង នាមករណ៍ ទីតាំងនៃទីស្នាក់ការកណ្ដាល ។ល។

១៣០. **លទ្ធកម្ម**
Eng. **a**cquisition
Fr. **a**cquisition

១-ការទទួលបាន។

២-ការបានឡើងជាម្ចាស់សិទ្ធិនៃវត្ថុណាមួយ ដោយការងាររបស់ខ្លួនក្តី ដោយទិញ ឬដោយដូរក្តី។

១៣១. **លិខិតយថាភូត**
Eng. **a**uthentic deed
Fr. **a**cte authentique

លិខិត ធ្វើឡើងតាមរូបមន្តច្បាប់ ដោយមន្ត្រីសាធារណៈ ដែលត្រូវបានអនុញ្ញាតឱ្យប្រតិបត្តិមុខងារនោះ។ តាមន័យចង្អៀតគឺជា លិខិតទាំងឡាយដែលរៀបចំឡើងដោយសារការី។

១៣២. **លិខិតឯកជន**
Eng. **p**rivate deed
Fr. **a**cte sous-seing privé

លិខិតទាំងឡាយណា ដែលបង្កើតឡើងដោយបុគ្គលឯកជន ដោយមានចុះហត្ថលេខា ឬស្នាមមេដៃ។

# ឧបសម្ព័ន្ធទី ៣
# ច្បាប់ស្តីពី នីតិវិធីនៃរឿងក្តី
# រដ្ឋប្បវេណីមិនមែនជាបណ្តឹង
# ឆ្នាំ២០១១

នស/រកម/០៣០៨/០១១

# ព្រះរាជក្រម

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរជ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីនីតិវិធីនៃការពិន័យស៊ីវិល ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភា បានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL

**មាត្រា ១៧.**_ វិសាលភាពនៃបុគ្គលដែលទទួលនូវអានុភាពនៃសាលក្រម ឬ សាលដីកាស្ថាពរ

១- ទោះបីជាមានបញ្ញត្តិនៃមាត្រា ១៩៨ (វិសាលភាពបុគ្គលដែលត្រូវទទួលអានុភាពរបស់សាលក្រមស្ថាពរ) នៃក្រមនីតិវិធីរដ្ឋប្បវេណីក៏ដោយ ក៏សាលក្រម ឬ សាលដីកាស្ថាពរនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលមានអានុភាពចំពោះតតិយជនដែរ ។

២-ក្នុងករណីដែលមានការទាមទារឱ្យលុបចោលនូវអាពាហ៍ពិពាហ៍ដោយយកមូលហេតុផ្អែកនឹងបញ្ញត្តិនៃមាត្រា ៩៤៩ (ការហាមឃាត់មិនឱ្យមានទ្វេពន្ធភាព) នៃក្រមរដ្ឋប្បវេណី ហើយបើការទាមទារនេះត្រូវបានច្រានចោល ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏សាលក្រម ឬ សាលដីកាស្ថាពរដែលច្រានចោលការទាមទារនោះ មានអានុភាពចំពោះសហព័ទ្ធនៃអាពាហ៍ពិពាហ៍មុន លុះត្រាតែសហព័ទ្ធនៃអាពាហ៍ពិពាហ៍មុននោះ បានចូលរួមអន្តរាគមន៍ក្នុងបណ្តឹងដែលពាក់ព័ន្ធនឹងការទាមទារនោះ ដោយយោងតាមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី ។

# ឧបសម្ព័ន្ធទី ៤
# សេចក្តីកំណត់មាត្រានីមួយៗ
# ក្រមរដ្ឋប្បវេណី
# នៃព្រះរាជាណាចក្រកម្ពុជា
# ឆ្នាំ២០០៩

# ជំពូកទី ៣ សន្តតិកម្មតាមមតកសាសន៍

## ផ្នែកទី ១ សមត្ថភាពក្នុងការធ្វើមតកសាសន៍

**មាត្រា ១១៦៨.–** បុគ្គលដែលអាចធ្វើមតកសាសន៍បាន

១-បុគ្គលដែលជានីតិជន និង អនីតិជនដែលបានអត្តាធីនភាពរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬ អំណាចមេបា អាចធ្វើមតកសាសន៍បាន ។

២-បញ្ញត្តិនៃមាត្រា ២៦ (សិទ្ធិលុបចោលសកម្មភាព) និង មាត្រា ៣០ (សិទ្ធិលុបចោលសកម្មភាព) នៃក្រមនេះ មិនត្រូវយកមកអនុវត្តចំពោះមតកសាសន៍ឡើយ ។

(កំណត់)

មាត្រានេះចែងថា បុគ្គលដែលជានីតិជន និង អនីតិជនដែលបានអត្តាធីនភាពរួចផុតពីអាណាព្យាបាលសម្រាប់អនីតិជន ឬ អំណាចមេបា អាចធ្វើមតកសាសន៍បាន ។

ជាបឋម កថាខណ្ឌទី ១ ចែងថា បុគ្គលដែលជានីតិជនអាចធ្វើមតកសាសន៍បាន ។ ទោះបីជាអ្នកនៅក្រោមអាណាព្យាបាលទូទៅ ឬ អ្នកនៅក្រោមហិតូបត្ថម្ភ ដែលបានទទួលការប្រកាសចាប់ផ្ដើមអាណាព្យាបាល ឬ ហិតូបត្ថម្ភក៏ដោយ (មាត្រា ២៤, មាត្រា ២៨) ក៏អាចធ្វើមតកសាសន៍បានដែរ ។ ក៏ប៉ុន្តែ ដើម្បីធ្វើមតកសាសន៍ ជនទាំងនេះត្រូវមានសមត្ថភាពខាងឆន្ទៈ (មាត្រាបន្ទាប់) ហើយចំពោះការធ្វើមតកសាសន៍របស់អ្នកនៅក្រោមអាណាព្យាបាលទូទៅដោយផ្អែកទៅតាមមាត្រា ១១៧៦ ជននោះត្រូវសះស្បើយមួយរយៈពេលឡើងវិញ នូវសមត្ថភាពក្នុងការយល់ដឹង និងវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ហើយចាំបាច់ត្រូវមានវត្តមានរបស់វេជ្ជបណ្ឌិតយ៉ាងតិច ២ នាក់ ។ ការទទួលស្គាល់ឱ្យអ្នកដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព ឱ្យធ្វើមតកសាសន៍នេះ ដោយសារតែមតក-



សាសន៍នោះនឹងមានអានុភាព ក្រោយពេលដែលជនដែលត្រូវបានកម្រិតនូវសមត្ថភាពនោះបានទទួលមរណភាព ដូច្នេះអានុភាពនៃមតកសាសន៍នោះ មិនមានឥទ្ធិពលទៅលើជីវភាពរស់នៅរបស់បុគ្គលនោះទេ ម្យ៉ាងទៀត មតកសាសន៍ធ្វើឡើងដើម្បីចាត់ចែងទ្រព្យសម្បត្តិដែលមាន គឺមិនមែនដើម្បីឱ្យខ្ចីទ្រព្យថ្មីទៀត ជាអាទិ៍ ទេ ។ បន្ទាប់មក កថាខណ្ឌទី ១ ចែងថា អនីតិជនដែលបានអត្តាធីនភាពរួចផុតពីអាណាព្យាបាល ឬ ពីអំណាចមេបា ក៏អាចធ្វើមតកសាសន៍បានដែរ ។ មាត្រា ៩៦១ នៃក្រមរដ្ឋប្បវេណីជប៉ុន ចែងថា អនីតិជនដែលមានអាយុចាប់ពី ១៥ ឆ្នាំ ឡើងទៅ អាចធ្វើមតកសាសន៍បាន ក៏ប៉ុន្តែ ក្នុងក្រមនេះចែងទៅតាមមាត្រា ៥៣១ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ។

ដោយសារជននៅក្រោមអាណាព្យាបាលទូទៅ ឬ ជននៅក្រោមហិតូបត្ថម្ភ អាចធ្វើមតកសាសន៍បាន ដូច្នេះកថាខណ្ឌទី ២ ចែងថា អ្នកអាណាព្យាបាលទូទៅ ឬ ហិតូបត្ថម្ភកៈមិនអាចលុបមតកសាសន៍ចោលបានទេ ។

(មាត្រាពាក់ព័ន្ធ)

ចំពោះវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ សូមមើលមាត្រា ៥៣១ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា រីឯចំពោះកថាខណ្ឌទី ២ វិញ សូមមើលមាត្រា ៩៦២ នៃក្រមរដ្ឋប្បវេណីជប៉ុន ។ មាត្រា ៥៣២ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ចែងផ្ទុយនឹងវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ។

**មាត្រា ១១៧៦.–** មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ

១-ដើម្បីធ្វើមតកសាសន៍ នៅពេលដែលជននៅក្រោមអាណាព្យាបាលទូទៅ បានសះស្បើយមួយរយៈឡើងវិញ នូវសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ត្រូវមានវត្តមានរបស់វេជ្ជបណ្ឌិត យ៉ាងតិច ២ (ពីរ) នាក់ ។

២-វេជ្ជបណ្ឌិតដែលមានវត្តមាននៅពេលធ្វើមតកសាសន៍ ត្រូវសរសេរបញ្ជាក់បន្ថែមលើលិខិតមតកសាសន៍នោះថា នៅពេលដែលម្ចាស់បណ្ដាំបានធ្វើមតកសាសន៍នោះ ម្ចាស់បណ្ដាំពុំបានស្ថិតក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិស្មារតីទេ ហើយត្រូវចុះហត្ថលេខាដោយបញ្ជាក់ថា ខ្លួនជាវេជ្ជបណ្ឌិតផងដែរ ។

(កំណត់)

មាត្រានេះចែងអំពីវិធីធ្វើមតកសាសន៍ក្នុងករណីដែលម្ចាស់បណ្ដាំជាជននៅក្រោមអាណាព្យាបាលទូទៅ ។

ទោះបីជាអ្នកនៅក្រោមអាណាព្យាបាលទូទៅក៏ដោយ ក៏អាចមានពេលដែលបុគ្គលនោះបានសះស្បើយមួយរយៈឡើងវិញ នូវសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យនូវលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដែរ ដូច្នេះ បញ្ញត្តិនេះទទួលស្គាល់នូវការធ្វើមតកសាសន៍ នៅពេលនោះ ។ មាត្រា ៩៥៤ ទទួលស្គាល់នូវអាពាហ៍ពិពាហ៍របស់អ្នកនៅក្រោមអាណាព្យាបាលទូទៅ ដូច្នេះ ចំពោះការធ្វើមតកសាសន៍ ក៏ត្រូវទទួលការពិចារណាដូចគ្នាដែរ ។ តែចាំបាច់ត្រូវមានគ្រូពេទ្យយ៉ាងតិច ២ នាក់ នៅពេលធ្វើមតកសាសន៍ ដើម្បីធ្វើការបញ្ជាក់មើលថា ម្ចាស់បណ្ដាំពិតជាបានសះស្បើយមួយរយៈឡើងវិញនូវសមត្ថភាពធ្វើមតកសាសន៍ ដើម្បីជៀសវាងជម្លោះនៅពេលអនាគត ។ ប៉ុន្តែ ក្នុងករណីដែលអនីតិជនបានត្រូវប្រកាសឱ្យស្ថិតនៅក្រោមអាណាព្យាបាលទូទៅ តាមមាត្រា ២៤ ហើយបានក្លាយជាជននៅក្រោមអាណាព្យាបាលទូទៅ ជននោះមិនអាចអនុវត្តតាមមាត្រានេះបានទេ រហូតដល់ខ្លួនបានក្លាយជានីតិជន (សូមមើលមាត្រា ១១៦៨) ។

កថាខណ្ឌទី ២ ចែងអំពីកាតព្វកិច្ចរបស់គ្រូពេទ្យ ដែលមានវត្តមាននៅពេលធ្វើមតកសាសន៍ ។ នេះគឺដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់អំពីការអនុវត្តតាមនីតិវិធី នៅក្នុងមតកសាសន៍នោះ ។ម្យ៉ាងទៀត ចំពោះករណីដែលចាំបាច់មានវត្តមានរបស់សាក្សី ដូចជាការធ្វើមតកសាសន៍ដោយលិខិតយថាភូត ជាអាទិ៍ ត្រូវមានវត្តមានសាក្សីផ្សេង ក្រៅពីគ្រូពេទ្យផងដែរ ។ ប្រសិនបើជនដែលនៅក្រោមអាណាព្យាបាលទូទៅ ធ្វើមតកសាសន៍ដោយលិខិតឯកជន ឬ ធ្វើមតកសាសន៍ដោយលិខិតសម្ងាត់ នៅក្នុងករណីនីមួយៗនេះ ចាំបាច់ត្រូវមានវត្តមានរបស់គ្រូពេទ្យដែលមានចែងក្នុងកថាខណ្ឌទី ១ នៅពេលជននោះសរសេរមតកសាសន៍ដោយផ្ទាល់ ឬ នៅពេលជននោះបង្ហាញខ្លឹមសារនៃមតកសាសន៍ទៅឱ្យសារការី ។

ម្យ៉ាងទៀត ក្នុងករណីដែលជននៅក្រោមអាណាព្យាបាលទូទៅ ធ្វើមតកសាសន៍ ត្រូវអនុវត្តតាមមាត្រា ១១៩៧ ហើយប្រសិនបើបានធ្វើមតកសាសន៍ចំពោះអ្នកអាណាព្យាបាល ជាអាទិ៍ គឺត្រូវមានកម្រិត ។

# ឧបសម្ព័ន្ធទី ៥

# ច្បាប់ស្តីពី បណ្តឹងទាក់ទងនឹងឋានៈបុគ្គល

# ព្រះរាជក្រម

នស/រកម/០៦១០/០០៩

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្មហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

លេខ ថ្ងៃទី ឆ្នាំ២០១០ ម៉ោង
បញ្ជូនទៅ

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៧ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE
ROYAL

**មាត្រា ៣.**_វិសាលភាពនៃច្បាប់នេះ:

ច្បាប់នេះ មានវិសាលភាពអនុវត្តលើបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលរួមមានបណ្តឹងដូចខាងក្រោមនេះ ៖

ក- បណ្តឹងទាមទារឱ្យបញ្ជាក់អំពីមោឃភាពនៃអាពាហ៍ពិពាហ៍ តាមបញ្ញត្តិនៃមាត្រា ៩៥៨ (មោឃភាពនៃអាពាហ៍ពិពាហ៍) នៃក្រមរដ្ឋប្បវេណី ។

ខ- បណ្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍ តាមបញ្ញត្តិចាប់ពីមាត្រា ៩៥៩ (ការលុបចោលអាពាហ៍ពិពាហ៍) ដល់មាត្រា ៩៦៣ (ការលុបចោលអាពាហ៍ពិពាហ៍ ដោយការឆបោក ឬ ការគំរាម) នៃក្រមរដ្ឋប្បវេណី ។

គ- បណ្តឹងទាមទារលែងលះគ្នា តាមបញ្ញត្តិនៃមាត្រា ៩៧៨ (មូលហេតុនៃការលែងលះគ្នា) នៃក្រមរដ្ឋប្បវេណី ។

ឃ- បណ្តឹងបដិសេធបិតុភាព តាមបញ្ញត្តិនៃមាត្រា ៩៩០ (បណ្តឹងបដិសេធបិតុភាពពីជនដែលត្រូវបានសន្មតថាជាឪពុក) និងមាត្រា៩៩១ (បណ្តឹងបដិសេធបិតុភាពពីកូន) នៃក្រមរដ្ឋប្បវេណី ។

ង-បណ្តឹងទាមទារឱ្យទទួលស្គាល់ តាមបញ្ញត្តិនៃមាត្រា ១០០១ (បណ្តឹងទាមទារឱ្យទទួលស្គាល់) នៃក្រមរដ្ឋប្បវេណី ។

ច- បណ្តឹងដែលមានគោលបំណងបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព តាមបញ្ញត្តិនៃមាត្រា ១០០២ (បណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព) នៃក្រមរដ្ឋប្បវេណី ។

ឆ- បណ្តឹងដែលមានគោលបំណងបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព តាមបញ្ញត្តិនៃមាត្រា ១០០៤ (បណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាពពីកូន) និង មាត្រា ១០០៥ (បណ្តឹងទាមទារឱ្យបញ្ជាក់



អំពីអត្ថិភាពនៃមាតុភាពពីម្តាយ) នៃក្រមរដ្ឋប្បវេណី ។

ជ- បណ្តឹងទាមទារកាត់កាល់ តាមបញ្ញត្តិនៃមាត្រា១០១៦ (ការកាត់កាល់នៃស្នុំកូនពេញលេញ) នៃក្រមរដ្ឋប្បវេណី ។

ឈ- បណ្តឹងទាមទារកាត់កាល់ តាមបញ្ញត្តិនៃមាត្រា ១០៣១ (មូលហេតុនៃការកាត់កាល់) នៃក្រមរដ្ឋប្បវេណី។

ញ- បណ្តឹងផ្សេងទៀតដែលមានគោលបំណងបង្កើត បញ្ជាក់អត្ថិភាព ឬ នត្ថិភាពនៃទំនាក់ទំនងនឹងឋានៈបុគ្គល។

**មាត្រា ៨.–** សមត្ថភាពក្នុងការធ្វើបណ្ដឹង ក្នុងបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ជាអាទិ៍

១- ចំពោះសកម្មភាពបណ្ដឹងក្នុងនីតិវិធីបណ្ដឹងនៃបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល បញ្ញត្តិនៃមាត្រា ១៨ (សិទ្ធិលុបចោលសកម្មភាព) មាត្រា ២៦ (សិទ្ធិលុបចោលសកម្មភាព) និង មាត្រា ៣០ (សិទ្ធិលុបចោលសកម្មភាព) នៃក្រមរដ្ឋប្បវេណី និង កថាខណ្ឌទី ៣ នៃមាត្រា ៣២ (សមត្ថភាពភាគី សមត្ថភាពក្នុងការធ្វើបណ្ដឹង ការតំណាងដែលច្បាប់បានកំណត់សម្រាប់ជនដែលគ្មានសមត្ថភាពក្នុងការធ្វើបណ្ដឹង) និង មាត្រា ៣៣ (បញ្ញត្តិពិសេសស្ដីពីសកម្មភាពបណ្ដឹងរបស់ជននៅក្រោមហិតូបត្ថម្ភ និង អ្នកតំណាងដែលច្បាប់បានកំណត់) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តឡើយ ។

២- ក្នុងករណីជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្ដឹង មានបំណងធ្វើសកម្មភាពបណ្ដឹងដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើយល់ឃើញថាចាំបាច់ ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចជ្រើសតាំងមេធាវីឱ្យធ្វើជាអ្នកតំណាងតាមពាក្យសុំបាន ។

Kol



៣- ទោះបីជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្ដឹង មិនដាក់ពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះក៏ដោយ ក៏ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចបង្គាប់ឱ្យជ្រើសតាំងមេធាវីជាអ្នកតំណាង ឬ អាចជ្រើសតាំងមេធាវីជាអ្នកតំណាងដោយឆន្ទានុសិទ្ធិបាន ។

៤- ចំនួនទឹកប្រាក់នៃកម្រៃដែលជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្ដឹង ត្រូវបង់ឱ្យមេធាវីដែលប្រធានក្រុមប្រឹក្សាជំនុំជម្រះបានជ្រើសតាំងជាអ្នកតំណាង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ឬ កថាខណ្ឌទី ៣ ខាងលើនេះ ត្រូវជាចំនួនទឹកប្រាក់ដែលតុលាការយល់ឃើញថាសមរម្យ ។

៥- ក្នុងចំណោមកម្រៃនិងសោហ៊ុយដែលបានបង់ឱ្យទៅមេធាវី ដែលប្រធានក្រុមប្រឹក្សាជំនុំជម្រះបានជ្រើសតាំង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ឬ កថាខណ្ឌទី៣ខាងលើនេះ ឬ បង់ឱ្យទៅមេធាវីដែលជនត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្ដឹងបានជ្រើសតាំង ក្នុងករណីដែលប្រធានក្រុមប្រឹក្សាជំនុំជម្រះបង្គាប់ឱ្យជ្រើសតាំង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ចំនួនទឹកប្រាក់ដែលតុលាការយល់ឃើញថាសមរម្យ ត្រូវក្លាយជាប្រាក់ប្រដាប់ក្ដី ។

**មាត្រា ២៦.–** ភាគីនៃបណ្ដឹងទាមទារឱ្យទទួលស្គាល់ ជាអាទិ៍

១- នៅក្នុងបណ្ដឹងទាមទារឱ្យទទួលស្គាល់ កូនត្រូវដាក់ពាក្យបណ្ដឹង ដោយយកឪពុកមកជាចុងចម្លើយ ។ ក្រោយមរណភាពរបស់ឪពុក ត្រូវយកតំណាងអយ្យការមកជាចុងចម្លើយ ។

២- ប្រសិនបើឪពុកដែលជាចុងចម្លើយ ទទួលមរណភាព នៅពេលដែលតុលាការកំពុងចាត់ការបណ្ដឹងទាមទារឱ្យទទួលស្គាល់នោះ តំណាងអយ្យការត្រូវទទួលបន្តនូវនីតិវិធីបណ្ដឹងនោះ ។

៣- ក្នុងករណីដែលកូនបានទទួលមរណភាព ក្រោយពីបានដាក់ពាក្យបណ្ដឹងទាមទារឱ្យទទួលស្គាល់ បច្ឆាញាតិផ្ទាល់របស់កូននោះ អាចទទួលបន្តនូវនីតិវិធីនៃបណ្ដឹងនោះ ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតពីថ្ងៃដែលកូននោះទទួលមរណភាព ទោះបីអំឡុងពេលដែលកំណត់ក្នុងកថាខណ្ឌទី ៣ ឬ កថាខណ្ឌទី ៥ នៃមាត្រា ១០០១ (បណ្ដឹងទាមទារឱ្យទទួលស្គាល់) នៃក្រមរដ្ឋប្បវេណី បានកន្លងផុតក៏ដោយ ។ បញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ១៧៣ (ការផ្អាកនិងការទទួលបន្តនូវនីតិវិធីនៃបណ្ដឹង) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តចំពោះករណីនេះឡើយ ។